ខ និងលក្ខខណ្ឌទូទៅ

មានសុពលភាពចាប់ពីថ្ងៃទី 17 ខែកក្កដា ឆ្នាំ2026

កំណែ 5.1

មាតិកា

សេចក្តីផ្តើម 2

1. និយមន័យ 3

ព័ត៌មានអំពីគណនី

2. ការគ្រប់គ្រងគណនី 5

3. ការប្រើប្រាស់គណនីរបស់អ្នក 8

4. ការយល់ដឹងអំពីកាតឥណពន្ធ 16

5. របាយការណ៍ធនាគាររបស់អ្នក 20

6. ការប្រើប្រាស់មូលប្បទានបត្រ 22

តម្លៃសេវា និងបន្ទុកនានា

7. តម្លៃសេវា និងបន្ទុកនានា 29

សុវត្ថិភាពគណនី និងការរ៉ាប់រង

8. សុវត្ថិភាព និងការរ៉ាប់រងលើការប្រើប្រាស់កាតនិងសេវាធនាគារអនឡាញ 31

9. ការរ៉ាប់រងលើប្រតិបត្តិការគ្មានការអនុញ្ញាត 32

ចំណុចផ្សេងទៀតដែលត្រូវដឹង

10. ការកែប្រែ ខ និងលក្ខខណ្ឌ 34

11. កិច្ចការទូទៅ 35

12. ដំណោះស្រាយវិវាទ 40

សេចក្តីផ្តើម

ខ និងលក្ខខណ្ឌទូទៅទាំងនេះ (“ខ និងលក្ខខណ្ឌ”) ជាផ្នែកនៃកិច្ចព្រមព្រៀងដែលមានវិសាលភាពគ្រប់គ្រងលើការប្រើប្រាស់ផលិតផល និងសេវានានារបស់ធនាគារយើងខ្ញុំ ដោយរួមបញ្ចូលទាំងគណនីផងដែរ។ ខ និងលក្ខខណ្ឌទាំងនេះនឹងត្រូវយកមកអនុវត្ត នៅពេលអ្នកទទួលយកនូវផលិតផល និងសេវាធនាគារ ដោយការចុះហត្ថលេខាលើទម្រង់បែបបទនានា ឬដោយផ្តល់ការយល់ព្រមតាមប្រព័ន្ធអេឡិកត្រូនិក។

ខ និងលក្ខខណ្ឌទាំងនេះ មិនតំណាងឲ្យរាល់ ខ និងលក្ខខណ្ឌទាំងអស់សម្រាប់ផលិតផល និងសេវាធនាគារយើងខ្ញុំ ដែលបានផ្តល់ជូនឡើយ។ ខ និងលក្ខខណ្ឌបន្ថែមដូចជា ខនិងលក្ខខណ្ឌ ឬលក្ខខណ្ឌផលិតផល និងសេវាកម្មជាក់លាក់មួយចំនួន អាចត្រូវបានអនុវត្តដោយច្បាប់ ឬខនិងលក្ខខណ្ឌផ្សេងៗទៀត ដែលអ្នកបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិកត្រូនិក។

ប្រសិនបើមានអសង្គតិភាពរវាង ខ និងលក្ខខណ្ឌទូទៅ និង ខ និងលក្ខខណ្ឌជាក់លាក់នៃផលិតផល ឬសេវាកម្មណាមួយ នោះខ និងលក្ខខណ្ឌជាក់លាក់សម្រាប់ផលិតផល ឬសេវាកម្មត្រូវមានអាទិភាព។

កូនសៀវភៅនេះ ចែងពី ខ និងលក្ខខណ្ឌគណនីរបស់អ្នក និងបង្កើតជាផ្នែកមួយនៃកិច្ចសន្យារបស់អ្នកជាមួយធនាគារ។ អ្នកត្រូវចាត់ទុកថាបានឯកភាពចងកាតព្វកិច្ចជាមួយ ខ និងលក្ខខណ្ឌទាំងនេះ ចាប់តាំងពីពេលដែលអ្នកប្រតិបត្តិការគណនីរបស់អ្នកលើកដំបូង ឬនៅពេលអ្នកបានយល់ព្រមនឹង ខ និងលក្ខខណ្ឌទាំងនេះ។ យើងខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកអានឯកសារនេះឲ្យបានយល់ច្បាស់ ឬក៏ស្នើសុំការប្រឹក្សាផ្នែកច្បាប់ នៅពេលអ្នកស្នើសុំបើកគណនីជាមួយយើងខ្ញុំ ឬនៅពេលអ្នកមានបំណងធ្វើប្រតិបត្តិការណាមួយ។

1. និយមន័យ

'ABA' ឬ 'ធនាគារ'	សំដៅលើ ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់
'គណនី'	មានន័យថា គណនីធនាគារណាមួយដែលបើកនៅធនាគារ។
'ម្ចាស់គណនី'	មានន័យថា បុគ្គលដែលមានឈ្មោះគណនី និងដែលទទួលខុសត្រូវចំពោះប្រតិបត្តិការទាំងអស់នៅក្នុងគណនីនោះ។
'ហត្ថលេខីទទួលសិទ្ធិ'	មានន័យថា ភាគីទីបីដែលត្រូវបានផ្តល់សិទ្ធិឲ្យប្រតិបត្តិការគណនី
'សមតុល្យក្នុងគណនី'	មានន័យថា សមតុល្យសរុបក្នុងគណនីរបស់អ្នកដោយដកចេញនូវប្រតិបត្តិការមិនទាន់ទូទាត់ និងកម្រិតឥណទានដែលអ្នកអាចមាននៅក្នុងគណនីរបស់អ្នកសម្រាប់គណនីរៀបចំជាឥណទានវិបារូបន៍។
'ថ្ងៃធ្វើការ'	មានន័យថា ថ្ងៃក្នុងសប្តាហ៍ដែលធនាគារបើកប្រតិបត្តិការ ក្រៅពីថ្ងៃឈប់សម្រាកបុណ្យជាតិ។ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ មិនមែនជាថ្ងៃធ្វើការឡើយ ទោះបីសាខារបស់យើងខ្ញុំមួយចំនួនបើកបម្រើសេវាក៏ដោយ។
'កូដ'	មានន័យថា លេខសម្ងាត់ (PIN), លេខកូដចូលប្រើសេវាធនាគារអេនឡាញ ABA, ពាក្យសម្ងាត់ធនាគារអេនឡាញ ឬ ព័ត៌មានប្រហាក់ប្រហែលដែលត្រូវការចាំបាច់សម្រាប់ធ្វើប្រតិបត្តិការផ្ទេរប្រាក់ទៅ ឬមករវាងគណនីនានា ហើយដែលអ្នកប្រើប្រាស់ចាំបាច់ត្រូវរក្សាទុកជាសម្ងាត់។
'អតិថិជន'	រាប់បញ្ចូលទាំងម្ចាស់គណនី ABA និងម្ចាស់គណនីមិនមែន ABA ដែលប្រើប្រាស់សេវាកម្ម ABA ម្តងម្កាល។ អតិថិជនទាំងអស់ត្រូវឆ្លងកាត់ទម្រង់ផ្សេងៗគ្នានៃការយកចិត្តទុកដាក់ស្គាល់អតិថិជន
'ឧបករណ៍អេឡិកត្រូនិក' ឬ 'ម៉ាស៊ីនអេឡិកត្រូនិក'	មានន័យថា ម៉ាស៊ីនអេឡិកត្រូនិក (ដូចជា ម៉ាស៊ីន ATM ម៉ាស៊ីនដាក់ប្រាក់ ម៉ាស៊ីនទូទាត់ POS និងម៉ាស៊ីនដែលស្ថិតនៅតាមបញ្ជរសាខា) កុំព្យូទ័រ ទូរស័ព្ទ និងឧបករណ៍អេឡិកត្រូនិកផ្សេងទៀត ដែលចាំបាច់សម្រាប់ធ្វើប្រតិបត្តិការសេវាធនាគារ។
'អ្នក' 'របស់អ្នក'	សំដៅដល់ម្ចាស់គណនី ឬហត្ថលេខីទទួលសិទ្ធិ
'យើងខ្ញុំ' 'របស់យើងខ្ញុំ'	សំដៅដល់ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់
'ប្រតិបត្តិការ'	ត្រូវបានកំណត់ដូចខាងក្រោម (រួមបញ្ចូល ដោយមិនកំណត់ត្រឹម)៖ ▪ សរសេរ, ចុះហត្ថលេខា និងអនុញ្ញាតលើមូលប្បទានបត្រ ឬឧបករណ៍នានាសម្រាប់ការទូទាត់។ ▪ ទូទាត់ប្រាក់, មូលប្បទានបត្រ, ក្រដាសប្រាក់, រូបិយាណត្តិ, បញ្ជាទូទាត់ និងរាល់ឧបករណ៍ផ្សេងៗទៀត។ ▪ បើក និងបិទគណនី ▪ ស្នើសុំ និងទទួលការបញ្ជុះតម្លៃ, កម្ចី, ឥណទានវិបារូបន៍, ឧបករណ៍ហិរញ្ញប្បទានពាណិជ្ជកម្ម ឬឧបករណ៍ផ្សេងៗទៀត ដោយមាន ឬមិនមានទ្រព្យធានា ▪ ដាក់បញ្ចាំ និងដាក់តម្កល់ប្រភេទផ្សេងៗនៃទ្រព្យធានាសម្រាប់ការទូទាត់សងបំណុល ▪ ទទួលបានរបាយការណ៍ និង/ឬលិខិតទំនាក់ទំនងណាមួយ ▪ ស្នើប្រតិបត្តិការ មិនថា តាមមែល, អ៊ីមែល, ទូរស័ព្ទ, ទូរសារ ឬមធ្យោបាយផ្សេង និង/ឬចុះកិច្ចសន្យា និងកិច្ចព្រមព្រៀង
បុគ្គល	សំដៅដល់ឯកត្តជន/រូបវន្តបុគ្គល ឬនីតិបុគ្គល
ថ្ងៃសុពលភាពប្រតិបត្តិការ	សំដៅលើកាលបរិច្ឆេទដែលប្រតិបត្តិការមានសុពលភាព។ ថ្ងៃសុពលភាពប្រតិបត្តិការ អាចខុសពីថ្ងៃធ្វើប្រតិបត្តិការ។

ព័ត៌មានអំពីគណនី

2. ការគ្រប់គ្រងគណនី

2.1. ការបើកគណនី

ដោយអាស្រ័យលើប្រភេទគណនី អ្នកអាចស្នើសុំបើកគណនីបានតាមអនឡាញ ឬតាមសាខា ឬតាមការណាត់ជួបជាមួយបុគ្គលិកធនាគារ។ ដើម្បីបើកគណនីថ្មី អ្នកចាំបាច់ត្រូវ៖

- ស្របតាមលក្ខខណ្ឌពេញសិទ្ធិ ហើយអាចបញ្ជាក់លក្ខខណ្ឌពេញសិទ្ធិរបស់ខ្លួន ប្រសិនបើមានការស្នើសុំឲ្យបញ្ជាក់ និង
- ផ្តល់ឯកសារ និងព័ត៌មានជាក់លាក់មួយចំនួនដល់ធនាគារ ដែលរួមមាន ឈ្មោះ, អាសយដ្ឋាន, ថ្ងៃខែឆ្នាំកំណើត, លេខទូរស័ព្ទ និងមុខរបររបស់អ្នកជាដើម។

យោងតាមច្បាប់របស់ធនាគារជាតិនៃកម្ពុជាស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ធនាគារ ត្រូវកំណត់អត្តសញ្ញាណម្ចាស់គណនី (រួមជាមួយនឹងហត្ថលេខីទទួលសិទ្ធិ និងបុគ្គលទាំងអស់ដែលពាក់ព័ន្ធនឹងគណនី)។ អ្នកអាចបំពេញតាមលក្ខខណ្ឌតម្រូវ អំពីការកំណត់អត្តសញ្ញាណដោយផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណច្បាប់ដើម និងមានសុពលភាពដល់ធនាគារ។ ប្រសិនបើអ្នក ឬហត្ថលេខីណាមួយនៃគណនីមិនបានផ្តល់អត្តសញ្ញាណស្របទៅតាមច្បាប់ពាក់ព័ន្ធ ឬអ្នកមិនបានបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ជាធរមានអំពីការយកចិត្តទុកដាក់ស្គាល់អតិថិជននោះទេ ធនាគារមានសិទ្ធិចាត់វិធានការណាមួយតាមដែលច្បាប់កម្ពុជាអនុញ្ញាត រួមមាន ការបិទគណនីរបស់អ្នកផងដែរ។ ប្រសិនបើអ្នកជាអតិថិជនចាស់ ឬអតិថិជនបច្ចុប្បន្ន អ្នកត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវអំពីការកំណត់អត្តសញ្ញាណរួចរាល់ ដូច្នេះ ប្រសិនបើធនាគារមិនបានតម្រូវ ឬស្នើសុំទេ អ្នកពុំចាំបាច់ផ្តល់ជូនម្តងទៀតឡើយ។

ដើម្បីបំពេញកាតព្វកិច្ចប្រតិបត្តិតាម និងបទប្បញ្ញត្តិរបស់ធនាគារ ធនាគារត្រូវតែប្រតិបត្តិតាមបញ្ជីទណ្ឌកម្មណាមួយសមស្របចំពោះប្រទេសកម្ពុជា និងបញ្ជីទណ្ឌកម្មណាមួយប្រើប្រាស់ដោយធនាគារ (ជារួមហៅកាត់ថា "ទណ្ឌកម្ម") នៅពេលទទួលយកអតិថិជន។ ហេតុនេះ អ្នកត្រូវអះអាងបញ្ជាក់ និងធានាថា អ្នកមិនស្ថិតក្រោមទណ្ឌកម្មណាមួយឡើយ ("បុគ្គលជាប់ទណ្ឌកម្ម") នៅពេលដែលអ្នកស្នើសុំបើកគណនី ឬសេវា ហើយគ្រប់ពេលវេលា អ្នករក្សានូវទំនាក់ទំនងសេវាធនាគារជាមួយយើងខ្ញុំ។ ប្រសិនបើអ្នកបើកគណនីក្នុងនាមជានីតិបុគ្គល (ដូចជា ក្រុមហ៊ុន, សាខា, ការិយាល័យតំណាង, ដៃគូ ,សហគ្រាសឯកកម្មសិទ្ធិ, សមាគម, អង្គការក្រៅរដ្ឋាភិបាល ជាដើម) នោះអ្នកអះអាងបញ្ជាក់ និងធានាបន្ថែមថា ទាំងអ្នក, ទាំងបុត្រសម្ពន្ធ, អភិបាល, មន្ត្រី ឬភាគហ៊ុនិករបស់នីតិបុគ្គល, សម្ពន្ធ, ភ្នាក់ងារ ឬបុគ្គលិករបស់នីតិបុគ្គលនោះ តាមដែលអ្នកបានដឹង គឺមិនមែនជាបុគ្គលជាប់ទណ្ឌកម្មឡើយ។ ប្រសិនបើអ្នក ឬនីតិបុគ្គលត្រូវបានដាក់ទណ្ឌកម្មណាមួយ ធនាគារនឹងព្យួរ ឬបិទគណនី និងបញ្ចប់ទំនាក់ទំនងសេវាធនាគារជាមួយអ្នក ឬនីតិបុគ្គល។ នៅពេលគណនីត្រូវបានព្យួរ ឬបិទ ធនាគារ និងដៃគូនឹងមិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយដែលអ្នក នីតិបុគ្គល ឬបុគ្គលពាក់ព័ន្ធណាមួយអាចទទួលរងនោះឡើយ (រួមទាំងការខាតបង់បន្តបន្ទាប់) កើតឡើងដោយប្រការណាមួយ។

2.1.1. កាតព្វកិច្ចតម្រូវ សម្រាប់គណនីប្រាក់រៀល

ដើម្បីគាំទ្រដល់ការប្រើប្រាស់រូបិយប័ណ្ណជាតិ និងធានាបាននូវការត្រៀមខ្លួនសម្រាប់ប្រតិបត្តិការទូទាត់ក្នុងស្រុក ធនាគារតម្រូវឲ្យអតិថិជនទាំងអស់បើក និងក្សាគណនីប្រាក់រៀល (KHR) យ៉ាងហោចណាស់ចំនួនមួយគណនី ជាផ្នែកនៃដំណើរការចុះឈ្មោះបើកគណនី ឬលទ្ធកម្ម។

- ការទូទាត់ និងផ្ទេរប្រាក់ក្នុងស្រុក
- ការបើកដំណើរការ សេវាធនាគារចល័ត/ទូរស័ព្ទ
- គោលបំណងទំនាក់ទំនង និងបទប្បញ្ញត្តិនានា

ធនាគាររក្សាសិទ្ធិក្នុងការ៖

- បើកគណនីប្រាក់រៀលស្វ័យប្រវត្ត សម្រាប់អតិថិជនរូបណាដែលមិនទាន់មាន អំឡុងពេលចុះឈ្មោះបើកគណនី ឬលទ្ធកម្ម
- ផ្អាក ឬដាក់កម្រិតការចូលប្រើសេវាកម្មមួយចំនួន ប្រសិនបើអតិថិជនមិនបានក្សាគណនីប្រាក់រៀលឲ្យដំណើរការ
- អនុវត្តលក្ខខណ្ឌតម្រូវនេះ ទាំងចំពោះអតិថិជនរូបវន្តបុគ្គល និងអតិថិជនអាជីវកម្មលុះត្រាមានការលើកលែងណាមួយដែលបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ

2.2. ភាពជាម្ចាស់កម្មសិទ្ធិលើគណនី

អ្នកយល់ព្រមថា នៅពេលអ្នកបើកគណនី ដាក់កម្មសិទ្ធិគណនី (ដូចជា ភាពជាម្ចាស់លើគណនី) គឺត្រឹមត្រូវ និងថា ធនាគារមិនមានទំនួលខុសត្រូវក្នុងការជូនដំណឹងដល់អ្នកថា ការដាក់កម្មសិទ្ធិអាចប៉ះពាល់ដល់ផលប្រយោជន៍ផ្លូវច្បាប់របស់អ្នកកម្រិតណានោះទេ (ដូចជា ក្នុងករណីគណនីរួម ទ្រព្យសកម្មនឹងត្រូវមានរួមគ្នាដោយបុគ្គលនីមួយៗនៅលើគណនី)។ ប្រសិនបើអ្នកមានចម្ងល់ណាមួយអំពីសិទ្ធិ និងកាតព្វកិច្ចផ្លូវច្បាប់របស់អ្នកសម្រាប់គណនីណាមួយរបស់អ្នក អ្នកគប្បីប្រឹក្សាជាមួយមេធាវី ឬអ្នកប្រឹក្សារបស់អ្នក។ បទប្បញ្ញត្តិមួយចំនួនតម្រូវឲ្យអ្នកផ្តល់ឲ្យយើងខ្ញុំនូវព័ត៌មានពាក់ព័ន្ធនឹងម្ចាស់ផលប្រយោជន៍ណាមួយ និងបុគ្គលពាក់ព័ន្ធសម្រាប់គណនីនៅពេលបើកគណនី។ អ្នកក៏អាចត្រូវបានស្នើសុំឲ្យផ្តល់ព័ត៌មានទាំងនេះនៅពេលផ្សេងណាមួយតាមការស្នើសុំរបស់ធនាគារ។ នៅគ្រប់ពេលវេលា ប្រសិនបើយើងខ្ញុំកំណត់ឃើញថាព័ត៌មានម្ចាស់ផលប្រយោជន៍ និងបុគ្គលពាក់ព័ន្ធដែលអ្នកបានផ្តល់ជូនយើងខ្ញុំ មិនពិត មិនត្រឹមត្រូវ ឬមិនពាក់ព័ន្ធ មកធនាគារ ឬប្រសិនបើអ្នកបដិសេធមិនព្រមផ្តល់ជូនយើងខ្ញុំនូវព័ត៌មាននៅពេលស្នើសុំ យើងខ្ញុំអាចបិទ ឬបង្កកគណនីណាមួយ ឬទាំងអស់របស់អ្នក និងចាត់វិធានការផ្សេងណាមួយដែលច្បាប់កម្ពុជាអនុញ្ញាត។

2.2.1. គណនីបុគ្គល

គណនីណាមួយអាចកាន់កាប់ដោយម្ចាស់គណនីជាលក្ខណៈបុគ្គលស្របតាមលក្ខន្តិក នៃខនិងលក្ខខណ្ឌទូទៅ និងច្បាប់ជាធរមាន ។

2.2.2. គណនីរួម/គណនីទទួលសិទ្ធិ

ប្រសិនបើមានជម្រើសផ្សេងទៀតសម្រាប់គណនីរបស់អ្នក អ្នកអាចបើកគណនីរួមគ្នាជាមួយនឹងដៃគូរបស់ខ្លួន សមាជិកគ្រួសារ ឬជាក្រុមបាន ។ សមតុល្យនៅក្នុងគណនីរួម/គណនីទទួលសិទ្ធិនោះ ត្រូវបានគ្រប់គ្រងរួមគ្នាដោយម្ចាស់គណនីទាំងអស់ ។ មានន័យថា ម្ចាស់គណនីនីមួយៗសុទ្ធតែមានសិទ្ធិដកប្រាក់ដែលនៅសល់ក្នុងគណនីនោះទាំងអស់ ។ ម្ចាស់គណនីទាំងអស់ត្រូវតែចុះហត្ថលេខាលើឃ្លាញ្ញត្តិគណនី ដែលបញ្ជាក់អំពីរបៀបប្រតិបត្តិការគណនីរួមនេះជូនធនាគារ ។ សម្រាប់គណនីរួមគ្នា ឃ្លាញ្ញត្តិប្រតិបត្តិការដែលទទួលសិទ្ធិអាចរួមមានដូចខាងក្រោម៖

- ឯកតោភាគី – ដែលហត្ថលេខីអាចប្រើប្រាស់បានតែម្នាក់ឯង ឬ
- ពហុភាគី – ដែលហត្ថលេខីចាប់ពីពីរនាក់ឡើងទៅ ត្រូវប្រើប្រាស់រួមគ្នា ឬ
- X ណាមួយនៃ Z – ដែលយ៉ាងហោចណាស់ត្រូវមានហត្ថលេខី X ចំនួននៃហត្ថលេខី Z សរុប ត្រូវតែប្រើប្រាស់រួមគ្នា ។

ធនាគារយើងខ្ញុំមិនអាចទទួលឃ្លាញ្ញត្តិគណនីទាំងឡាយណាដែលហួសពីលក្ខខណ្ឌនីមួយៗខាងលើបានឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារ ។ សម្រាប់គណនីទទួលសិទ្ធិ ឃ្លាញ្ញត្តិគណនីត្រូវតែជាឯកតោភាគី ខណៈដែលហត្ថលេខីណាមួយអាចប្រើប្រាស់ដាច់ដោយឡែកពីគ្នា ។

ម្ចាស់គណនីរួម អាចផ្លាស់ប្តូរឃ្លាញ្ញត្តិគណនីនេះបានគ្រប់ពេលវេលា តាមរយៈការចុះហត្ថលេខាលើឃ្លាញ្ញត្តិគណនីថ្មីរួមគ្នា ។ ដោយមិនគិតអំពីឃ្លាញ្ញត្តិគណនីណាមួយដើម្បីធ្វើប្រតិបត្តិការ ភាគីនីមួយៗនៃគណនីរួមអាចស្នើសុំឲ្យយើងខ្ញុំធ្វើប្រតិបត្តិការគណនីសម្រាប់តែហត្ថលេខីដែលបានបញ្ជាក់នៅក្នុងឃ្លាញ្ញត្តិគណនីចុងក្រោយដែលបានផ្តល់ជូនយើងខ្ញុំ និងដែលមានប្រសិទ្ធភាព ។ សម្រាប់គណនីរួមដែលបានបើកនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី 01 ខែកុម្ភៈ ឆ្នាំ2016 ម្ចាស់គណនីរួមទាំងអស់ ត្រូវតែចុះហត្ថលេខាលើបែបបទស្នើសុំដើម្បីលុបចោលបញ្ជាត្តិគណនីដែលមានស្រាប់ទាំងអស់ ។ ផ្ទុយមកវិញ ម្ចាស់គណនីរួមអាចស្នើសុំឲ្យធនាគារ បិទគណនីរួមនេះបាន ដោយអនុវត្តតាមបញ្ជត្តិគណនីដែលបានកំណត់លក្ខខណ្ឌជាមុនដោយការរៀបចំរបស់ម្ចាស់គណនីរួមទាំងអស់ (ឧទាហរណ៍ បញ្ជត្តិគណនី X នៃ Z ដើម្បីគ្រប់គ្រងប្រតិបត្តិការ និងបិទគណនីសម្រាប់គណនីរួមណាមួយ ។ ដូច្នេះចំនួន X នៃហត្ថលេខីអាចស្នើសុំធនាគារឲ្យបិទគណនីរួម ដោយមិនចាំបាច់ប្រមូលហត្ថលេខារបស់ហត្ថលេខីចំនួន Z ឡើយ) ។

2.2.3. គណនីសម្រាប់អនីតិជន

អនីតិជន សំដៅលើរូបវន្តបុគ្គលដែលមានអាយុក្រោម 18 ឆ្នាំ ។ អនីតិជន អាចបើកគណនីធនាគារបាន ប្រសិនបើមានការចូលរួមពីនីតិជន ។ ធនាគារផ្តល់មធ្យោបាយជាប្រើនដល់អតិថិជនក្នុងការបើកគណនីជូនអនីតិជន ។ គណនីអនីតិជន នឹងត្រូវបើកជាប្រភេទគណនីរួមរវាងរូបអ្នក និងអនីតិជន លើកលែងតែមានការចែងដោយឡែកនៅក្នុងលក្ខខណ្ឌជាក់លាក់របស់យើងខ្ញុំ ។

ធនាគារ អនុញ្ញាតឲ្យអ្នកបើកគណនីជាមួយអនីតិជនបាន លុះត្រាតែអ្នកអាចបញ្ជាក់ថា អ្នកមានទំនាក់ទំនងស្របច្បាប់ជាមួយអនីតិជន ។ ទំនាក់ទំនងស្របច្បាប់រវាងអ្នក និងអនីតិជន អាចបញ្ជាក់បានតាមរយៈឯកសារមួយចំនួន ដូចជាសំបុត្រកំណើត, លិខិតឆ្លងដែនរបស់អនីតិជន (ដែលក្នុងឯកសារទាំងនេះបានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងរវាងរូបអ្នក និងអនីតិជន), សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬប្រភេទឯកសារផ្សេងទៀតដែលធនាគារអាចទទួលយកតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

ទោះបីគណនីនេះ ជាគណនីរួម អ្នកនៅតែជាម្ចាស់ផ្តាច់មុខនៃគណនីនេះ ដែលមានន័យថា អ្នកជាបុគ្គលមានសិទ្ធិតែម្នាក់គត់ដែលត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការ និងបិទគណនីនេះ ។

ពេលអនីតិជន ពេញវ័យគ្រប់គ្រាន់ អ្នកអាចផ្ទេរម្ចាស់កម្មសិទ្ធិគណនី ឬអនុញ្ញាតឲ្យអនីតិជនធ្វើប្រតិបត្តិការគណនីតាមឆន្ទានុសិទ្ធិរបស់អ្នក ដោយអញ្ជើញមកធនាគារដើម្បីចុះហត្ថលេខាលើទម្រង់បែបបទចាំបាច់មួយចំនួន ឬដោយការផ្តល់សិទ្ធិអនុញ្ញាតរបស់អ្នក តាមរយៈបណ្តាញផ្សេងៗទៀតរបស់ធនាគារ រួមមានបណ្តាញអេឡិកត្រូនិកផងដែរ ។ ទោះបីជាគណនីរួម ក្នុងពេលណាមួយ អាចត្រូវបានប្រើប្រាស់ដោយអ្នក ឬអនីតិជន ឬទាំងរូបអ្នក និងអនីតិជនរួមគ្នា ទំនួលខុសត្រូវនៃគណនីនេះ គឺជាទំនួលខុសត្រូវរួម លុះត្រាតែអ្នកបានផ្ទេរកម្មសិទ្ធិពេញលេញ និងបានដកខ្លួនអ្នកចេញពីគណនីនោះរួចរាល់ ។

2.2.4. គណនីអាណត្តិព្យាបាល

តាមរយៈការចុះហត្ថលេខាលើឯកសារផ្តល់សិទ្ធិលើគណនី អ្នកផ្តល់សិទ្ធិដល់បុគ្គលដែលមានឈ្មោះលើឯកសារផ្តល់សិទ្ធិ ធ្វើប្រតិបត្តិការក្នុងសមត្ថភាពស្របច្បាប់របស់ខ្លួន ដើម្បីគ្រប់គ្រង និងប្រតិបត្តិការគណនីស្របតាមសំណើប្រតិបត្តិការដែលមានការចុះហត្ថលេខា ។ ទន្ទឹមនោះដែរ គណនីដែលបានផ្តល់សិទ្ធិត្រូវបានចាត់ទុកថាជាគណនីអាណត្តិព្យាបាល ។

2.2.5. ការពិនិត្យ ឬចូលប្រើប្រាស់ព័ត៌មានគណនី

ទោះបីជាបញ្ជត្តិគណនី បានកំណត់ថា “ហត្ថលេខីណាមួយ” ក៏ដោយ ក៏អ្នក, ដៃគូរបស់អ្នក, ម្ចាស់គណនីទទួលសិទ្ធិអនុញ្ញាត, ម្ចាស់គណនីរួម, ហត្ថលេខី ត្រូវបានអនុញ្ញាត ឲ្យពិនិត្យ ឬចូលប្រើប្រាស់ព័ត៌មានគណនី មិនថា តាមបញ្ជរ ឬបណ្តាញអេឡិកត្រូនិក ពីព្រោះបុគ្គលទាំងនេះជាភាគីនៃគណនី ។ ជាលទ្ធផល ធនាគារនឹងគិតកម្រៃសេវា រួចទូទាត់លើគណនីរបស់អ្នក ប្រសិនបើមានសំណើណាមួយពីបុគ្គលណាម្នាក់ក្នុងចំណោមនោះ ដើម្បីពិនិត្យ ឬចូលប្រើប្រាស់ព័ត៌មានគណនី ជាឧទាហរណ៍ សំណើសុំការបញ្ជាក់សមតុល្យជាដើម ។

2.3. ការផ្លាស់ប្តូរស្ថានភាព

ប្រសិនបើអ្នកមិនទាន់គ្រប់អាយុតាមលក្ខខណ្ឌកំណត់ អ្នកត្រូវមានអាណាព្យាបាលម្នាក់ដើម្បីបើកគណនីរួមគ្នាជាមួយអ្នក។ ទោះបីអ្នកជាភាគីនៃគណនីរួមក្តី ប៉ុន្តែសកម្មភាពហិរញ្ញវត្ថុរបស់អ្នកត្រូវបានកម្រិតដោយសារអ្នកជាអនីតិជននៅឡើយ។ យើងខ្ញុំនឹងបន្តការដាក់កំហិតប្រភេទគណនីអនីតិជននេះរហូតទាល់តែធនាគារទទួលបានការជូនដំណឹងថា អ្នកលែងជាអនីតិជន ឬក្លាយជាអត្ថាធិនភាពក្រោមច្បាប់កម្ពុជា ហើយអាចផ្តល់ឯកសារបញ្ជាក់គ្រប់គ្រាន់ ដែលស្របតាមលក្ខខណ្ឌតម្រូវអំពីការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់យើងខ្ញុំ។

ក្នុងករណីភាគីគណនីរួមទទួលមរណភាព ម្ចាស់គណនីនៅរស់រានមានជីវិត នៅតែទទួលខុសត្រូវរួមគ្នា និងជាច្រើនលើគណនីរួមនោះ។

ធនាគារអាចសម្រេចចិត្តបញ្ឈប់ផ្តល់ផលិតផល និងសេវាមួយចំនួន ដោយសារតែការប្រែប្រួលស្ថានភាពណាមួយ (ឧទាហរណ៍ ស្ថានភាពទីផ្សារ លក្ខខណ្ឌតម្រូវផ្នែកច្បាប់)។ យើងខ្ញុំនឹងជូនដំណឹងដល់អ្នកយ៉ាងតិច 30 ថ្ងៃ មុនពេលធ្វើការប្តូរគណនី និង/ឬផលិតផល និងសេវាទៅគណនី និង/ឬផលិតផល ឬសេវាមួយផ្សេងទៀត។ ប្រសិនបើអ្នកមិនយល់ព្រមនឹងការប្តូរទៅគណនី និង/ឬផលិតផល ឬសេវាមួយផ្សេងទៀតទេ អ្នកត្រូវជូនដំណឹងដល់ធនាគារឲ្យបាន 10 ថ្ងៃមុនពេលយើងខ្ញុំធ្វើការប្តូរ និងជូនដំណឹងមកធនាគារអំពីគោលបំណងរបស់អ្នកក្នុងការបិទគណនី និង/ឬបញ្ឈប់ផលិតផល ឬសេវា និងជូនដំណឹងមកធនាគារអំពីកន្លែងដែលត្រូវទូទាត់ថវិកាដែលនៅសល់របស់អ្នក។ ប្រសិនបើអ្នកមិនបានជូនដំណឹងដល់យើងខ្ញុំទេនោះ យើងខ្ញុំនឹងចាត់ទុកថាអ្នកបានយល់ព្រមជាមួយនឹងការប្តូរគណនីរបស់អ្នក និង/ឬផលិតផល ឬសេវាជាមួយយើងខ្ញុំ។

2.4. លេខអត្តសញ្ញាណកម្មសារពើពន្ធ

ច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីបរទេស (FATCA) តម្រូវឲ្យគ្រឹះស្ថានហិរញ្ញវត្ថុ (FIs) រាយការណ៍អំពីលេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) សហរដ្ឋអាមេរិកសម្រាប់អតិថិជនជាជនជាតិអាមេរិក ដែលបានបង្កើតទំនាក់ទំនងជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុនោះ។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលចាត់ទុកថាជាជនជាតិអាមេរិក ត្រូវមានចំណុចណាមួយនៃលក្ខណៈវិនិច្ឆ័យខាងក្រោម៖

- ជនជាតិអាមេរិក (រាប់ទាំង អ្នកដែលមានសញ្ជាតិពីរ)
- អនិវាសនជនអាមេរិកសម្រាប់គោលបំណងពន្ធ
- អ្នកកាន់កាតបៃតងសហរដ្ឋអាមេរិក
- ដៃគូអាមេរិក
- សាជីវកម្មអាមេរិក
- អចលនទ្រព្យអាមេរិកក្រៅពីអចលនទ្រព្យនៅបរទេស ឬ
- គណនីអាណត្តិព្យាបាល ប្រសិនបើ (i) តុលាការនៅសហរដ្ឋអាមេរិកអាចធ្វើការត្រួតពិនិត្យបឋមលើការគ្រប់គ្រងលើអាណត្តិព្យាបាល និង (ii) ពលរដ្ឋអាមេរិកម្នាក់ ឬច្រើននាក់ មានសិទ្ធិគ្រប់គ្រងលើការសម្រេចចិត្តសំខាន់លើគណនីអាណត្តិព្យាបាលនោះ។

អ្នកយល់ច្បាស់ថា ច្បាប់តម្រូវឲ្យធនាគារផ្តល់របាយការណ៍គ្រប់គ្រាន់ និងពេញលេញដល់ស្ថាប័នរដ្ឋាភិបាលផ្សេងៗ ហើយអ្នកធានាថាជូនដំណឹងដល់ធនាគារក្នុងរយៈពេល 30 ថ្ងៃ នៅពេលមានការផ្លាស់ប្តូរស្ថានភាពរបស់អ្នក ដើម្បីឲ្យលក្ខណៈវិនិច្ឆ័យខាងលើអាចអនុវត្តចំពោះអ្នកបាន។ អ្នកយល់ព្រមយ៉ាងច្បាស់ជាមួយធនាគារដោយផ្តល់នូវព័ត៌មានណាមួយអំពីរូបអ្នកដល់ស្ថាប័នរដ្ឋាភិបាល ប្រសិនបើច្បាប់កម្ពុជាតម្រូវ ឬដើម្បីប្រតិបត្តិតាមកាតព្វកិច្ចរបស់ធនាគារចំពោះច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីបរទេស (FATCA)។

លើសពីនេះទៅទៀត អ្នកបានឯកភាពថា ការណ៍ដែលមិនបានផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) ដែលត្រឹមត្រូវ, ពេញលេញ និងច្បាស់លាស់ ឬការដែលមិនបានបំពេញតាមលក្ខខណ្ឌខាងក្រោម អាចបណ្តាលឲ្យស្ថានភាពរបស់អ្នកត្រូវបានចាត់ថ្នាក់ជា "ម្ចាស់គណនីមិនប្រតិបត្តិតាម"៖

- មិនបានប្រតិបត្តិតាមការស្នើសុំព័ត៌មានចាំបាច់ក្នុងការកំណត់ថាតើគណនីនោះគឺជាគណនីសហរដ្ឋអាមេរិក រួមទាំងលិខិតធានាអះអាងផ្លូវការអំពីស្ថានភាពពន្ធរបស់ខ្លួន។
- មិនបានផ្តល់ឈ្មោះ, អាសយដ្ឋាន, និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់ពលរដ្ឋអាមេរិក ឬម្ចាស់នីតិបុគ្គល ឬអាជីវកម្មដែលជាកម្មសិទ្ធិរបស់ជនជាតិអាមេរិក។
- មិនបានផ្តល់ឯកសារស្តីពីការអនុគ្រោះពីច្បាប់បរទេស ដែលការពារកុំឲ្យគ្រឹះស្ថានហិរញ្ញវត្ថុបរទេសធ្វើការរាយការណ៍ព័ត៌មានដែលតម្រូវក្រោមច្បាប់ FATCA។
- ម្ចាស់គណនីដែលមិនប្រតិបត្តិតាមនឹងត្រូវរាយការណ៍ទៅស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ដែលនេះជាកាតព្វកិច្ចរាយការណ៍មួយរបស់ច្បាប់ FATCA។

2.5. ទំនួលខុសត្រូវរបស់ម្ចាស់គណនីរួម/គណនីទទួលសិទ្ធិ

អ្នកចាំបាច់ត្រូវយល់ដឹងអំពីទំនួលខុសត្រូវរបស់ខ្លួនមុនពេលបើកគណនីរួម។ អ្នកគួរយល់ដឹងនូវចំណុចមួយចំនួនដូចខាងក្រោម៖

- ទំនួលខុសត្រូវរបស់ម្ចាស់គណនីរួមនៅលើគណនី គឺជាទំនួលខុសត្រូវរួម និងរៀងៗខ្លួន ដូច្នេះប្រសិនបើម្ចាស់គណនីម្នាក់ ឬច្រើននាក់ ដកសាច់ប្រាក់ចេញពីគណនី (ប្រសិនបើបានអនុញ្ញាត) ម្ចាស់គណនីរួមនីមួយៗអាចមានទំនួលខុសត្រូវទូទាត់ចំនួនទឹកប្រាក់ដែលបានដកទាំងអស់ ឬក្នុងចំណែកណាមួយ។
- ទំនួលខុសត្រូវរួម និងរៀងៗខ្លួនលើបំណុល អាចនឹងកើតឡើង ប្រសិនបើក្រោយមកទៀត អ្នក និងម្ចាស់គណនីផ្សេងទៀតមិនយល់ស្របលើបំណុលនោះ។ ក្នុងករណីមិនយល់ស្របគ្នានេះ អ្នកគួរតែជូនដំណឹងដល់ធនាគារជាបន្ទាន់ និងស្វែងរកការប្រឹក្សាផ្លូវច្បាប់ឯករាជ្ស។
- ធនាគារអាចបន្តបង់ការប្រាក់របស់ម្ចាស់គណនីរួម/គណនីទទួលសិទ្ធិ ហើយនៅក្នុងករណីមានជម្លោះពាក់ព័ន្ធនឹងគណនីរបស់អ្នក មិនថាលើកម្មសិទ្ធិ មូលនិធិក្តី ឬប្រតិបត្តិការគណនីក្តី ធនាគារអាចបញ្ឈប់ប្រតិបត្តិការគណនីទាំងស្រុង ឬដោយផ្នែកទៅតាមការស្នើសុំរបស់ម្ចាស់គណនី ឬតាមឆន្ទានុសិទ្ធិរបស់ធនាគារ រហូតទាល់តែមានដំណោះស្រាយសម្រាប់ជម្លោះនោះ។
- នៅក្នុងករណីម្ចាស់គណនីរួម/គណនីទទួលសិទ្ធិណាម្នាក់ទទួលមរណភាព នោះធនាគារនឹងទូទាត់ប្រាក់ និងទ្រព្យសម្បត្តិផ្សេងទៀតទាំងអស់ជូនម្ចាស់គណនីរួម/គណនីទទួលសិទ្ធិ (“អ្នកនៅរស់រាន”) ដែលជាឥណទានរបស់គណនីរួម/គណនីទទួលសិទ្ធិនោះ។
- ប្រសិនបើម្ចាស់គណនីរួមជូនដំណឹងដល់ធនាគារដើម្បីដកហត្ថលេខីចេញពីគណនីរួម ធនាគារនឹងបញ្ឈប់ប្រតិបត្តិការគណនីនោះ ប៉ុន្តែទំនួលខុសត្រូវរួម និងដាច់ដោយឡែកសម្រាប់បំណុលនៅសល់មិនទាន់ទូទាត់ នឹងបន្តមានរហូតទាល់តែមានការទូទាត់ចូលគណនីរួមនោះវិញគ្រប់ចំនួន។
- ប្រសិនបើទ្រព្យរួមត្រូវបានដាក់ជាវត្ថុធានាសម្រាប់កម្ចី អ្នកគួរស្វែងរកការប្រឹក្សាផ្លូវច្បាប់ឯករាជ្ស អំពីទំនួលខុសត្រូវរបស់អ្នកចំពោះបំណុលដែលកើតឡើងនាពេលបច្ចុប្បន្ន និងនាពេលអនាគត។ ការរៀបចំអាចធ្វើឡើងចំពោះតែកាគីនៃគណនីរួមប៉ុណ្ណោះ។
- សម្រាប់ការប្រើប្រាស់សេវាធនាគារតាមអនឡាញ អ្នកអាចពិនិត្យមើលគណនីនានាដែលអ្នកមានជាមួយម្ចាស់គណនីរួម ប្រសិនបើប្ញញ្ញត្តិគណនីមិនមែន “ឯកតោភាគី”។ ផ្ទុយមកវិញ អ្នកអាចមានសិទ្ធិចូលប្រើប្រាស់សេវាធនាគារតាមអនឡាញក្នុងកម្រិតដូចគ្នា នៅពេលដែលអ្នកបានជ្រើសរើសប្ញញ្ញត្តិគណនី “ឯកតោភាគី”។
- ធនាគារអាចទទួលយកមូលប្ជទានបត្រនៅក្នុងគណនីរួម ដែលត្រូវបង់ជូនម្ចាស់គណនីម្នាក់ ឬម្ចាស់គណនីច្រើននាក់។
- ប្រសិនបើអ្នកមិនបានបញ្ជាក់ថា ចាំបាច់ត្រូវមានម្ចាស់គណនីទទួលសិទ្ធិពីរនាក់ ឬច្រើននាក់ទើបអាចប្រតិបត្តិការគណនីរួមរបស់អ្នកទេ នោះគណនីរួមរបស់អ្នកអាចនឹងត្រូវបិទដោយម្ចាស់គណនីណាម្នាក់ (ឬបុគ្គលផ្សេងទៀតដែលមានសិទ្ធិ) ដូច្នេះសូមបញ្ជាក់ប្រាប់ធនាគារឲ្យបានច្បាស់។ នៅក្នុងករណីនេះ ធនាគារនឹងមិនទទួលខុសត្រូវចំពោះម្ចាស់គណនីរួមផ្សេងទៀតលើផលវិបាកណាមួយដែលអាចកើតចេញពីការបិទគណនីរួមនោះឡើយ។
- ធនាគារមានសិទ្ធិតម្រូវឲ្យម្ចាស់គណនីទាំងអស់យល់ព្រមមុនពេលចាត់ចំណាត់ការបិទគណនីតាមការស្នើសុំរបស់ម្ចាស់គណនីណាម្នាក់ ទោះបីជាម្ចាស់គណនីរូបនោះមានសិទ្ធិដាក់សំណើមកធនាគារក៏ដោយ។
- នៅពេលដែលអ្នកចង់ផ្លាស់ប្តូរ/កែប្រែប្រតិបត្តិការគណនីរួមរបស់អ្នក ម្ចាស់គណនីរួមរូបនោះត្រូវអញ្ជើញមកកាន់ធនាគារដោយផ្ទាល់ដើម្បីចុះហត្ថលេខាលើបែបបទស្នើសុំ។
- ធនាគារអាចត្រូវការពេលវេលាមួយចំនួនដើម្បីធ្វើការផ្ទៀងផ្ទាត់ និងអនុវត្តតាមការណែនាំស្របតាមនីតិវិធីផ្ទៃក្នុងរបស់ធនាគារ។ ធនាគារមានសិទ្ធិបញ្ឈប់ប្រតិបត្តិការគណនីរួមណាមួយដើម្បីបម្រើផលប្រយោជន៍រួមរបស់ម្ចាស់គណនីរួមទាំងអស់ ឬធនាគារមានសិទ្ធិបញ្ឈប់ប្រតិបត្តិការគណនីនោះ បណ្តោះអាសន្ននៅពេលអនុវត្តតាមសំណើរបស់ម្ចាស់គណនីណាម្នាក់។ ធនាគារមិនត្រូវទទួលខុសត្រូវលើការខូចខាត និងផលវិបាកផ្លូវច្បាប់ដែលអាចកើតចេញពីការការពារម្ចាស់គណនីរួមផ្សេងទៀតក្នុងចំណោមម្ចាស់គណនីទាំងអស់នោះទេ។

2.6. ទំនួលខុសត្រូវរបស់អ្នក

អ្នកត្រូវទទួលខុសត្រូវចំពោះធនាគារសម្រាប់បំណុលទាំងអស់ដែលពាក់ព័ន្ធនឹងគណនីរបស់អ្នក ហើយត្រូវរ៉ាប់រងចំពោះធនាគារលើរាល់បំណុលណាមួយដែលអាចកើតចេញពីគណនីរបស់អ្នក ក្នុងករណីដែលអ្នកបំពានតួនាទី ឬកាតព្វកិច្ចណាមួយនៅក្នុងច្បាប់របស់កម្ពុជា។

3. ការប្រើប្រាស់គណនីរបស់អ្នក

មានមធ្យោបាយជាច្រើនដែលអ្នកអាចចូលប្រើប្រាស់គណនី និងធ្វើការដាក់ និងដកប្រាក់។ ប៉ុន្តែជម្រើសទាំងអស់ដែលបានរៀបរាប់នៅក្នុងផ្នែកនេះមិនសុទ្ធតែមានសម្រាប់គណនីរបស់អ្នកឡើយ។ គណនីរបស់អ្នកក៏អនុញ្ញាតឲ្យមានការដាក់ប្រាក់ចូលដោយផ្ទាល់ផងដែរ ដែលមានន័យថា អ្នកអាចរៀបចំកំណត់ឲ្យមានការផ្ទេរប្រាក់ចូលគណនីរបស់អ្នកដោយស្វ័យប្រវត្តិ។

3.1. សេវាធនាគារអនឡាញ

សេវាទាំងនេះរួមមាន ៖

- កម្មវិធីសេវាធនាគារ ABA Mobile (“ABA Mobile”)
- ម៉ាស៊ីន ATM
- ម៉ាស៊ីនដក-ដាក់ប្រាក់
- ម៉ាស៊ីនដាក់ប្រាក់
- ម៉ាស៊ីនដាក់មូលប្បទានបត្រ

ជាមួយនឹងសេវាទាំងនោះ និងអាស្រ័យលើមុខងារនៃគណនីរបស់អ្នក អ្នកអាច ៖

- មើលគណនីរបស់អ្នកទាំងអស់នៅលើអេក្រង់តែមួយ
- ផ្ទេរប្រាក់ទៅមករវាងគណនីផ្សេងទៀតរបស់អ្នក
- ផ្ទេរប្រាក់ទៅកាន់គណនី ABA អ្នកផ្សេងទៀត
- ផ្ទេរប្រាក់រវាងគណនី និង កាបូបឌីជីថល (wallet) នៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតដែលមានកិច្ចព្រមព្រៀងទ្វេភាគីជាមួយធនាគារ ABA
- បង់រំកៃយបត្រ
- បើកគណនីបន្ថែមទៀត ដែលមាននៅក្នុងកម្មវិធី ABA Mobile តែប៉ុណ្ណោះ
- ផ្ទេរប្រាក់ទៅកាន់ម៉ាស៊ីន ATM (ដូចជា សេវា E-Cash)
- បើកកាតនិម្មិត
- បង្កកកាត
- ដាក់កម្រិតកំណត់លើកាត
- បើកដំណើរការកាត
- ដាក់កាលវិភាគទូទាត់ថ្ងៃខាងមុខ/បញ្ជាទូទាត់ប្រចាំ
- ទូទាត់ដោយប្រើមុខងារកូដ QR ដែលមានឈ្មោះថា ABA PAY
- ដាក់ប្រាក់បញ្ញើ
- ដកប្រាក់
- មើលអត្រាប្តូរប្រាក់នៅធនាគារ
- ស្វែងរកកន្លែងទូទាត់តាម ABA PAY (ពាណិជ្ជករផ្តល់ការបញ្ចុះតម្លៃ)
- ស្វែងរកកន្លែងមានម៉ាស៊ីន ATM, សាខា, និងបណ្តាញម៉ាស៊ីនដាក់ប្រាក់របស់ធនាគារ ABA នៅលើផែនទី
- ធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នក (ដូចជា រូបថតរបស់អ្នក)
- ផ្លាស់ប្តូរលេខសម្ងាត់ (PIN)
- ផ្តល់មតិរបស់អ្នកដល់ធនាគារ

3.1.1. កម្មវិធី ABA Mobile

ជាមួយសេវានេះ អ្នកអាចប្រើប្រាស់ប្រាក់របស់អ្នកយ៉ាងងាយស្រួលបានគ្រប់ពេលវេលា សម្រាប់មុខងារស្តង់ដារភាគច្រើននៅក្នុងផ្នែក 3.1 ។ អ្នកអាចប្រើប្រាស់សេវានេះដោយខ្លួនឯងតាមគណនីរបស់អ្នក ឬលេខកាតដែលធនាគារបានផ្តល់ជូន ។ ប្រសិនបើអ្នកមានតែគណនីរួមដែលបានភ្ជាប់ទៅនឹងប្រូហ្វាលរបស់អ្នក អ្នកមិនអាចប្រើប្រាស់គណនីរួមរបស់អ្នកដើម្បីបើកដំណើរការកម្មវិធី ABA Mobile នេះដោយខ្លួនឯងបានទេ ទោះស្ថិតក្នុងឃ្លាញ្ញត្តិគណនីណាមួយក៏ដោយ ។ ប៉ុន្តែ ប្រសិនបើអ្នក

បើកដំណើរការកម្មវិធី ABA Mobile របស់អ្នកដោយប្រើគណនីទោល នោះគណនីរួមដែលភ្ជាប់ទៅនឹងប្រូហ្វាលរបស់អ្នក នឹងបង្ហាញនៅក្នុងកម្មវិធី ABA Mobile របស់អ្នក។ ការចូលប្រើប្រាស់គណនីរួម នោះគឺផ្អែកលើឃ្លាញត្តិគណនីរួម (ដូចជា ប្រសិនបើឃ្លាញត្តិគណនី គឺជា"ឯកតោភាគី" អ្នកអាចពិនិត្យមើល និងអាចដកប្រាក់ពីគណនីរួមនោះ បញ្ញត្តិគណនីដែលកំណត់ដោយស្វ័យប្រវត្តិ បានត្រឹម "ពិនិត្យមើលប៉ុណ្ណោះ")។

អ្នកចាំបាច់ត្រូវប្រើប្រាស់លេខទូរស័ព្ទណាមួយដែលអ្នកបានប្រើពេលចុះបញ្ជីជាមួយធនាគារនៅពេលបើកគណនី។ ប្រសិនបើធនាគារដឹងថា លេខទូរស័ព្ទរបស់អ្នកត្រូវបានបិទមិនឲ្យដំណើរការ ឬត្រូវបានប្រតិបត្តិការទូរគមនាគមន៍ផ្ទេរ ឬលក់ទៅឲ្យអ្នកប្រើប្រាស់ផ្សេងទៀត ហើយអ្នកមិនបានជូនដំណឹងដល់ធនាគារទេ នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពកំណត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យរបស់ខ្លួនដោយស្វ័យប្រវត្តិ ដោយសារច្បាប់ជាធរមានកំណត់ឲ្យធនាគាររក្សាបច្ចុប្បន្នភាពទិន្នន័យអតិថិជន។ ដោយជាផ្នែកមួយនៃដំណើរការបើកគណនី ធនាគារអាចផ្ទៀងផ្ទាត់ឃើញថា អ្នកមិនមែនជាម្ចាស់កម្មសិទ្ធិនៃលេខទូរស័ព្ទដែលអ្នកបានផ្តល់ឲ្យធនាគារកាលពីជំបូងពេលបើកគណនី ព្រោះលេខទូរស័ព្ទនោះ ត្រូវបានកាន់កាប់ជាកម្មសិទ្ធិ ដោយអតិថិជនថ្មី។ ក្នុងករណីបែបនេះ អ្នកយល់ព្រម៉ាប់រងចំពោះ ធនាគារ សម្រាប់រាល់ការខាតបង់គ្រប់ប្រភេទ ប្រសិនបើធនាគារលុបលេខទូរស័ព្ទនោះចេញពីប្រូហ្វាលរបស់អ្នកដែលចុះបញ្ជីនៅធនាគារ ដែលបង្កឡើងដោយសារតែអ្នកមិនបានជូនដំណឹងដល់ធនាគារទាន់ពេលវេលាអំពីលេខទូរស័ព្ទបច្ចុប្បន្នរបស់អ្នក។

ធនាគារប្រើប្រាស់មធ្យោបាយផ្សេងៗគ្នាដើម្បីធានាសុវត្ថិភាពពាក្យសម្ងាត់សម្រាប់ប្រើមួយលើក (OTP) របស់អ្នកដែលធនាគារបានផ្តល់ជូនអ្នកដើម្បីបើកដំណើរការកម្មវិធី ABA Mobile របស់អ្នក។ អ្នកមានកាតព្វកិច្ចរក្សា OTP ជាការសម្ងាត់ និងមិនត្រូវបង្ហាញ OTP និង/ឬ ព័ត៌មានបញ្ជាក់ការចូលប្រើកម្មវិធី ABA Mobile ដល់បុគ្គលណាម្នាក់ឡើយ រាប់ទាំងបុគ្គលិកធនាគារ ABA ផងដែរ។

3.1.2. សេវាធនាគារអនឡាញ

ជាមួយសេវានេះ អ្នកអាចចូលប្រើប្រាស់ថវិការបស់អ្នកបានយ៉ាងងាយស្រួល និងគ្រប់ពេលវេលា សម្រាប់មុខងារស្តង់ដារភាគច្រើនដូចមានបញ្ជាក់ត្រង់ចំណុច 3.1។ អ្នកត្រូវផ្តល់ព័ត៌មានពិត ត្រឹមត្រូវ និងពេញលេញ លើអាសយដ្ឋានអ៊ីមែល និងលេខទូរស័ព្ទរបស់អ្នក ដើម្បីទទួល OTP រាល់ពេលដែលអ្នកបើកចូល។ អ្នកត្រូវប្រើលេខទូរស័ព្ទណាមួយ ដែលចុះបញ្ជីជាមួយធនាគារ អំឡុងពេលបើកគណនី។ ប្រសិនបើធនាគារដឹងថា លេខទូរស័ព្ទរបស់អ្នកត្រូវបានបិទមិនឲ្យដំណើរការ ឬត្រូវបានប្រតិបត្តិការទូរគមនាគមន៍ផ្ទេរ ឬលក់ទៅឲ្យអ្នកប្រើប្រាស់ផ្សេងទៀត ហើយអ្នកមិនបានជូនដំណឹងដល់ធនាគារទេ នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពកំណត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យរបស់ខ្លួនដោយស្វ័យប្រវត្តិ ដោយសារច្បាប់ជាធរមានកំណត់ឲ្យធនាគារក្សាបច្ចុប្បន្នភាពទិន្នន័យអតិថិជន។ ដោយជាផ្នែកមួយនៃកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ធនាគារ ដូច្នេះធនាគារអាចនឹងផ្ទៀងផ្ទាត់ឃើញថា អ្នកមិនមែនជាម្ចាស់កម្មសិទ្ធិនៃលេខទូរស័ព្ទដែលអ្នកបានផ្តល់ឲ្យធនាគារកាលពីជំបូងពេលបើកគណនី ព្រោះលេខទូរស័ព្ទនោះ ត្រូវបានកាន់កាប់ជាកម្មសិទ្ធិ ដោយអតិថិជនថ្មី។ ក្នុងករណីបែបនេះ អ្នកយល់ព្រម៉ាប់រងចំពោះ ធនាគារ សម្រាប់រាល់ការខាតបង់គ្រប់ប្រភេទ ប្រសិនបើធនាគារលុបលេខទូរស័ព្ទនោះចេញពីប្រូហ្វាលរបស់អ្នកដែលចុះបញ្ជីនៅធនាគារ ដែលបង្កឡើងដោយសារតែអ្នកមិនបានជូនដំណឹងដល់ធនាគារទាន់ពេលវេលាអំពីលេខទូរស័ព្ទបច្ចុប្បន្នរបស់អ្នក។

3.2. ចាប់ផ្តើមប្រតិបត្តិការ

3.2.1. អ្នកចូលរួមប្រតិបត្តិការ

ធនាគារកំណត់នីតិវិធី និងកម្រិតប្រតិបត្តិការ ស្របតាមច្បាប់ជាធរមាន ដើម្បីកំណត់ និងផ្ទៀងផ្ទាត់ព័ត៌មានលម្អិតប្រតិបត្តិការ និងអ្នកចូលរួមប្រតិបត្តិការ។ អ្នកចូលរួមប្រតិបត្តិការ អាចជាម្ចាស់គណនី បុគ្គលទទួលសិទ្ធិ ឬម្ចាស់គណនីមិនមែន ABA។ អ្នកចូលរួម ក្រៅពីម្ចាស់គណនី ABA ត្រូវតែផ្តល់ជូនព័ត៌មានដែលធនាគារត្រូវការ ដើម្បីកំណត់អត្តសញ្ញាណអ្នកចូលរួម និងលក្ខណៈសំណើដែលនឹងត្រូវដំណើរការតាមរយៈប្រព័ន្ធធនាគារស្វ័យ។ ក្នុងករណីមិនបានបង្ហាញព័ត៌មានចាំបាច់សម្រាប់ការយកចិត្តទុកដាក់ស្គាល់អតិថិជន អាចនឹងនាំឲ្យធនាគារបដិសេធមិនដំណើរប្រតិបត្តិការ ព្រមទាំងត្រូវពិនិត្យអំពីទំនាក់ទំនងជាមួយអ្នកស្របតាម ខ និងលក្ខខណ្ឌរបស់ធនាគារ និងអនុលោមតាមច្បាប់ជាធរមាន។

3.2.2. ម៉ាស៊ីន ATM (ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ)

ចំនួនទឹកប្រាក់អតិបរមាដែលអ្នកអាចដកពីម៉ាស៊ីន ATM គឺអាស្រ័យលើប្រភេទកាតដែលអ្នកបានជ្រើសរើស ហើយចំនួនទឹកប្រាក់អតិបរមាអាចមានរហូតដល់ 1,000 ដុល្លារអាមេរិកក្នុងមួយថ្ងៃ (អំឡុង 24 ម៉ោង)។ ធនាគារសូមរក្សាសិទ្ធិកែប្រែ/ផ្លាស់ប្តូរកម្រិតទឹកប្រាក់ប្រចាំថ្ងៃសម្រាប់ប្រតិបត្តិការតាមម៉ាស៊ីន ATM និងម៉ាស៊ីនទូទាត់ POS ដោយពុំចាំបាច់ជូនដំណឹងជាមុនឡើយ តាមកម្រិតដែលច្បាប់កម្ពុជាអនុញ្ញាត។ អ្នកនឹងទទួលបានការជូនដំណឹងអំពីការកែប្រែតាមរយៈមធ្យោបាយជូនដំណឹងផ្សេងៗ។

ប្រសិនបើអ្នកធ្វើប្រតិបត្តិការតាមរយៈម៉ាស៊ីន ATM នៅមុនពេលចប់ម៉ោងធ្វើការ (EOD) របស់ធនាគារ ប្រតិបត្តិការនោះ អាចនឹងត្រូវដំណើរការនៅថ្ងៃនោះ ឬនៅថ្ងៃធ្វើការបន្ទាប់ មិនថាសាខាធនាគារបើកដំណើរការឬអត់ឡើយ។ ជាធម្មតា ធនាគារដំណើរការប្រតិបត្តិការដែលទទួលបានរហូតដល់ពេលចប់ម៉ោងធ្វើការ(EOD) រាល់ល្ងាច។

អ្នកអាចនឹងត្រូវគិតថ្លៃសេវាសម្រាប់ការប្រើប្រាស់កាតរបស់អ្នកជាមួយនឹងម៉ាស៊ីនទូទាត់ POS ឬម៉ាស៊ីន ATM ដែលមិនមែនជារបស់ធនាគារ ABA។ ថ្លៃសេវានេះ មានរៀបរាប់លម្អិតនៅក្នុងកូនសៀវភៅណែនាំអំពី "ថ្លៃសេវា" ខ និងលក្ខខណ្ឌដាក់លាក់របស់ផលិតផល/សេវា និង/ឬវិបសាយរបស់ធនាគារ។

អ្នកចាំបាច់ត្រូវមានកាតមួយដែលអាចភ្ជាប់ទៅនឹងគណនីរបស់អ្នកដើម្បីប្រើប្រាស់មុខងារនានារបស់ម៉ាស៊ីន ATM។ អ្នកក៏អាចប្រើប្រាស់សេវា E-Cash ដើម្បីដកប្រាក់ពីគណនីរបស់អ្នកបានដែរ។ អ្នកអាចដាក់ប្រាក់ចូលទៅក្នុងគណនីរបស់អ្នកដោយប្រើប្រាស់លេខគណនី ឬលេខកាត 16 ខ្ទង់របស់អ្នក។ ធនាគារ ផ្តល់ជូននូវមុខងារម៉ាស៊ីន ATM ពីរប្រភេទ (i) ម៉ាស៊ីនដកតែប្រាក់ និង (ii) ម៉ាស៊ីនដាក់-ដកប្រាក់ ដែលអ្នកអាចដក និង/ឬដាក់ប្រាក់បាន។

អ្វីដែលអ្នកអាចធ្វើបាន ៖

អ្វីដែលអ្នកអាចធ្វើបាននៅតាមម៉ាស៊ីន ABA ATM	អ្វីដែលអ្នកអាចធ្វើបាននៅតាមម៉ាស៊ីន ATM ដែលមានសញ្ញាប្រាក់រៀល	ម៉ាស៊ីន ATM មិនមែនរបស់ធនាគារ ABA
▪ ដកប្រាក់ដោយមិនអស់ថ្លៃសេវា ▪ ដកប្រាក់ដោយមិនចាំបាច់ប្រើកាត ពោលគឺប្រើប្រាស់សេវា E-Cash ▪ ដាក់ប្រាក់ (តាមទីតាំង ATM ដាក់លាក់ណាមួយ) ▪ ពិនិត្យមើលសមតុល្យគណនី និងរបាយការណ៍សមតុល្យសង្ខេប ▪ ប្តូរលេខសម្ងាត់ (PIN) (ប្រសិនបើអ្នកដឹងអំពីលេខសម្ងាត់ (PIN) ចាស់របស់អ្នក) ▪ បើកកាតឥណពន្ធ និងឥណទាន ▪ ស្នើសុំរបាយការណ៍សង្ខេប	▪ ដកប្រាក់ដោយប្រើប្រាស់កាត ABA ដោយគិតថ្លៃសេវាទាប ▪ ដករបាយការណ៍សមតុល្យដោយគិតថ្លៃសេវាទាប ▪ ស្នើសុំរបាយការណ៍សង្ខេប	▪ ចូលប្រើប្រាស់គណនីរបស់អ្នកក៏មាននៅតាមម៉ាស៊ីន ATM មិនមែនរបស់ធនាគារ ABA (រួមមានម៉ាស៊ីន ATM នៅក្រៅប្រទេសតាមរយៈកាត និងបណ្តាញម៉ាស៊ីន ATM Mastercard/Cirrus®, Visa, UPI) ដែលអនុញ្ញាតឲ្យអ្នកអាចមើលសមតុល្យគណនី ឬដកប្រាក់ ▪ សូមជម្រាបថា កម្រិតប្រតិបត្តិការដកប្រាក់ប្រចាំថ្ងៃ អាចនឹងត្រូវអនុវត្តនៅតាមម៉ាស៊ីន ATM មិនមែនធនាគារ ABA។ វិធានការពិតត្បិតផ្សេងៗ អាចនឹងត្រូវអនុវត្តផងដែរ។ ▪ ម៉ាស៊ីន ATM មិនមែនរបស់ធនាគារ ABA អាចត្រូវបានម្ចាស់ម៉ាស៊ីន ATM គិតថ្លៃសេវាម៉ាស៊ីន ATM

3.2.3. វិធានអំពីការដាក់ប្រាក់តាមម៉ាស៊ីន ATM និងម៉ាស៊ីនដាក់ប្រាក់របស់ធនាគារ ABA (“CIM”)

ប្រសិនបើអ្នកដាក់ប្រាក់តាមរយៈម៉ាស៊ីន ATM របស់ ABA នោះចំនួនទឹកប្រាក់ដែលបានដាក់នឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីរបស់អ្នក ប៉ុន្តែការធ្វើប្រតិបត្តិការនេះ ក៏ត្រូវឆ្លងកាត់ការផ្ទៀងផ្ទាត់ពីធនាគារផងដែរ។ ចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់សុពលភាពដោយម៉ាស៊ីន ATM/ធនាគារ នឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីរបស់អ្នក។ នៅពេលធ្វើការដាក់ប្រាក់តាមរយៈម៉ាស៊ីន ATM របស់ ABA នៅតាមសាខា ៖

- ការដាក់ប្រាក់ ត្រូវបញ្ចូលទៅក្នុងគណនីរបស់អ្នកនៅថ្ងៃដដែលនោះ
- ការដាក់ប្រាក់តាមម៉ាស៊ីន ATM ត្រូវមានសុពលភាពនៅថ្ងៃធ្វើការបន្ទាប់របស់សាខាធនាគារ។ ប្រសិនបើមានភាពខុសគ្នារវាងចំនួនដែលបានដាក់ និងចំនួនទឹកប្រាក់ដែលបានព្រីននៅលើវិក្កយបត្រ ឬចំនួនដែលបានបញ្ចូលទៅក្នុងម៉ាស៊ីន ATM យើងខ្ញុំនឹងជូនដំណឹងឲ្យបានឆាប់តាមដែលអាចធ្វើបាន អំពីចំនួនដាក់ស្តែងដែលបានបញ្ចូលទៅក្នុងគណនី។
- ធនាគារអាចនឹងកំណត់កម្រិតទឹកប្រាក់អតិបរមាក្នុងមួយលើក និងប្រចាំថ្ងៃសម្រាប់ការដាក់ប្រាក់តាមម៉ាស៊ីន ATM និងម៉ាស៊ីនដកដាក់ប្រាក់។ សូមពិគ្រោះយោបល់ជាមួយទីប្រឹក្សា និងភ្នាក់ងារយើងខ្ញុំសម្រាប់ការគាំទ្ម។

សូមជម្រាបថា ការដាក់ប្រាក់ អាចចំណាយពេលយូរក្នុងការធ្វើប្រតិបត្តិការ ប្រសិនបើម៉ាស៊ីន ATM របស់ ABA មិនស្ថិតនៅក្នុងសាខា។ ប្រសិនបើអ្នកធ្វើការដាក់ប្រាក់តាមម៉ាស៊ីនដាក់ប្រាក់របស់ធនាគារ ABA ចំនួនទឹកប្រាក់ដែលបានដាក់នេះ ត្រូវឆ្លងកាត់ការផ្ទៀងផ្ទាត់ដោយធនាគារ។ ចំនួនទឹកប្រាក់ដែលបានពិនិត្យសុពលភាពដោយម៉ាស៊ីនដាក់ប្រាក់/ធនាគារ គឺជាចំនួនទឹកប្រាក់ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីរបស់អ្នក។ នៅពេលធ្វើការដាក់ប្រាក់តាមម៉ាស៊ីនដាក់ប្រាក់ ប្រាក់នោះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងគណនីរបស់អ្នកនៅថ្ងៃដែលប្រតិបត្តិការដាក់ប្រាក់បានធ្វើឡើង បន្ទាប់ពីឆ្លងកាត់ការផ្ទៀងផ្ទាត់។

3.2.4. ការដាក់ប្រាក់ចូលគណនីធនាគាររបស់អ្នកតាមសេវាដាក់ប្រាក់ (“CiS”)

ធនាគារ ABA ផ្តល់ជូនសេវាដាក់ប្រាក់តាមរយៈវិធីសាស្ត្រផ្សេងៗគ្នា (ការដាក់ប្រាក់ចូលក្នុងគណនីធនាគារ) ដូចជាការដាក់ប្រាក់តាមរយៈសាខាធនាគារ និងការដាក់ប្រាក់តាមម៉ាស៊ីនដាក់ប្រាក់។ ក្រៅពីវិធីសាស្ត្រទាំងនេះ ធនាគារ ក៏បានពង្រីកវិសាលភាពសេវាដាក់ប្រាក់របស់ខ្លួនតាមរយៈការបង្កើតភាពជាដៃគូជាមួយនឹងក្រុមហ៊ុនផ្តល់សេវាទូទាត់ប្រាក់ឈានមុខជាច្រើនផ្សេងទៀតផងដែរ។ ការដាក់ប្រាក់ក្នុងគណនីតាមរយៈសេវានេះ គឺត្រូវបង់ថ្លៃសេវា និងបន្ទុកមួយចំនួន និងត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយធនាគារស្របតាមច្បាប់ជាធរមានផងដែរ។ ធនាគារអាចនឹងបដិសេធមិនដំណើរការប្រតិបត្តិការណាមួយ ប្រសិនបើធនាគារមានមូលហេតុសមស្របដែលអាចជឿជាក់ថា ប្រតិបត្តិការនេះត្រូវបានធ្វើឡើងមិនត្រូវគ្នាជាមួយនឹងប្រូហ្វាលរបស់ម្ចាស់គណនី ឬតាមច្បាប់ជាធរមានតម្រូវ។

3.2.5. សាខា

តើអ្នកអាចធ្វើអ្វីបានខ្លះនៅតាមសាខាធនាគារ?

យើងខ្ញុំមានបុគ្គលិកសាខាសម្រាប់ពិភាក្សាជាមួយនឹងអ្នកដោយផ្ទាល់អំពីផលិតផល និងសេវាកម្មនានា និងបង្ហាញអ្នកពីរបៀបប្រើប្រាស់សេវាកម្មនានាដែលអ្នកមិនបានដឹង ដូចជាសេវាធនាគារអនឡាញជាដើម។ បុគ្គលិកសាខារបស់យើងខ្ញុំអាច៖

- ជួយអ្នកក្នុងការដាក់ប្រាក់ ដកប្រាក់, និងធ្វើការផ្ទេរប្រាក់ទៅគណនី ABA
- ជួយអ្នកក្នុងការផ្ទេរប្រាក់ក្នុងប្រទេស ឬក្រៅប្រទេស
- ជួយអ្នកក្នុងការទិញមូលប្បទានបត្រ រួមទាំងមូលប្បទានបត្ររបស់ធនាគារកិតផងដែរ
- ណាត់ជួបជាមួយអ្នកជំនាញ ដូចជា មន្ត្រីឥណទានខ្នាតតូច, មន្ត្រីឥណទានសហគ្រាសធុនតូច និងមធ្យមឬ ប្រធានផ្នែកទំនាក់ទំនង
- ឆ្លើយសំណួរទូទៅមួយចំនួនដែលអ្នកចង់ដឹងពាក់ព័ន្ធនឹងគណនីរបស់អ្នក
- ដោះស្រាយបញ្ហាការមិនពេញចិត្ត និងណែនាំអ្នកទៅកាន់បុគ្គលិកសមស្របនៅធនាគារ

ធនាគារអាចកំណត់ចំនួនទឹកប្រាក់ខុសៗគ្នាសម្រាប់បញ្ហាពាក់ព័ន្ធនឹងប្រតិបត្តិការសម្រាប់ចំនួនទឹកប្រាក់កំណត់ក្នុងមួយលើក និងប្រចាំថ្ងៃនៅតាមសាខាផ្សេងៗគ្នា។ អ្នកគួរពិគ្រោះយោបល់ជាមួយបុគ្គលិក ទាក់ទងមកភ្នាក់ងាររបស់យើងខ្ញុំ និង/ឬចូលទៅកាន់វិបសាយរបស់ធនាគារដើម្បីដឹងព័ត៌មានបន្ថែម។

ធនាគារក៏ផ្តល់វេនធ្វើការចំនួន 3 ប្រភេទ

(i) ថ្ងៃចន្ទ - ថ្ងៃសុក្រ ចាប់ពីម៉ោង 8:00 ព្រឹក - 4:00 រសៀល

(ii) ថ្ងៃចន្ទ - សុក្រ ម៉ោង 8:00 ព្រឹក - 4:00 រសៀល និង សៅរ៍ ម៉ោង 8:00 ព្រឹក - 11:00 ថ្ងៃត្រង់ និង

(iii) ថ្ងៃចន្ទ - ថ្ងៃអាទិត្យ ចាប់ពីម៉ោង 8:00 ព្រឹក - 8:00 យប់។

ម៉ោងធ្វើការទាំងនេះ ធ្វើឡើងដើម្បីឆ្លើយតបនឹងតម្រូវការសេវាធនាគារ ហើយនេះជាឆន្ទានុសិទ្ធិរបស់ធនាគារក្នុងការពិនិត្យ និងផ្លាស់ប្តូរដោយមិនជម្រាបជូនជំណឹងជាមុន។

មិនមែនគ្រប់សេវាទាំងអស់ (ដូចជា ការផ្តល់ប្រាក់កម្ចី) ត្រូវបានធ្វើឡើងសម្រាប់ប្រតិបត្តិការនៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យឡើយ។ ធនាគារអាចនឹងបិទប្រតិបត្តិការរបស់ខ្លួននៅគ្រប់សាខាទាំងអស់ ដោយមិនគិតអំពីម៉ោងប្រតិបត្តិការឡើយ ស្របទៅតាមច្បាប់ជាធរមាន និង/ឬកាលៈទេសៈចាំបាច់។ ទោះបីជាយ៉ាងណា ធនាគារនឹងធ្វើការជូនជំណឹងទៅតាមករណីចាំបាច់នីមួយៗ។

3.2.6. សេវាធនាគារអនឡាញ ABA

អ្នកគប្បីពិនិត្យ ខ និងលក្ខខណ្ឌទូទៅសម្រាប់សេវាធនាគារអនឡាញ ABA រួមជាមួយ ខ និងលក្ខខណ្ឌទូទៅនេះ។ នៅពេលអ្នកប្រើសេវាធនាគារអនឡាញ អ្នកត្រូវពិនិត្យ និងយល់ព្រមតាម ខ និងលក្ខខណ្ឌជាក់លាក់សម្រាប់ផលិតផល ឬសេវាកម្មជាក់លាក់។

ដោយផ្អែកលើមុខងារគណនីដែលអ្នកមាន អ្នកអាចប្រើប្រាស់សេវាធនាគារអនឡាញដោយខ្លួនឯងបាន។ អ្នកគប្បីពិនិត្យផ្នែក 3.1 សម្រាប់មុខងារលម្អិត និងរបៀបចាប់ផ្តើមប្រើប្រាស់សេវាទាំងនេះ។

3.2.7. ប្រតិបត្តិការតាមម៉ាស៊ីនទូទាត់ POS

ចំនួនទឹកប្រាក់អតិបរមាដែលអ្នកអាចប្រើប្រាស់បានតាមម៉ាស៊ីនទូទាត់ POS សម្រាប់ប្រតិបត្តិការទិញ គឺអាស្រ័យលើប្រភេទកាតដែលអ្នកបានជ្រើសរើស ពោលគឺអាចចាប់ពីចំនួន 1,000 ដុល្លារអាមេរិកក្នុងមួយថ្ងៃ (រយៈពេល 24 ម៉ោង)។ ធនាគារ ABA សូមរក្សាសិទ្ធិកែប្រែ/កែតម្រូវការកំណត់ប្រចាំថ្ងៃសម្រាប់ប្រតិបត្តិការតាមម៉ាស៊ីនទូទាត់ POS។ អ្នកនឹងទទួលបានការជូនជំណឹងអំពីការកែប្រែ តាមរយៈមធ្យោបាយទំនាក់ទំនងផ្សេងៗ។

ចំនួនទឹកប្រាក់ដែលអ្នកអាចដកបានតាមរយៈម៉ាស៊ីនទូទាត់ POS អាចនឹងត្រូវកំណត់ទៅតាមឆន្ទានុសិទ្ធិរបស់ម្ចាស់ពាណិជ្ជករ (ប្រសិនបើធនាគារអនុញ្ញាត) ដែលប្រើប្រាស់ម៉ាស៊ីនទូទាត់ POS នោះ។

ការបង្ហាញរូបសញ្ញាថា ទទួលទូទាត់តាមម៉ាស៊ីនទូទាត់ POS នៅក្នុងប្រទេសកម្ពុជា ឬឡូហ្គោកាត Visa កាត MasterCard កាត UPI នៅក្នុងបរិវេណ ឬទីតាំងណាមួយ គឺមិនអាចចាត់ទុកជាការធានារបស់ធនាគារ ឬពាណិជ្ជករដែលធ្វើអាជីវកម្មនៅក្នុងបរិវេណនោះថា អ្នកអាចទិញទំនិញ និងសេវាកម្មដែលមាននៅក្នុងបរិវេណនោះដោយប្រើប្រាស់កាតរបស់អ្នកឡើយ។

តើអ្នកអាចធ្វើអ្វីបានខ្លះនៅម៉ាស៊ីនទូទាត់ POS ប្រសិនបើគណនីរបស់អ្នកមានកាត

- ធ្វើការទិញដោយមិនប្រើសាច់ប្រាក់នៅតាមកន្លែងលក់រាយ ឬសេវាកម្មកាតច្រើន
- ក្នុងពេលជាមួយគ្នានោះ អាចដកប្រាក់ (ប្រសិនបើអនុញ្ញាត) ពីគណនីសន្សំរបស់អ្នក ឬគណនីប្រភេទណាមួយដែលកាតភ្ជាប់ជាមួយ (លើកលែងតែប្រាក់បញ្ញើមានកាលកំណត់) ពីកន្លែងលក់រាយ ឬសេវាកម្ម

- ព្រីនវិក្កយបត្រ
- ប្រើប្រាស់ឧបករណ៍ដែលអាចដំណើរការដើម្បីធ្វើការទូទាត់ជាមួយកម្មវិធី ABA Mobile

ម៉ាស៊ីនទូទាត់ POS សំដៅលើប្រតិបត្តិការបង្កើតឡើងនៅលើទាំងឧបករណ៍ទូទាត់ POS និងទម្រង់ផ្សេងៗនៃប្រតិបត្តិការតាមម៉ាស៊ីនទូទាត់ POS ដូចជាតាមទម្រង់កូដ QR ។

3.2.8. សេវាផ្ទេរប្រាក់ក្នុងស្រុក

ធនាគារផ្តល់ជូនទម្រង់ខុសៗគ្នានៃសេវាផ្ទេរប្រាក់ក្នុងប្រទេស ដូចជាការផ្ទេរឆ្លងគ្រឹះស្ថាន, សេវាទូទាត់រហ័ស, បាគង, រវាងគណនី និងកាបូបឌីជីថល(wallet) (តាមរយៈកិច្ច

ព្រមព្រៀងទ្វេភាគី) និងសេវាផ្សេងៗ ដែលអាចត្រូវបានប្រើប្រាស់សម្រាប់ការផ្ទេរទាំងក្នុងប្រទេស និងក្រៅប្រទេស ។ សេវាផ្ទេរប្រាក់ក្នុងប្រទេស គឺត្រូវបង់ថ្លៃសេវា និងបន្ទុក ហើយនឹងត្រូវពិនិត្យដោយធនាគារស្របតាមច្បាប់ជាធរមានតម្រូវ ។

ធនាគារអាចបដិសេធមិនធ្វើប្រតិបត្តិការនៅក្នុងដំណាក់កាលណាមួយ ដោយមិនជម្រាបជូនដំណឹងជាមុនដល់អ្នកទទួលការទូទាត់ប្រាក់ ស្របតាមច្បាប់ជាធរមាន និង/ឬ នៅពេលធនាគារមានមូលហេតុច្បាស់លាស់ដែលអាចបញ្ជាក់ប្រតិបត្តិការនេះ ត្រូវបានធ្វើឡើងដោយមិនមានសង្គតិភាពជាមួយនឹងប្រូហ្វាលរបស់ម្ចាស់គណនី ។ ប្រសិនបើធនាគារសម្រេចបដិសេធការផ្ទេរប្រាក់ក្នុងស្រុកនៅក្នុងដំណាក់កាលណាមួយ នោះធនាគារនឹងជូនដំណឹងដល់អ្នកផ្ញើអំពីមូលហេតុនៃការបដិសេធនោះ លើកលែងតែមានលក្ខខណ្ឌផ្សេងៗដែលតម្រូវឲ្យធនាគារអនុលោមតាមវិធានការដាក់លាក់ណាមួយ ។

ធនាគារអាចនឹងកំណត់កម្រិតប្រតិបត្តិការក្នុងមួយលើក និងប្រចាំថ្ងៃខុសៗគ្នា ទៅតាមប្រភេទខុសៗគ្នានៃសេវាផ្ទេរប្រាក់ក្នុងស្រុក ។ អ្នកអាចស្វែងរកមើលចំនួនទឹកប្រាក់កំណត់នេះនៅតាមបណ្តាញដែលអ្នកបានធ្វើប្រតិបត្តិការ និង/ឬដោយពិគ្រោះយោបល់ជាមួយអ្នកផ្តល់ប្រឹក្សា ឬភ្នាក់ងារនៅផ្នែកទំនាក់ទំនង ។

3.2.9. សេវាផ្ទេរប្រាក់ក្រៅប្រទេស

ធនាគារ ផ្តល់ទម្រង់ផ្សេងៗនៃសេវាផ្ទេរប្រាក់ក្រៅប្រទេស ដូចជា SWIFT, DBP Mobile Transfer, MoneyGram, Ria Money Transfer, Ripple, API ក្នុងសេវាផ្សេងទៀត ។ សេវាផ្ទេរទៅក្រៅប្រទេស គឺអាចប្រើប្រាស់បានទាំង តាមសេវាធនាគារអនឡាញ និងនៅបញ្ជរតាមសាខា ។ សេវាផ្ទេរទៅក្រៅប្រទេសមួយចំនួនអាចនឹងមិនមាននៅតាមបញ្ជរសាខាធនាគារឡើយ លើកលែងតែអតិថិជនគឺជាម្ចាស់គណនី ABA ។

ធនាគារ អាចនឹងដាក់ឲ្យអនុវត្តនូវកម្រិតទឹកប្រាក់ប្រតិបត្តិការក្នុងមួយលើក ឬប្រចាំថ្ងៃផ្សេងៗគ្នា តាមរយៈមធ្យោបាយណាមួយ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការនេះ ។ អ្នកត្រូវបង្ហាញ និងបំពេញព័ត៌មានដែលបានស្នើសុំពាក់ព័ន្ធនឹងការផ្ទេរនេះក្នុងលក្ខណៈមួយពេញលេញ ត្រឹមត្រូវ និងសុក្រឹត្យ ។ ធនាគារ អាចនឹងបដិសេធមិនធ្វើប្រតិបត្តិការ នៅក្នុងដំណាក់កាលណាមួយ ដោយមិនជម្រាបជូនដំណឹងជាមុនដល់អ្នកទទួលប្រាក់ ដោយស្របទៅតាមច្បាប់ជាធរមាន និង/ឬ នៅពេលធនាគារមានមូលហេតុសមស្របដែលអាចជឿថា ប្រតិបត្តិការនេះ ត្រូវបានធ្វើឡើងដោយមិនមានសង្គតិភាពជាមួយនឹងប្រូហ្វាលរបស់ម្ចាស់គណនី ។ ប្រសិនបើធនាគារសម្រេចបដិសេធការផ្ទេរប្រាក់ក្រៅប្រទេស នៅក្នុងដំណាក់កាលណាមួយ នោះធនាគារនឹងជូនដំណឹងដល់អ្នកផ្ញើអំពីមូលហេតុនៃការបដិសេធនោះ លើកលែងតែមានការតម្រូវផ្សេងៗដែលកម្រិតឲ្យធនាគារអនុលោមតាមវិធានការដាក់លាក់ណាមួយ ។

3.2.10. មូលប្បទានបត្រ

មូលប្បទានបត្រផ្តល់ភាពងាយស្រួលក្នុងការទូទាត់វិក្កយបត្រ ឬទទួលប្រាក់ ។ ការដកប្រាក់ អាចប្រតិបត្តិការបាន លុះត្រាតែគណនីរបស់អ្នកទទួល ត្រូវបានអនុញ្ញាតភ្ជាប់ជាមួយមូលប្បទានបត្រ ។

3.2.10.1. ការដាក់មូលប្បទានបត្រ

មូលប្បទានបត្រ ប្រាក់បញ្ញើអេឡិកត្រូនិក ឬឯកសារផ្សេងៗទៀត ដែលត្រូវបានដាក់សម្រាប់ការដាក់ប្រាក់ចូលទៅក្នុងគណនីរបស់អ្នក ត្រូវបានទទួលតាមគោលការណ៍ "សម្រាប់ការប្រមូលប្រាក់" តែប៉ុណ្ណោះ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះពីធនាគារ ។ ចំណុចនេះ មានន័យថា ប្រាក់បញ្ញើត្រូវបាន "ផ្ទាត់ទាត់" សម្រាប់ការទូទាត់ ។ អ្នកមិនអាចដកប្រាក់នោះបានឡើយ រហូតទាល់តែទឹកប្រាក់នេះត្រូវបានផ្ទាត់ទាត់អស់ ។ ជាទូទៅ ប្រតិបត្តិការនេះត្រូវចំណាយពេលចំនួន 2 (ពីរ) ថ្ងៃធ្វើការ ប៉ុន្តែការងារមួយចំនួន អាចចំណាយពេលរហូតទៅដល់ 5 (ប្រាំ) ថ្ងៃធ្វើការឯណោះ ។ ប្រសិនបើការដាក់មូលប្បទានបត្រទាំងអស់ ឬក្នុងចំណែកណាមួយដែលបានដាក់ មិនបានផ្ទាត់ទាត់ទេ នោះចំណែកមួយចំនួន ឬចំណែកទាំងស្រុងដែលបានដាក់តម្កល់ នឹងត្រូវបានបដិសេធ ។ ទឹកប្រាក់ក្នុងគណនីរបស់អ្នក នឹងត្រូវដកចេញទៅតាមចំនួននៃប្រតិបត្តិការដែលត្រូវបានបដិសេធ ។

មានមធ្យោបាយជាច្រើនដែលអ្នកអាចដាក់មូលប្បទានបត្រ រួមមាន ៖

- អញ្ជើញទៅកាន់សាខាធនាគារ ABA
- ប្រើម៉ាស៊ីនដាក់មូលប្បទានបត្រឌីជីថល ABA

3.2.10.2. ការសរសេរមូលប្បទានបត្រ

- សៀវភៅមូលប្បទានបត្រអាចប្រើប្រាស់បានសម្រាប់តែគណនីដែលត្រូវបានអនុញ្ញាតឲ្យមានសិទ្ធិប្រើប្រាស់មូលប្បទានបត្រប៉ុណ្ណោះ។ ព័ត៌មានបន្ថែមអំពីមូលប្បទានបត្រ មាននៅក្នុងផ្នែក "ការប្រើប្រាស់មូលប្បទានបត្រ" នៃ ខ និងលក្ខខណ្ឌទូទៅ។
- មូលប្បទានបត្ររបស់ធនាគារ អាចទិញបាននៅតាមសាខាធនាគារ ឬបញ្ជាទិញតាមរយៈមធ្យោបាយផ្សេងៗ (ដូចជា សេវាធនាគារអនឡាញ ABA)។ ពេលទៅដល់សាខាធនាគារ អ្នកអាចទិញមូលប្បទានបត្រធនាគារ ដោយធ្វើការកាត់ប្រាក់ពីក្នុងគណនីរបស់អ្នក។ ថ្លៃសេវាទិញមូលប្បទានបត្រធនាគារតាមរយៈសេវាធនាគារអនឡាញ នឹងត្រូវកាត់ចេញពីគណនីរបស់អ្នកទៅតាមតម្លៃមូលប្បទានបត្រដែលបានទិញ។

នៅពេលបំពេញមូលប្បទានបត្រ សូមប្រើប្រាស់ប៊ិកហ្ជីត ឬបិចក្បាលមូល ដើម្បីការពារកុំឲ្យមានការកែប្រែ។ សូមសរសេរមូលប្បទានបត្រជាប្រចាំ ដើម្បីធ្វើឲ្យអក្សរ និងតួលេខមិនអាចកែប្រែ ឬបន្ថែមបាន។ អ្នកអាចសរសេរមូលប្បទានបត្រ ដោយបំពេញចន្លោះចំនួនទឹកប្រាក់ឲ្យបានពេញលេញ ឬដោយការគូសបន្ទាត់ដើម្បីបំពេញកន្លែងទំនេរនោះ។ សូមកុំភ្លេចដាក់កាលបរិច្ឆេទឲ្យបានត្រឹមត្រូវនៅលើមូលប្បទានបត្រនោះ។ ប្រសិនបើអ្នកត្រូវការចេញមូលប្បទានបត្រជាសាច់ប្រាក់ សូមកុំទាន់ចុះហត្ថលេខារហូតទាល់តែអ្នកសម្រេចចិត្ត។ សូមកុំចុះហត្ថលេខាទុកមុន នៅលើមូលប្បទានបត្រទំនេរដោយដាច់ខាត។

3.2.11. ឥណទានវិបារូបន៍មិនបានរៀបចំ

ប្រសិនបើគណនីរបស់អ្នកត្រូវបានដកលើសឥណទាន ឬអ្នកប្រើប្រាស់លើសកម្រិតខ្វីដែលបានព្រមព្រៀង (ក្នុងករណីមានការអនុញ្ញាតពីធនាគារ) ធនាគារអាចគិតថ្លៃការប្រាក់លើចំនួនដែលដកលើសពីគណនី ឬចំនួនកំណត់លើអត្រាដកឥណទានរបស់ធនាគារនោះ បូករួមទាំងប្រាក់ពិន័យផងដែរ។ លើសពីនេះ ធនាគារនឹងគិតថ្លៃបន្ទុកចំពោះឥណទានវិបារូបន៍ដែលមិនបានរៀបចំ។

ការសម្រេចចិត្តទទួលយកប្រតិបត្តិការណាមួយ ដែលមានមូលនិធិទូទាត់មិនគ្រប់គ្រាន់ ឬនៅពេលលើសពីការកំណត់ខ្វីដែលបានព្រមព្រៀង ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ត្រូវបានធ្វើឡើងទាំងស្រុងតាមឆន្ទានុសិទ្ធិតែមួយគត់របស់ធនាគារ។ គណនីដាក់ប្រាក់បញ្ញើ មិនអាចដកលើសបានឡើយ លុះត្រាតែអ្នកមានការព្រមព្រៀងគ្នាជាមុនជាមួយធនាគារ ដូចជាតាមរយៈឥណទានវិបារូបន៍។

អ្នកមិនគប្បីធ្វើការដកប្រាក់ ឬការទូទាត់ប្រាក់ ដែល៖

- ធ្វើឲ្យគណនីរបស់អ្នកមានសមតុល្យអវិជ្ជមាន/ឥណពន្ធអវិជ្ជមាន (ឬសមតុល្យ/ឥណពន្ធអវិជ្ជមានច្រើនជាងនេះ) នៅពេលមិនមានការព្រមព្រៀងឥណទានវិបារូបន៍ណាមួយ
- មានន័យថា អ្នកនឹងត្រូវបង់ថ្លៃសេវាចំពោះគណនីរបស់អ្នកដែលក្លាយទៅជាសមតុល្យ/ឥណពន្ធអវិជ្ជមាន (ឬតម្លៃសេវា និង/ឬថ្លៃការប្រាក់ ដែលធ្វើឲ្យគណនីរបស់អ្នកក្លាយជាសមតុល្យ/ឥណពន្ធអវិជ្ជមានធ្ងន់ធ្ងរជាងនេះ) នៅពេលមិនមានការព្រមព្រៀងឥណទានវិបារូបន៍ណាមួយ
- ការដកពីគណនីរបស់អ្នកលើស (ឬដកលើសច្រើន) ពីឥណទានវិបារូបន៍ដែលបានព្រមព្រៀងនៅពេលមានការព្រមព្រៀងឥណទានវិបារូបន៍ណាមួយ
- ការដកមូលនិធិមិនទាន់បានផ្ទាត់ទាត់។ នៅពេលដែលធនាគារ មិនមានកាតព្វកិច្ចអនុវត្តការងារនេះ នៅក្នុងឱកាសដាក់លាក់ណាមួយ ធនាគារអាចនឹងអនុញ្ញាតឲ្យអ្នក ដកលើសឥណទានពីក្នុងគណនីរបស់អ្នក ដូចការរៀបរាប់ខាងលើ។ ឧទាហរណ៍ អាចអនុញ្ញាតឲ្យធ្វើឡើងតាមរយៈការទទួលយកមូលប្បទានបត្រ ឬការទូទាត់ប្រតិបត្តិការ ដោយប្រើប្រាស់មធ្យោបាយផ្សេងៗដូចជា កាតឥណពន្ធ Mastercard ឬ Visa ឬ UnionPay International ("UPI") ការទូទាត់តាមកាលកំណត់ ការដកដោយផ្ទាល់ ឬការដក ឬការទូទាត់តាមរយៈម៉ាស៊ីន ATM ឬមធ្យោបាយប្រតិបត្តិការអេឡិកត្រូនិកផ្សេងៗ។

3.2.12. ការដាក់បញ្ញើជារូបិយប័ណ្ណបរទេស

គណនីជាគណនីប្រាក់ដុល្លារអាមេរិក។ ប្រសិនបើយើងខ្ញុំទទួលបានទឹកប្រាក់ ឬវត្ថុផ្សេងៗជារូបិយប័ណ្ណបរទេស សម្រាប់ការដាក់ប្រាក់បញ្ញើទៅក្នុងគណនីរបស់អ្នក (រួមទាំងការផ្ទេរប្រាក់តាមទូរគមនាគមន៍ ឬមូលប្បទានបត្រជារូបិយប័ណ្ណបរទេស) យើងខ្ញុំនឹងធ្វើការប្តូរទឹកប្រាក់រូបិយប័ណ្ណបរទេសនោះទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទៅតាមអត្រាប្រចាំថ្ងៃនីមួយៗ។ សូមអញ្ជើញមកកាន់សាខាធនាគាររបស់យើងខ្ញុំ ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីអត្រាប្តូរប្រាក់ដែលធនាគារផ្តល់ជូន។

3.2.13. ការដាក់ប្រាក់ចូលក្នុងគណនីរបស់អ្នកសម្រាប់គោលបំណងដាក់លាក់

ធនាគារនឹងមិនទទួលប្រាក់បញ្ញើចូលក្នុងគណនីរបស់អ្នកទេ ក្នុងករណីប្រាក់នោះត្រូវបានរក្សាទុក ឬប្រើប្រាស់សម្រាប់គោលបំណងដាក់លាក់ណាមួយ (ដូចជាការប្រមូលថវិកាពីកម្មវិធីវិនិយោគចំណូលខ្ពស់ដែលអ្នកបានវិនិយោគ) ទោះបីជាសេចក្តីពិពណ៌នាគណនីរបស់អ្នកបញ្ជាក់ពីគោលបំណងដាក់លាក់នោះក៏ដោយ ពេលគឺអនុញ្ញាតបានលុះត្រាតែ អ្នកបានជូនដំណឹងច្បាស់លាស់ថា ប្រាក់បញ្ញើគឺសម្រាប់គណនីរបស់បុគ្គលផ្សេងទៀត ហើយអ្នកអាចបើកគណនីអាណិត្តព្យាបាលដាច់ដោយឡែកសម្រាប់ការដាក់ប្រាក់បញ្ញើនោះ។ ប្រសិនបើពុំមានបញ្ជាក់នៅក្នុងប្រការនេះ នោះការដាក់ប្រាក់ទាំងអស់ដែលត្រូវបានដាក់ចូលក្នុងគណនីរបស់អ្នកនឹងត្រូវគ្រប់គ្រងតាមទម្លាប់អាជីវកម្មធម្មតា។

3.2.14. ការដាក់ប្រាក់ចូលគណនីរបស់អ្នកដែលជាកំហុសរបស់ធនាគារ ABA

ធនាគារអាចនឹងបង្វិលទឹកប្រាក់ទៅគណនីរបស់អ្នកវិញ ប្រសិនបើការដាក់ប្រាក់ទៅក្នុងគណនីនោះ ជាកំហុសបង្កឡើងដោយធនាគារ។

3.2.15. ការទូទាត់ដោយស្វ័យប្រវត្តិ

ដើម្បីធ្វើការទូទាត់ដោយស្វ័យប្រវត្តិ អ្នកអាចអញ្ជើញមកសាខាធនាគារ ABA ណាមួយ ឬបើកដំណើរការដោយខ្លួនឯងតាមសេវាធនាគារអនឡាញ ABA ។

ប្រសិនបើសំណើដែលអ្នកផ្តល់ជូនធនាគារសម្រាប់ការទូទាត់ប្រាក់ដោយស្វ័យប្រវត្តិក្នុងគោលបំណងអាជីវកម្ម នោះធនាគារនឹងទទួលយកសំណើនោះ ដោយមិនទទួលខុសត្រូវលើការបដិសេធ ឬការពុំធ្វើប្រតិបត្តិការទូទាត់ដោយស្វ័យប្រវត្តិ ឬការទទួលខុសត្រូវណាមួយចំពោះការទូទាត់យឺតយ៉ាវ ឬការពុំបានអនុវត្តតាមសំណើនោះឡើយ ។

ធនាគារនឹងយកចិត្តទុកដាក់ និងប្រើប្រាស់ជំនាញអស់ពីលទ្ធភាពដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពនូវសំណើដែលអ្នកផ្តល់ជូនដល់ធនាគារពាក់ព័ន្ធនឹងការទូទាត់ស្វ័យប្រវត្តិ ។ ធនាគារពឹងផ្អែកលើព័ត៌មានទូទាត់ស្វ័យប្រវត្តិប្រកបដោយសុក្រឹត្យភាពដែលអ្នកបានផ្តល់ជូន និងមិនត្រូវបានតម្រូវឲ្យធ្វើការត្រួតពិនិត្យលើសុក្រឹត្យភាពនោះឡើយ ។ អ្នកត្រូវជូនដំណឹងធនាគារភ្លាមៗអំពីព័ត៌មាននៃការទូទាត់ស្វ័យប្រវត្តិក្នុងរបាយការណ៍ធនាគារ ដែលមិនមានភាពត្រឹមត្រូវ ។

សមត្ថកិច្ចក្នុងការទូទាត់ដោយស្វ័យប្រវត្តិត្រូវមានការរៀបចំនៅពេលនេះ ឬបន្ទាប់ពីមានការព្រមព្រៀងពាក់ព័ន្ធនឹងគណនីរបស់លោកអ្នកដែលធ្វើឡើងរវាងអ្នក និងធនាគារ ។ ធនាគារអាចធ្វើការទូទាត់ដោយស្វ័យប្រវត្តិ តាមលំដាប់លំដោយណាមួយដែលធនាគារគិតថាសមស្រប ។ ការទូទាត់នឹងត្រូវកាត់កងទៅតាមថវិកាដែលមាន ហើយអាចទទួលយក បដិសេធ ឬបង្វិលត្រលប់វិញ ប្រសិនបើថវិកាមានចំនួនមិនគ្រប់គ្រាន់ ។

ប្រសិនបើកាលបរិច្ឆេទសម្រាប់ការទូទាត់ដោយស្វ័យប្រវត្តិត្រូវចំថ្ងៃមិនធ្វើការ នោះយើងខ្ញុំនឹងទូទាត់នៅថ្ងៃធ្វើការបន្ទាប់ លើកលែងតែអ្នកស្នើសុំឲ្យខាងធនាគារដំណើរការការទូទាត់នោះ មុនថ្ងៃមិនធ្វើការនោះតែម្តង ។

សមត្ថកិច្ចក្នុងការទូទាត់ដោយស្វ័យប្រវត្តិ នឹងនៅតែមានសុពលភាពជាធរមាន រហូតទាល់តែធនាគារបានបញ្ឈប់ ឬអ្នកទូទាត់ ឬអ្នក ប្រាប់ឲ្យធនាគារលុបចោល ឬក្នុងករណីអ្នកទទួលមរណភាព ឬក្សីយធន (និងនៅពេលដែលធនាគារទទួលដំណឹងអំពីមរណភាព និងការក្សីយធនរបស់អ្នក) ។

ធនាគារនឹងមិនពាក់ព័ន្ធក្នុងជម្លោះណារវាងអ្នក និងបុគ្គលណាម្នាក់ទៀត ដែលកើតចេញពីការទូទាត់ដោយស្វ័យប្រវត្តិឡើយ ។ សំណើសុំការទូទាត់ទាំងឡាយណាដែលមិនបានធ្វើឡើងលើទម្រង់បទដ្ឋានរបស់ធនាគារ នឹងត្រូវចាត់ទុកថាបានបញ្ចូលក្នុង ខ ដែលមានចែងនៅក្នុងទម្រង់បទដ្ឋានរបស់ធនាគារ ។ ប្រសិនបើមានអសង្គតិភាពណាមួយរវាងទម្រង់ទាំងនេះ នោះ ខ ដែលមាននៅក្នុងទម្រង់បទដ្ឋានរបស់ធនាគារនឹងយកជាអាទិភាព ។

3.2.16. គណនីមិនដំណើរការ

ប្រសិនបើគណនីរបស់អ្នកមិនមានប្រតិបត្តិការរយៈពេលចាប់ពី 12 (ដប់ពីរ) ខែឡើងទៅ គិតចាប់ពីថ្ងៃដែលមានប្រតិបត្តិការចុងក្រោយ (លើកលែងប្រតិបត្តិការប្រព័ន្ធ) នោះគណនីរបស់អ្នកនឹងត្រូវចាត់ទុកថាជាគណនីមិនដំណើរការ ហើយធនាគារនឹងចាត់វិធានការដូចខាងក្រោម ៖

- ធនាគារមិនអនុញ្ញាតឲ្យធ្វើការដកប្រាក់ចេញពីគណនីឡើយ លើកលែងតែស្ថានភាពរបស់គណនីនេះ ត្រូវបានប្តូរពី "មិនដំណើរការ" មកជា "ដំណើរការ" ។ ម្ចាស់គណនីត្រូវអញ្ជើញទៅសាខាធនាគារ ឬប្រើមធ្យោបាយណាមួយដែលមាន ដើម្បីផ្លាស់ប្តូរស្ថានភាពពី "មិនដំណើរការ" មកជា "ដំណើរការ" ។
- ធនាគារអាចបិទគណនីរបស់អ្នកដោយស្វ័យប្រវត្ត ដោយមិនជម្រាបជំណឹងជាមុនឡើយ ប្រសិនបើគណនីដែលមិនដំណើរការនោះ មានសមតុល្យសូន្យ ។

មុនពេលចុះឈ្មោះបើកគណនី និងសេវារបស់ធនាគារ ABA អ្នកត្រូវបានជូនដំណឹង និងទទួលស្គាល់ថា គណនីរបស់អ្នកត្រូវតែមានដំណើរការ ប្រើប្រាស់ស្របតាមគោលបំណងដែលបានអះអាង និងមានប្រតិបត្តិការលក្ខណៈជាទីពេញចិត្ត ។ គណនីមិនមានប្រតិបត្តិការ នឹងត្រូវចាត់ទុកថាជាគណនី "មិនដំណើរការ" ។ ធនាគារក៏មានសិទ្ធិដាក់កម្រិតការចូលប្រើប្រាស់គណនីរបស់អ្នកផងដែរ និងចាត់វិធានការផ្សេងៗដែលច្បាប់កម្ពុជាអនុញ្ញាត រហូតដល់ស្ថានភាពគណនីរបស់អ្នកត្រូវបានចាត់ថ្នាក់ជាថ្មីជា "គណនីដំណើរការ" ។ ដូច្នេះ អ្នកទទួលស្គាល់ និងយល់ព្រមថា អ្នកមានកាតព្វកិច្ចធ្វើឲ្យគណនី "ដំណើរការ" ដោយមិនចាំបាច់ត្រូវការឲ្យធនាគាររំលឹកថា គណនីរបស់អ្នកអាចត្រូវបានចាត់ថ្នាក់ជាគណនីមិនដំណើរការ ប្រសិនបើអ្នកមិនបានប្រើប្រាស់គណនីរបស់អ្នក ។ ទោះបីមិនមែនជាកាតព្វកិច្ច ប៉ុន្តែធនាគារអាចជូនដំណឹងដល់អ្នកអំពីថ្លៃសេវាដែលនឹងត្រូវអនុវត្ត នៅពេលគណនីក្លាយជាគណនី "មិនដំណើរការ" តាមមធ្យោបាយណាមួយដែល ខ និងលក្ខខណ្ឌអនុញ្ញាត ។ អ្នកត្រូវបានជូនដំណឹង និងណែនាំឲ្យបើកដំណើរការគណនីរបស់អ្នកវិញ មុនពេលការបង់ថ្លៃសេវា និងបន្ទុកត្រូវបានអនុវត្ត និងការចាត់វិធានការតឹតតឹតផ្សេងៗ ។

3.2.17. ការបើកដំណើរការឡើងវិញ ចំពោះគណនីមិនដំណើរការ

ធនាគារអនុញ្ញាតឲ្យបើកដំណើរការឡើងវិញ ចំពោះគណនីមិនដំណើរការ បន្ទាប់ពីបានផ្ញើរដ្ឋាត់បញ្ជាក់ថា អ្នកជាម្ចាស់គណនី ឬហត្ថលេខី នៃគណនីមិនដំណើរការនោះ ។ ធនាគារ ផ្តល់ជូននូវបណ្តាញផ្សេងៗជាច្រើន ដែលអ្នកអាចប្រើប្រាស់ ដើម្បីបើកដំណើរការ គណនីមិនដំណើរការរបស់អ្នក ឧទាហរណ៍ អ្នកអាចស្នើដោយបំពេញពាក្យសុំផ្លាស់ប្តូរស្ថានភាពគណនី ពីមិនដំណើរការ ទៅជាដំណើរការ ឬ ដកប្រាក់ពីគណនីរបស់អ្នក នៅសាខាណាមួយរបស់ធនាគារយើងខ្ញុំដែលនៅជិតអ្នក ។ ជម្រើសផ្សេងពីនេះ អ្នកអាចបើកដំណើរការគណនីរបស់អ្នកឡើងវិញ តាមបណ្តាញអេឡិកត្រូនិក ដោយធ្វើប្រតិបត្តិការផ្ទេរប្រាក់ចេញពីគណនីមិនដំណើរការនោះផ្ទាល់ ។

3.2.18. ប្រាក់មិនបានដកពីគណនីអសកម្ម

ប្រសិនបើអ្នកមិនបានធ្វើប្រតិបត្តិការលើគណនីមិនដំណើរការ របស់អ្នកក្នុងរយៈពេល 10 (ដប់) ឆ្នាំ ធនាគារនឹងបិទគណនីរបស់លោកអ្នក ហើយធ្វើការផ្ទេរចំនួនទឹកប្រាក់ដែលមានក្នុងគណនីរបស់លោកអ្នក ទៅកាន់ធនាគារដាតិនៃកម្ពុជា ឬស្ថាប័នរដ្ឋាភិបាល ស្របតាមច្បាប់ជាធរមាន ដោយមិនមានការជូនដំណឹងផ្នែករដ្ឋបាលបន្ថែមឡើយ ។ ទោះបីមិនមែនជាកាតព្វកិច្ច ធនាគារអាចនឹងជូនដំណឹងដល់អ្នក មុនពេលបិទគណនីមិនដំណើរការរបស់អ្នក ប៉ុន្តែអាចមានកាលៈទេសៈមួយចំនួនដែលធនាគារមិនអាចជូនដំណឹងបាន (ដូចជា នៅពេលដែលកំណត់ត្រាអាសយដ្ឋានរបស់អ្នក ឬលេខទំនាក់ទំនងរបស់អ្នកមិនមានធ្វើបច្ចុប្បន្នភាព) ។ លោកអ្នកអាចអញ្ជើញមកកាន់សាខារបស់ធនាគារដើម្បីស្វែងយល់អំពីមធ្យោបាយទទួលយកនូវប្រាក់ដែលមិនបានដកនោះមកវិញ (វាអាចត្រូវការពេលយូរក្នុងការទទួលយកប្រាក់ដែលត្រូវបានផ្ទេរទៅរដ្ឋាភិបាលរួចហើយ) ។

3.2.19. ការព្យួរ ការបិទ ឬការដាក់គណនីបញ្ចូលគ្នា

អ្នកអាចស្នើសុំឲ្យធនាគារបិទគណនីរបស់ខ្លួនបានគ្រប់ពេលវេលាទាំងអស់ ។ ធនាគារ នឹងតម្រូវឲ្យអ្នកបង្ហាញវត្តមានផ្ទាល់ ដើម្បីស្នើសុំបិទគណនីរបស់អ្នក ។ អ្នកត្រូវបានណែនាំឲ្យបិទគណនីរបស់ខ្លួនបានតែនៅតាមសាខាដែលអ្នកបើកគណនីនោះប៉ុណ្ណោះ ។ ប៉ុន្តែ ធនាគារអាចនឹងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុញ្ញាតឲ្យបិទគណនីរបស់អ្នកនៅសាខាផ្សេងរបស់ធនាគារ ដោយផ្អែកលើប្រភេទគណនីដែលអ្នកបើក និងសំណើសុំដកប្រាក់នៅពេលដំណើរការបិទគណនីនោះ ។

ប្រសិនបើធនាគារគិតថា គណនីណាមួយរបស់អ្នកមិនបានប្រើប្រាស់ស្របតាមលក្ខណៈត្រឹមត្រូវទេ គណនីនោះនឹងត្រូវព្យួរប្រតិបត្តិការ ឬបិទគណនីណាមួយ/ទាំងអស់ ។ ធនាគារនឹងមិនទទួលខុសត្រូវលើការខាតបង់ណាមួយបណ្តាលមកពីការព្យួរ ឬបិទគណនីនោះឡើយ ។ លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចអនុវត្តបាន ធនាគារនឹងបិទគណនីរបស់អ្នក បន្ទាប់ពីបានជូនដំណឹងសមស្របណាមួយដល់អ្នក និងបានកំណត់ព័ត៌មានលម្អិតអំពីគណនីដែលត្រូវបិទ ។

នៅគ្រប់ពេលវេលាទាំងអស់ ដោយពុំចាំបាច់ជូនដំណឹងជាមុន ធនាគារអាចប្រើប្រាស់សមតុល្យឥណទានក្នុងគណនីរបស់លោកអ្នកទាំងអស់ ឬដោយផ្ទែក ទោះជារូបិយប័ណ្ណណាមួយក៏បាន ដើម្បីទូទាត់ប្រាក់នានាដែលអ្នកជំពាក់ធនាគារ ។ ប្រសិនបើចំនួនទឹកប្រាក់មួយដល់កំណត់ ឬមិនបានគណនាដោយយថាភាពណាមួយ ធនាគារអាចនឹងកាត់ទុកនូវការទូទាត់សមតុល្យឥណទានទាំងឡាយ ដែលរងចាំដល់កំណត់ ឬការគណនា និងអាចបណ្តាលឲ្យមានបំណុលអតិបរមាដែលអាចដល់កាលកំណត់គ្រប់ពេលវេលា ។ កថាខណ្ឌនេះ ត្រូវអនុវត្តដោយមិនប៉ះពាល់សិទ្ធិ និងបន្ថែមពីលើសិទ្ធិកាត់កង គណនីច្រើនរួមគ្នា ប្រតិភោគ ឬសិទ្ធិផ្សេងៗទៀតដែលជាសិទ្ធិរបស់ធនាគារដោយយោងទៅតាមមធ្យោបាយនៃការអនុវត្តច្បាប់ ឬកិច្ចសន្យា និងការអនុវត្តផ្សេងៗក្រៅពីនេះ ។

ធនាគារអាចព្យួរប្រតិបត្តិការគណនីណាមួយ ឬបិទគណនីណាមួយរបស់អ្នកដោយមិនជម្រាបជូនដំណឹងដល់អ្នកជាមុនឡើយ ប្រសិនបើ (ហើយបញ្ជីនេះមិនទាន់ពេញលេញទេ)៖

- អ្នកប្រើប្រាស់គណនីក្នុងលក្ខណៈមិនត្រឹមត្រូវ (ដូចជា ចេញមូលប្បទានបត្រគ្មានទឹកប្រាក់គ្រប់គ្រាន់ គណនីត្រូវបានប្រើប្រាស់ក្នុងសកម្មភាពហាមឃាត់)
- ធនាគារអនុលោមតាមដីការបស់តុលាការ
- អ្នកបានប្រព្រឹត្តអំពើល្មើសច្បាប់
- អ្នកបានរំលោភបំពាន ខ និងលក្ខខណ្ឌគណនី ផលិតផល ឬសេវាកម្មណាមួយ
- អ្នកបានប្រព្រឹត្តអំពើដែលរំលោភបំពានលើបុគ្គលិកធនាគារ
- ធនាគារទទួលបានការជូនដំណឹងអំពីភាគីទីបីដែលធ្វើការទាមទារពាក់ព័ន្ធនឹងគណនីរបស់អ្នក ។ ធនាគារមិនទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការព្យួរគណនីនេះឡើយ ។

3.2.20. ការបិទគណនី

- ផ្អែកតាមបញ្ញត្តិគណនី ដែលអ្នកបានកំណត់ អំឡុងពេលបើកគណនី អ្នក ឬបុគ្គលទទួលសិទ្ធិផ្សេងទៀត អាចបិទគណនីរបស់អ្នកបានគ្រប់ពេលវេលាទាំងអស់ តាមបណ្តាញនានារបស់ធនាគារ ។
- នៅក្នុងកាលៈទេសៈកម្រ ធនាគារអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបិទ ឬការបដិសេធមិនទទួលយកការដាក់ប្រាក់បន្ថែម ឬអនុញ្ញាតការដកប្រាក់បន្ថែម ដោយសារតែប្រតិបត្តិការធ្វើឡើងក្នុងលក្ខណៈមិនត្រឹមត្រូវ ឬដោយសារមូលហេតុផ្សេងណាមួយដែលសមស្រប ដូចជា ៖
  - ប្រសិនបើគណនីរបស់អ្នកត្រូវបានបង្កើតឡើងសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬជាលក្ខណៈបុគ្គល ដោយរូបអ្នកក្នុងនាមជាអតិថិជនផ្ទាល់ និងកំពុងត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្សេង ឬ
  - នៅពេលដែលអ្នកកាន់កាប់គណនីដែលត្រូវបានកំណត់ឲ្យប្រើដើម្បីជាប្រយោជន៍របស់អ្នកក្នុងនាមជាម្ចាស់គណនី ដែលមិនទាន់គ្រប់អាយុ ពោលគឺអនីតិជន ហើយតាមការយល់ឃើញរបស់ធនាគារ គណនីបែរជាត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្សេងដែលមិនផ្តល់ជាប្រយោជន៍ដល់អ្នក ឬមិនផ្តល់ផលប្រយោជន៍ដល់ម្ចាស់គណនីដែលមានអាយុក្រោម 18 ឆ្នាំ ។ ធនាគារនឹងជូនដំណឹងដល់អ្នក ឬហត្ថលេខីណាម្នាក់/បណ្តាហត្ថលេខី មុនពេលបិទគណនី ។

3.2.21. ចំណុចត្រូវចងចាំនៅពេលបិទគណនី

នៅពេលដែលអ្នកបិទគណនី អ្នកត្រូវផ្តល់ជូនធនាគារនូវ ៖

- កាតដែលប្រតិបត្តិការគណនី (រួមទាំងកាតដែលបានចេញជូនម្ចាស់កាតបន្ថែម)
- មូលប្បទានបត្រមិនទាន់ប្រើ
- សៀវភៅធនាគារ

គណនីដែលអាចប្រើប្រាស់មូលប្បទានបត្រ អាចធ្វើការបិទបានលុះត្រាតែមូលប្បទានបត្រដែលបានចេញតាមរយៈគណនីដោយមិនទាន់ទូទាត់ ត្រូវបានយកមកជាមួយ និង/ឬបិទរួចហើយ ។ ធនាគារសូមរក្សាសិទ្ធិប្រគល់មូលប្បទានបត្រដែលយកមកទូទាត់នោះត្រលប់ទៅវិញ បន្ទាប់ពីគណនីត្រូវបានបិទ ស្របតាមច្បាប់ជាធរមាន ។

4. ការយល់ដឹងអំពីកាតឥណពន្ធ

4.1. ការអនុញ្ញាតឲ្យនរណាម្នាក់ប្រើប្រាស់គណនីរបស់អ្នក

អ្នកត្រូវផ្តល់សិទ្ធិជាច់ដោយឡែកមួយដើម្បីអនុញ្ញាតឲ្យបុគ្គលផ្សេងទៀតចូលប្រើប្រាស់គណនីរបស់អ្នកតាមរយៈកាត ហើយសិទ្ធិនេះគឺជាច់ដោយឡែកពីសិទ្ធិអនុញ្ញាតឲ្យបុគ្គលផ្សេងទៀតប្រតិបត្តិការគណនីតាមរយៈសាខា (ដូចដែលបានកំណត់ខាងក្រោម)។ សូមមើល ខ និងលក្ខខណ្ឌកាតសម្រាប់ដាក់ព័ត៌មានបន្ថែមអំពីការអនុញ្ញាតឲ្យបុគ្គលផ្សេងចូលប្រើប្រាស់គណនីរបស់អ្នកតាមរយៈកាតក្នុងនាមជាអ្នកប្រើកាតដែលទទួលសិទ្ធិ។ សម្រាប់គណនីរួម ម្ចាស់គណនីរួមនីមួយៗ ត្រូវចុះហត្ថលេខាលើឯកសារផ្តល់សិទ្ធិ។ ទម្រង់ជូនដំណឹងអំពីការផ្តល់សិទ្ធិនេះមាននៅតាមសាខា និងវិបសាយ www.ababank.com។

ការទទួលខុសត្រូវបន្ទាប់ពីបញ្ចប់សិទ្ធិ	▪ ម្ចាស់គណនី ឬហត្ថលេខីទទួលសិទ្ធិ អាចបញ្ចប់សិទ្ធិធ្វើប្រតិបត្តិការបានគ្រប់ពេលវេលា ដោយយោងតាម ខ និងលក្ខខណ្ឌគណនី លើកលែងតែមានហត្ថលេខីទទួលសិទ្ធិតែម្នាក់លើគណនីដែលកាន់កាប់ដោយអនីតិជន។ ▪ ប៉ុន្តែ អ្នកត្រូវទទួលខុសត្រូវចំពោះ៖ ▪ គ្រប់ប្រតិបត្តិការដែលបានធ្វើឡើង (រួមទាំងប្រតិបត្តិការធ្វើឡើងដោយកាគីទីបី) មុនពេលសិទ្ធិអនុញ្ញាតត្រូវបានបញ្ចប់ ទោះបីជាទឹកប្រាក់មិនទាន់ត្រូវបានកាត់ពីគណនីក៏ដោយ (រួមបញ្ចូលទាំងថ្លៃសេវា និងបន្ទុកពាក់ព័ន្ធ) និង ▪ ការទូទាត់ពេលខាងមុខ, ការទូទាត់មូលប្បទានបត្រ, ឥណពន្ធមានការអនុញ្ញាត, ការទូទាត់តាមកាលកំណត់, ការទូទាត់វិក្កយបត្រ, លិខិតបញ្ជាទិញ, រូបិយាណត្តិ ឬកិច្ចសន្យាទូទាត់បង្កើតដោយហត្ថលេខីទទួលសិទ្ធិ មុនពេលបញ្ចប់សិទ្ធិ នោះប្រភេទទូទាត់ទាំងនេះ ត្រូវបានអនុញ្ញាតលើគណនីរបស់អ្នក។
សិទ្ធិពាក់ព័ន្ធនឹងកាតឥណពន្ធ	▪ ធនាគារអាចចេញកាតឥណពន្ធបន្ថែមជូនបុគ្គលណាម្នាក់ដែលអ្នកបានតែងតាំង ប្រសិនបើបុគ្គលទាំងនោះគឺជានីតិជន (មានឯកសារជ្យភាពតាមច្បាប់) ហើយធនាគារមានសិទ្ធិពិនិត្យ។ ▪ អ្នកត្រូវទទួលខុសត្រូវចំពោះធនាគារសម្រាប់ការប្រើប្រាស់កាតឥណពន្ធរបស់ម្ចាស់កាតដែលជាកាគីទីបី។
សិទ្ធិរបស់ហត្ថលេខីទទួលសិទ្ធិ	▪ ហត្ថលេខីទទួលសិទ្ធិនីមួយៗ នឹងមិនអាចបន្ថែម ឬបញ្ចប់ភាគីទីបីណាផ្សេងទៀតនៅក្នុងគណនីដែលពួកគេប្រើប្រាស់បានឡើយ ▪ ក្រៅពីសិទ្ធិផ្សេងៗរបស់ហត្ថលេខីទទួលសិទ្ធិ ប្រសិនបើម្ចាស់គណនីមានអាយុក្រោម 18 ឆ្នាំ ហត្ថលេខីទទួលសិទ្ធិអាចអនុវត្តដូចខាងក្រោម៖ ▪ កែប្រែព័ត៌មានលម្អិតរបស់ម្ចាស់គណនីនៅលើគណនី ▪ ក្នុងករណីសមស្របមួយចំនួន ធនាគារកម្រលុបចោលសិទ្ធិប្រតិបត្តិការរបស់បុគ្គលណាមួយដែលទទួលសិទ្ធិធ្វើប្រតិបត្តិការគណនីរបស់អ្នក ដោយសារការធ្វើប្រតិបត្តិការមិនត្រឹមត្រូវ ឬដោយហេតុផលណាមួយសមស្របផ្សេងដែលធនាគារគិតថាសមស្រប ដូចជាប្រសិនបើធនាគារជឿជាក់ថាការបន្តអនុញ្ញាតផ្តល់សិទ្ធិលើគណនីរបស់អ្នកអាចធ្វើឲ្យអ្នក ឬធនាគារខាតបង់។
វិាទ	ប្រសិនបើធនាគារទទួលបានការជូនដំណឹងអំពីវិាទពាក់ព័ន្ធនឹងសិទ្ធិ ម្ចាស់គណនីម្នាក់ ឬច្រើននាក់ ធនាគារអាចបដិសេធក្នុងការអនុញ្ញាតប្រតិបត្តិការលើគណនីរបស់អ្នក លុះត្រាណាតែគូភាគីសាមីទាំងអស់បានចុះហត្ថលេខាលើសិទ្ធិណាមួយដែលធនាគារតម្រូវ។

ប្រសិនបើអ្នកត្រូវការកាតបន្ថែមសម្រាប់អ្នកផ្សេងទៀតប្រើប្រាស់ អ្នកអាចដាក់បែបបទស្នើសុំផ្ញើរការទៅកាន់ធនាគារឲ្យចេញកាតបន្ថែមទៅឲ្យបុគ្គលដែលអ្នកបានតែងតាំង។ បុគ្គលនោះ ត្រូវបានតែងតាំងជាបុគ្គលទទួលបានសិទ្ធិបន្ថែមលើគណនីរបស់អ្នក និងត្រូវតែចុះហត្ថលេខាដោយខ្លួនឯង។

កាតបន្ថែមអាចនឹងត្រូវប្រើប្រាស់ដើម្បីចូលប្រើប្រាស់គណនីរបស់អ្នក និងត្រូវអនុលោមតាមលក្ខខណ្ឌទាំងនេះ។ ក្នុងនាមជាម្ចាស់គណនី អ្នកត្រូវទទួលខុសត្រូវលើការប្រើប្រាស់កាតភ្នាក់ងារ/បន្ថែមនោះ ដូចដែលអ្នកប្រើប្រាស់កាតនោះផ្ទាល់ និងទទួលខុសត្រូវលើការរំលោភបំពានរបស់បុគ្គលដែលអ្នកបានតែងតាំងលើលក្ខខណ្ឌទាំងនោះ។

ក្រៅពីការជូនដំណឹងដល់ធនាគារអំពីការបញ្ឈប់សិទ្ធិនោះ ដើម្បីបញ្ឈប់សិទ្ធិរបស់ភ្នាក់ងារ/បុគ្គលបន្ថែមនៅលើគណនីរបស់អ្នក ដែលកាតភ្នាក់ងារ/កាតបន្ថែមនោះ ត្រូវបានបើកប្រើប្រាស់ អ្នកត្រូវតែស្នើសុំធនាគារឲ្យបញ្ឈប់កាតភ្នាក់ងារ/កាតបន្ថែមនោះ និងត្រូវប្រគល់កាតនោះមកឲ្យធនាគារវិញ។ កាតភ្នាក់ងារ/កាតបន្ថែមនោះ នឹងត្រូវបញ្ឈប់ នៅពេលធនាគារទទួលបានកាតនោះមកវិញ។

4.2. វិធានអំពីកាតឥណពន្ធ

លក្ខខណ្ឌទាំងនេះ អនុវត្តចំពោះការប្រើប្រាស់កាតឥណពន្ធរបស់ធនាគារ ដែលបើកជូនសម្រាប់ចូលប្រើប្រាស់គណនីរបស់អ្នក។ ពេលអ្នកប្រើប្រាស់កាតនេះ ដើម្បីធ្វើប្រតិបត្តិការអេឡិកត្រូនិក អ្នកបានយល់ព្រមចងកាតព្វកិច្ចដោយលក្ខខណ្ឌទាំងនេះ បន្ថែមពីលើ ខ និងលក្ខខណ្ឌដែលបានចែងនៅក្នុង ខ និងលក្ខខណ្ឌរបស់កាត។

4.2.1. ការមកទទួលកាតឥណពន្ធរបស់អ្នក

អ្នកយល់ព្រមថា អ្នកនឹងមកទទួលកាតដែលអ្នកស្នើសុំដោយខ្លួនឯងផ្ទាល់នៅសាខាដែលអ្នកស្នើសុំ ឬសាខាផ្សេងដែលអ្នកបានយល់ព្រម ឬបានរៀបចំឯកសារនៅពេលស្នើសុំកាត។ ក្នុងករណី អ្នកចង់ឲ្យធនាគារប្រគល់កាតនោះឲ្យអ្នកតាមអាសយដ្ឋាន ឬកន្លែងណាមួយដែលអ្នកកំណត់ អ្នកត្រូវយល់ព្រមថា ធនាគារអាចដឹកជញ្ជូនកាតនោះជូនលោកអ្នកតាមរយៈក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនដែលធនាគារចាត់តាំង ហើយអ្នកយល់ព្រមថា ធនាគារអាចបង្ហាញព័ត៌មានផ្ទាល់ខ្លួនមួយចំនួនរបស់អ្នកដល់ក្រុមហ៊ុនដឹកជញ្ជូនក្នុងគោលបំណងរៀបចំការដឹកជញ្ជូននោះ។ អ្នកយល់ព្រមទទួលរ៉ាប់រងចំពោះធនាគារ សម្រាប់រាល់ការខាតបង់ និងបណ្តឹងទាំងអស់ដែលកើតឡើងបណ្តាលមកពីការយល់ព្រមរបស់អ្នកក្នុងការអនុញ្ញាតឲ្យធនាគារផ្លាស់ប្តូរព័ត៌មាននោះជាមួយក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូន ដើម្បីដឹកជញ្ជូនកាតនោះទៅឲ្យអ្នកដោយផ្ទាល់។

អ្នកត្រូវព្រមព្រៀងបន្ថែមថា ក្នុងករណីដែលកាតត្រូវបានបើកជូន ហើយលោកអ្នកមិនមកទទួលក្នុងរយៈពេល 60ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទធនាគារបើកកាតទេ នោះធនាគារមានសិទ្ធិបញ្ឈប់កាតនោះ ដោយមិនសងថ្លៃសេវាបើកកាត ឬសេវាថែទាំកាតប្រចាំឆ្នាំទៅឲ្យអ្នកវិញឡើយ ហើយអ្នកត្រូវយល់ព្រមបន្ថែមថា អ្នកនឹងត្រូវបង់ថ្លៃសេវាបើកកាតម្តងទៀត ប្រសិនបើអ្នកស្នើសុំកាតឥណពន្ធជាថ្មី។

4.2.2. ការបើកដំណើរការកាតឥណពន្ធរបស់អ្នក

អ្នកយល់ច្បាស់ថា កាតឥណពន្ធមិនអាចប្រើប្រាស់បានឡើយ ប្រសិនបើកាតនោះមិនទាន់បានបើកដំណើរការ។ ដូច្នេះ អ្នកត្រូវយល់ព្រមបើកដំណើរការកាតនោះភ្លាមៗ នៅតាមម៉ាស៊ីន ATM របស់ធនាគារ ឬតាមកម្មវិធី ABA Mobile នៅពេលដែលអ្នកទទួលបានកាតនោះជាកម្មសិទ្ធិ និងត្រូវប្តូរលេខសម្ងាត់ (PIN) ភ្លាមៗផងដែរ។

អ្នកយល់ច្បាស់ថា ក្នុងអំឡុងពេលបើកដំណើរការកាតតាមម៉ាស៊ីន ATM ឬតាមកម្មវិធី ABA Mobile លេខសម្ងាត់ (PIN) នឹងត្រូវផ្ញើទៅលោកអ្នកតាមរយៈលេខទូរស័ព្ទដែលបានចុះបញ្ជីជាមួយធនាគារ ដូច្នេះ អ្នកយល់ព្រមធានាថា ទូរស័ព្ទរបស់អ្នកមានដំណើរការល្អ ក្នុងអំឡុងពេលដំណើរការនោះ។

អ្នកយល់ច្បាស់ថា លេខសម្ងាត់ (PIN) ដែលបានផ្ញើទៅអ្នក គឺមិនចេះអស់សុពលភាពនោះទេ ហើយជាលេខដូចៗគ្នា មិនថាអ្នកស្នើសុំលេខសម្ងាត់ (PIN) ប៉ុន្មានដងនោះទេ ដូច្នេះ អ្នកទទួលស្គាល់ និងយល់ព្រមថា អ្នកនឹងប្តូរលេខសម្ងាត់ (PIN) ភ្លាមៗនៅពេលដែលអ្នកទទួលបានកាតនោះ។ ការមិនបានអនុវត្តតាមការណែនាំខាងលើ អ្នកយល់ព្រមទទួលរ៉ាប់រងចំពោះធនាគារ សម្រាប់រាល់ការខាតបង់ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន។

ធនាគារ អាចនឹងដាក់ឲ្យដំណើរការតាមបណ្តាញអនឡាញផ្សេងៗសម្រាប់ការបើកដំណើរការកាត។ ប្រសិនបើមានការដាក់ឲ្យដំណើរការ ធនាគារនឹងជូនដំណឹងដល់អ្នក។

4.2.3. ការការពារកាតឥណពន្ធ និងលេខសម្ងាត់ (PIN) របស់អ្នក

នៅពេលអ្នកទទួលបានកាត អ្នកត្រូវតែចុះហត្ថលេខានៅផ្នែកខាងក្រោយកាតភ្លាមៗ ដោយប្រើប្រាស់ហត្ថលេខាដូចគ្នាទៅនឹងហត្ថលេខាដែលអ្នកបានប្រើប្រាស់លើទម្រង់បែបបទស្នើសុំបើកគណនី/ទម្រង់ហត្ថលេខាគំរូ។ អ្នកត្រូវរក្សាទុកកាតនោះនៅតាមខ្លួនអ្នក ឬនៅកន្លែងសុវត្ថិភាពនៅគ្រប់ពេលវេលាទាំងអស់។

អ្នកអាចជ្រើសរើសលេខសម្ងាត់ (PIN) ផ្ទាល់ខ្លួនសម្រាប់កាតរបស់អ្នកនៅតាមម៉ាស៊ីន ATM តាមកម្មវិធី ABA Mobile ឬសាខាធនាគារបាន។ លេខសម្ងាត់ (PIN) របស់អ្នកអាចឲ្យអ្នកចូលប្រើប្រាស់គណនីរបស់អ្នកជាមួយធនាគារ។ លេខសម្ងាត់ (PIN) ដែលអ្នកជ្រើសរើសមិនត្រូវ៖

- ជាលេខងាយចំណាំ ឬការដាក់បញ្ចូលគ្នាជាលេខលំដាប់នោះទេ (ដូចជា 1100 ឬ 3456)ឬ
- ផ្អែកលើទិន្នន័យដែលងាយនឹងរកបាន (ដូចជាថ្ងៃខែឆ្នាំកំណើត ឬផ្នែកនៃលេខទូរស័ព្ទ)

ជាការចាំបាច់ដែលអ្នកត្រូវចងចាំលេខសម្ងាត់ (PIN) របស់អ្នក។ ប្រសិនបើអ្នកមានការលំបាកក្នុងការចងចាំលេខសម្ងាត់ (PIN) សូមប្រឹក្សាជាមួយធនាគារអំពីការជ្រើសរើសលេខសម្ងាត់ (PIN) នោះ។ អ្នកមិនត្រូវ៖

- សរសេរលេខសម្ងាត់ (PIN) នៅលើកាត ឬភ្ជាប់ជាមួយកាត ឬ នៅកន្លែងណាមួយឡើយ ឬ
- សរសេរទុក ឬ
- បង្ហាញឲ្យអ្នកផ្សេងដឹង ក្នុងនោះរួមទាំងសមាជិកគ្រួសារ ឬអ្នកដែលមានសមត្ថកិច្ច ឬរួមទាំងបុគ្គលិកធនាគារផងដែរ ឬ
- បញ្ចេញព័ត៌មាននេះដោយធ្វេសប្រហែស (ដូចជា មិនប្រយ័ត្ន មិនបានការពារលេខសម្ងាត់កុំឲ្យអ្នកដទៃឃើញអ្នកក្នុងពេលបញ្ចូល)

ប្រសិនបើលេខសម្ងាត់ (PIN) របស់អ្នកត្រូវបានបុគ្គលណាម្នាក់ដឹង អ្នកត្រូវតែប្តូរលេខនោះជាបន្ទាន់។ សូមជូនដំណឹងទៅកាន់ធនាគារ ប្រសិនបើអ្នកមិនចង់ប្រើប្រាស់មុខងារណាមួយដែលត្រូវការលេខសម្ងាត់ (PIN) សម្រាប់ចូលប្រើប្រាស់។

4.2.4. សុពលភាព និងការផុតកាលកំណត់កាត

កាតនេះត្រូវប្រើប្រាស់នៅអំឡុងកាលបរិច្ឆេទ "មានសុពលភាពពី" និង "មានសុពលភាពដល់"។ នៅពេលកាតផុតកាលកំណត់ អ្នកត្រូវប្រាកដថា អ្នកបានកម្ទេចកាតនោះចោល ដោយកាត់កាតនោះទៅជាបំណែកតូចៗ និងបោះចោលទៅកន្លែងមានសុវត្ថិភាព។

4.2.5. កម្រិតកំណត់ប្រតិបត្តិការកាត

ធនាគារអាចនឹងកំណត់កម្រិតទឹកប្រាក់ប្រតិបត្តិការក្នុងមួយលើក និងប្រចាំថ្ងៃ ដើម្បីគ្រប់គ្រងការប្រើប្រាស់កាតរបស់អ្នក សម្រាប់ពង្រឹងការគ្រប់គ្រងហានិភ័យ៣ក់ព័ន្ធនឹងការប្រើប្រាស់កាត។ កាតឥណពន្ធប្រភេទផ្សេងគ្នាមានកម្រិតទឹកប្រាក់ប្រតិបត្តិការផ្សេងៗគ្នា។ សូមពិគ្រោះយោបល់ជាមួយបុគ្គលិកផ្នែកប្រឹក្សា ផ្នែកគាំទ្រអតិថិជន និង/ឬចូលទៅកាន់វិបសាយរបស់ធនាគារសម្រាប់ព័ត៌មានលម្អិតបន្ថែម។

ធនាគារអាចពិនិត្យឡើងវិញលើកម្រិតទឹកប្រាក់ប្រតិបត្តិការនេះ ជាប្រចាំស្របទៅតាម ខ និងលក្ខខណ្ឌជាក់លាក់។ នៅពេលធនាគារធ្វើការផ្លាស់ប្តូរ ធនាគារនឹងជូនដំណឹងដល់អ្នកតាមមធ្យោបាយផ្សេងៗ ដូចមានកំណត់ក្នុង ខ និងលក្ខខណ្ឌនេះ។

4.3. សេវាកម្ម

កាតឥណពន្ធរបស់អ្នកអនុញ្ញាតឲ្យអ្នកចូលទៅប្រើប្រាស់គណនី ABA ដែលអ្នកបានកំណត់ តាមប្រព័ន្ធអេឡិកត្រូនិក តាមរយៈ៖

- ម៉ាស៊ីន ATM របស់ធនាគារមួយចំនួនទាំងនៅក្នុង និងក្រៅប្រទេស
- ម៉ាស៊ីន ATM មួយចំនួននៅក្រៅប្រទេសដែលមានឡូហ្គោកាត Visa Mastercard ឬ UPI ហើយឡូហ្គោទាំងនោះត្រូវគ្នានឹងឡូហ្គោនៅលើកាតរបស់អ្នក។
- ម៉ាស៊ីនទូទាត់ POS របស់ធនាគារ ABA
- អាជីវករនៃពាណិជ្ជកម្មអេឡិកត្រូនិកដែលបង្ហាញឡូហ្គោ Visa UPI ឬ Mastercard ដែលឡូហ្គោទាំងនោះត្រូវគ្នានឹងរូបសញ្ញានៅលើកាតរបស់អ្នក។
- អាជីវករមួយចំនួននៅបរទេស ដែលមានប្រើប្រាស់ម៉ាស៊ីនទូទាត់ POS ដែលបង្ហាញឡូហ្គោ Visa UPI ឬ Mastercard។

ធនាគារអាចបន្ថែម រឹតត្បិត ឬផ្លាស់ប្តូរមធ្យោបាយធ្វើប្រតិបត្តិការអេឡិកត្រូនិក។

ធនាគារមិនទទួលខុសត្រូវ ប្រសិនបើ៖

- អាជីវករមិនទទួលយកកាតរបស់អ្នក ឬមិនអនុញ្ញាតឲ្យអ្នកប្រើប្រាស់ម៉ាស៊ីនទូទាត់ POS ដែលប្រតិបត្តិការដោយអាជីវករបូបនោះ ឬ
- អាជីវករមិនអនុញ្ញាតឲ្យអ្នកដកសាច់ប្រាក់ពីម៉ាស៊ីនទូទាត់ POS ឬ
- អ្នកមិនពេញចិត្តចំពោះទំនិញ ឬសេវាណាមួយ ដែលអ្នកបានទិញដោយប្រើប្រាស់កាតរបស់អ្នក

ការចូលប្រើម៉ាស៊ីនទូទាត់ POS ទាំងនៅក្នុង និងក្រៅប្រទេស ត្រូវបានកំណត់ផ្តាច់មុខដោយអាជីវករដែលធ្វើប្រតិបត្តិការម៉ាស៊ីនទូទាត់ POS នោះ។ ធនាគារមិនអាចបញ្ឈប់ប្រតិបត្តិការអេឡិកត្រូនិកដែលបានធ្វើឡើងដោយប្រើប្រាស់កាតរបស់អ្នកឡើយ។

អ្នកមិនអាចធ្វើប្រតិបត្តិការត្រលប់ដោយប្រើប្រាស់កាតរបស់អ្នកឡើយ។ ក្នុងកាលៈទេសៈមួយចំនួន អាជីវករអាចដាក់ប្រាក់ចូលគណនីចរន្ត គណនីសន្សំ ឬគណនីកាតឥណទានរបស់អ្នកបាន ទៅតាមការសម្រេចចិត្តរបស់អាជីវករ។

4.4. កាតបាត់ ឬត្រូវគេលួច ឬលេខសម្ងាត់ (PIN) មានគេដឹង

ប្រសិនបើកាតរបស់អ្នកបានបាត់ ឬត្រូវគេលួច (ឬអ្នកគិតថា កាតរបស់អ្នកអាចបាត់ ឬអាចត្រូវគេលួច) ឬលេខសម្ងាត់ (PIN) របស់អ្នកមានគេដឹង អ្នកត្រូវជូនដំណឹងមកធនាគារភ្លាមៗដោយ៖

- បង្កកកាតរបស់អ្នកតាមរយៈសេវាធនាគារអនឡាញ (កម្មវិធី ABA Mobile) ឬ
- ទូរស័ព្ទទៅកាន់សេវាបម្រើអតិថិជនតាមរយៈប្រព័ន្ធឥតគិតថ្លៃ 1800 203 203 ឬលេខ (855) 98 203 203 (24 ម៉ោងក្នុងមួយថ្ងៃ និង 7 ថ្ងៃក្នុងមួយសប្តាហ៍) ឬ
- ទាក់ទងមកកាន់សាខាណាមួយរបស់ធនាគារ

ប្រសិនបើអ្នកបានជូនដំណឹងមកធនាគារតាមមធ្យោបាយផ្សេងក្រៅពីការអញ្ជើញមកផ្ទាល់ សូមអញ្ជើញមកសាខាធនាគារដែលនៅជិតអ្នកបំផុតដើម្បីបញ្ជាក់ពីការបាត់ ឬលេខសម្ងាត់ត្រូវបានគេដឹង។ អ្នកក៏ត្រូវបញ្ជាក់លម្អិតជាលាយលក្ខណ៍អក្សរអំពីការបាត់ ឬលេខកូដ PIN ត្រូវគេដឹងនោះមកកាន់ធនាគារក្នុងរយៈពេល 5 (ប្រាំ) ថ្ងៃ។

សម្រាប់ហេតុផលសុវត្ថិភាព ធនាគារមិនអាចចេញកាតថ្មីជំនួសឲ្យកាតដែលបានបាត់, ត្រូវបានគេលួច, ឬខូចបានឡើយ ខណៈដែលអ្នកស្ថិតនៅបរទេស។

4.5. ការប្រើប្រាស់កាតរបស់អ្នកនៅបរទេស

ការប្រើប្រាស់កាតរបស់អ្នកនៅក្រៅប្រទេសកម្ពុជា គឺអាស្រ័យលើលក្ខខណ្ឌគ្រប់គ្រងការប្តូរប្រាក់របស់ប្រទេសដែលអ្នកកំពុងប្រើប្រាស់កាត។ ការប្រើប្រាស់កាតរបស់អ្នកនៅបរទេសមិនធានាថា អាជ្ញាធរគយកម្ពុជានឹងអនុញ្ញាតឲ្យនាំយកទំនិញដែលទិញនោះចូលប្រទេសកម្ពុជាទេ។ សូមប្រឹក្សាជាមួយអាជ្ញាធរគយកម្ពុជា ប្រសិនបើអ្នកមានចម្ងល់ណាមួយអំពីផលិតផលដែលអាចនាំចូលប្រទេសកម្ពុជាបាន។

ចំនួនទឹកប្រាក់នៃប្រតិបត្តិការលើកាតដែលធ្វើឡើងនៅក្រៅប្រទេសកម្ពុជានឹងត្រូវប្តូរទៅជាប្រាក់ដុល្លារអាមេរិកក្នុងតម្លៃសមមូល។ ចំនួនទឹកប្រាក់សមមូលនោះនឹងត្រូវបានបង្ក/កាត់ចេញពីគណនីសន្សំ គណនីចរន្ត ឬគណនីកាតឥណទានរបស់អ្នក។ ថ្លៃប្តូររូបិយប័ណ្ណ នឹងត្រូវបានទូទាត់ និងបូកបន្ថែមទៅលើបន្ទុកនៃប្រតិបត្តិការរបស់អ្នក។

ការប្រើប្រាស់ម៉ាស៊ីន ATM មួយចំនួននៅបរទេសដែលមានបង្ហាញឡូហ្គោ Visa ឬ Mastercard អាចអនុវត្តបន្ទុកបន្ថែមនៅពេលដែលអ្នកប្រើប្រាស់។

អ្នកនឹងត្រូវគិតថ្លៃសេវាប្រតិបត្តិការសម្រាប់ការប្រើប្រាស់កាតរបស់អ្នកនៅបរទេស។ តម្លៃសេវា និងបន្ទុកទាំងនេះ មានលម្អិតនៅក្នុងខិត្តប័ណ្ណ "ថ្លៃសេវា" ដែលអាចរកបាននៅតាមសាខារបស់ធនាគារ ឬនៅលើគេហទំព័រផ្លូវការរបស់ធនាគារ។

4.6. ការទទួលខុសត្រូវរបស់អ្នកក្នុងការប្រើប្រាស់កាត

អ្នកនឹងមិនត្រូវទទួលរ៉ាប់រងសម្រាប់រាល់ការខាតបង់ដែលបង្ករឡើងដោយ៖

- ការក្លែងបន្លំ ឬការធ្វេសប្រហែសដោយបុគ្គលិកធនាគារ ឬភាគីដែលពាក់ព័ន្ធក្នុងការផ្តល់សេវាធនាគារអេឡិចត្រូនិច
- កំហុសដែលកើតឡើងនៅក្នុងម៉ាស៊ីន, កាត ឬប្រព័ន្ធដែលប្រើប្រាស់ លុះត្រាតែកំហុសនោះជាកំហុសជាក់ស្តែង ឬត្រូវបានជូនដំណឹងរួចហើយតាមរយៈសារ ឬសេចក្តីជូនដំណឹងដែលមានបង្ហាញនៅលើអេក្រង់
- ប្រតិបត្តិការគ្មានការអនុញ្ញាត ដែលកើតឡើងមុនពេលដែលអ្នកទទួលបានកាត ដែលក្នុងករណីនេះ ប្រសិនបើមានវិវាទ ធនាគារនឹងមិនធ្វើការវិនិច្ឆ័យដោយផ្អែកតែទៅលើកំស្តុតាងដែលបង្ហាញថា អ្នកបានទទួលបានកាតនោះឡើយ និង
- ប្រតិបត្តិការគ្មានការអនុញ្ញាតផ្សេងទៀត ដែលបង្ហាញយ៉ាងច្បាស់ថា អ្នកមិនបានរួមចំណែកធ្វើឲ្យមានការខាតបង់។

អ្នកត្រូវទទួលរ៉ាប់រងលើរាល់ការខាតបង់ទាំងឡាយណាដែលអ្នកបានធ្វើការក្លែងបន្លំ ទោះជាប្រព្រឹត្តម្នាក់ឯង ឬរួមគ្នាជាមួយអ្នកដទៃក៏ដោយ។ អ្នកអាចនឹងត្រូវទទួលរ៉ាប់រងលើរាល់ការខាតបង់ទាំងឡាយណាដែលកើតឡើងដោយសារការប្រតិបត្តិការគ្មានការអនុញ្ញាត ប្រសិនបើអ្នកមានចំណែក ឬបង្កឲ្យមានការខាតបង់នោះ ឧទាហរណ៍ដូចជា៖

- ការជ្រើសរើសលេខសម្ងាត់ (PIN) មិនសមស្រប
- មិនបានរក្សាការពារកាតរបស់អ្នកបានត្រឹមត្រូវ
- សរសេរលេខសម្ងាត់ (PIN) ទុកនៅកន្លែងណាមួយ
- ចែក និង/ឬប្រាប់លេខសម្ងាត់ (PIN) ដល់អ្នកដទៃ
- មិនបានចាត់វិធានការសមស្របដើម្បីកុំឲ្យអ្នកផ្សេងដឹងនៅពេលបញ្ចូលលេខសម្ងាត់ (PIN)
- យឺតយ៉ាវក្នុងការជូនដំណឹងមកធនាគារអំពីការបាត់កាត ឬត្រូវបានគេលួច ឬការដែលមានអ្នកផ្សេងដឹងលេខសម្ងាត់ (PIN)។

ប្រសិនបើអ្នកបានរាយការណ៍ភ្លាមៗអំពីការបាត់កាត ឬត្រូវបានលួច ឬការដែលមានអ្នកផ្សេងដឹងលេខសម្ងាត់ (PIN) នោះអ្នកនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ដែលកើតឡើង បន្ទាប់ពីការជូនដំណឹងនោះទេ លើកលែងតែអ្នកបានប្រព្រឹត្តការក្លែងបន្លំ ឬការធ្វេសប្រហែស។

ធនាគារនឹងមិនពាក់ព័ន្ធក្នុងវិវាទរវាងអ្នក និងអ្នកផ្សេងដែលអ្នកទូទាត់ជូន ឬព្យាយាមទូទាត់ទៅឲ្យ តាមរយៈអ៊ីនធឺណិតឡើយ។

ប្រសិនបើធនាគារព្យាយាមតាមលក្ខណៈណាមួយក្នុងការអនុវត្ត ឬការពារសិទ្ធិរបស់ខ្លួន ឬដោះស្រាយវិវាទណាមួយពាក់ព័ន្ធនឹងគណនី នោះអតិថិជនត្រូវទូទាត់ជូនធនាគារនូវការចំណាយ, ថ្លៃសេវា, និងបន្ទុកផ្សេងៗ ដូចជាកម្រៃផ្លូវច្បាប់ ហើយធនាគារមានសិទ្ធិក្នុងការកាត់ថ្លៃចំណាយទាំងនោះចេញពីគណនីរបស់អតិថិជនទៅតាមនោះដែរ។

5. របាយការណ៍ធនាគាររបស់អ្នក

5.1. តើត្រូវធ្វើដូចម្តេច ប្រសិនបើអ្នកចង់ជំទាស់នឹងប្រតិបត្តិការ?

ប្រសិនបើអ្នកត្រូវការជំទាស់នឹងប្រតិបត្តិការណាមួយ អ្នកអាចធ្វើការជំទាស់បានជាលាយលក្ខណ៍អក្សរឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសពី 90 (កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍ដែលមានកត់ត្រានៅលើប្រតិបត្តិការនោះ។ ក្នុងកាលៈទេសៈមួយចំនួន វិធានស្តីពីការប្រើប្រាស់កាត អនុញ្ញាតឲ្យយើងខ្ញុំដកទឹកប្រាក់ប្រតិបត្តិការត្រលប់ពីគណនីអាជីវករដែលអ្នកធ្វើប្រតិបត្តិការជាមួយនោះមកវិញ។ ប្រតិបត្តិការនេះ ត្រូវបានគេហៅថា ប្រតិបត្តិការបង្វិលប្រាក់ត្រលប់វិញ។ ប្រសិនបើអាចអនុវត្តបាន យើងខ្ញុំនឹងប្រើប្រាស់សិទ្ធិបង្វិលប្រាក់ត្រលប់វិញសម្រាប់ប្រតិបត្តិការនៅលើគណនីរបស់អ្នក ប្រសិនបើ៖

- អ្នកស្នើសុំឲ្យធនាគារធ្វើដូច្នេះ និង
- អ្នកផ្តល់ព័ត៌មាន និងឯកសារដែលធនាគារត្រូវការ ដើម្បីគាំទ្រដល់ប្រតិបត្តិការបង្វិលប្រាក់ត្រលប់វិញ ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទ របាយការណ៍ដែលប្រតិបត្តិការនោះបានកត់ត្រា។

បើមិនដូច្នេះទេ សិទ្ធិបង្វិលប្រាក់ត្រឡប់វិញដែលយើងខ្ញុំមាន អាចនឹងត្រូវបាត់បង់ ។ រយៈកាលសម្រាប់ជំទាស់នឹងប្រតិបត្តិការមិនអាចអនុវត្តបាន នៅពេលប្រើប្រាស់មុខងារ 3DS (សុវត្ថិភាព 3D) ។ លទ្ធភាពក្នុងការជំទាស់នឹងប្រតិបត្តិការអាចនឹងត្រូវបាត់បង់ ប្រសិនបើមិនបានរាយការណ៍មកធនាគារក្នុងរយៈពេលកំណត់នេះទេ ។

5.2. ការបញ្ជាក់ពីប្រតិបត្តិការ

នៅពេលដែលអ្នកប្រើប្រាស់កាតធនាគារ ABA (ប្រភេទ Visa, UPI និង/ឬ Mastercard ដែលចេញដោយធនាគារ ABA) នៅតាមម៉ាស៊ីនទូទាត់ POS និង/ឬតាមផ្លែតហ្វមពាណិជ្ជកម្មអេឡិកត្រូនិកណាមួយ វិក្កយបត្រប្រតិបត្តិការនោះនឹងត្រូវបានព្រីនចេញ ។ វិក្កយបត្រប្រតិបត្តិការនឹងបង្ហាញព័ត៌មានលម្អិតអំពីប្រតិបត្តិការរបស់អ្នក (ដូចជា ចំនួនទឹកប្រាក់ កាលបរិច្ឆេទ ។ល ។) ។ សូមរក្សាវិក្កយបត្រដែលបានព្រីនចេញនោះ ហើយផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍គណនីរបស់អ្នក ។

5.3. របាយការណ៍ធនាគារ

អ្នកគប្បីរក្សាទុកនូវសន្លឹកបត្រ វិក្កយបត្រ និងកំណត់ត្រាប្រតិបត្តិការដែលអ្នកទទួលបាននៅពេលប្រើកាតរបស់អ្នក ។ អ្នកអាចប្រើសន្លឹកបត្រ វិក្កយបត្រ និងកំណត់ត្រាប្រតិបត្តិការទាំងនេះ ដើម្បីផ្ទៀងផ្ទាត់ប្រតិបត្តិការលើគណនីរបស់អ្នក ។

ទោះបីមិនមានប្រតិបត្តិការនៅលើគណនីរបស់អ្នកអំឡុងពេលចេញរបាយការណ៍ (ដែលចេញនៅចុងខែនីមួយៗ) របាយការណ៍នោះនឹងចេញជាប្រចាំ ។ អ្នកអាចជ្រើសរើសការទទួលរបាយការណ៍របស់អ្នកកាន់តែញឹកញាប់ដោយអញ្ជើញទៅសាខា និង/ឬដោនឡូតរបាយការណ៍ពីសេវាធនាគារអនឡាញ ABA ។

ទោះបីមិនមែនជាកាតព្វកិច្ច ក៏ធនាគារអាចនឹងរំលឹកអ្នកដោយផ្ញើសារ SMS ទៅលេខទូរស័ព្ទដែលអ្នកបានចុះបញ្ជី ឬតាមការជូនដំណឹងតាមអ៊ីមែល អំពីរបាយការណ៍ជាក្រដាស ឬអេឡិកត្រូនិក ដែលអាចទទួល ឬដោនឡូតបាន ។ ប្រសិនបើអនុវត្ត ការជូនដំណឹងទាំងនេះជាកស្តុតាងបញ្ជាក់ថា ធនាគារមានផ្តល់របាយការណ៍គណនីជូនអ្នក ។

ដើម្បីការពារថវិកានៅក្នុងគណនីធនាគាររបស់អ្នក អ្នកត្រូវបានជូនដំណឹងអំពីការទទួលខុសត្រូវរបស់ខ្លួនក្នុងការអនុវត្តការផ្ទៀងផ្ទាត់របាយការណ៍គណនីរបស់អ្នកភ្លាម ៗ នៅពេលដែលរបាយការណ៍គណនីថ្មីបានចេញនៅរាល់ចុងខែ ។ នេះជាការទទួលខុសត្រូវរបស់អ្នកក្នុងការផ្ទៀងផ្ទាត់របាយការណ៍គណនីរបស់អ្នកភ្លាមៗនៅពេលដែលរបាយការណ៍គណនីថ្មីត្រូវបានចេញ ទោះបីធនាគារ ABA មិនផ្ញើការរំលឹកប្រចាំខែដល់អ្នកក៏ដោយ ។

ដើម្បីសម្រួលដល់ការផ្តល់របាយការណ៍គណនីប្រកបដោយប្រសិទ្ធភាព អ្នកគប្បីប្រើសេវាធនាគារអនឡាញ ABA ដើម្បីដោនឡូតរបាយការណ៍អេឡិកត្រូនិកយ៉ាងហោចណាស់ម្តងមួយខែដើម្បីឲ្យអ្នកអាចផ្ទៀងផ្ទាត់ជារៀងរាល់ខែ និងនៅពេលណាដែលអ្នកចង់ផ្ទៀងផ្ទាត់ ។

5.4. របាយការណ៍អេឡិកត្រូនិក

អ្នកយល់ច្បាស់ និងយល់ព្រមថា តាមរយៈការស្នើសុំផ្តល់របាយការណ៍អេឡិកត្រូនិក អ្នកនឹងមិនទទួលបានរបាយការណ៍ជាក្រដាសទេ ។ អ្នកយល់ព្រមថា ការផ្តល់របាយការណ៍អេឡិកត្រូនិកនឹងបំពេញតាមលក្ខខណ្ឌតម្រូវរបស់ធនាគារដើម្បីផ្តល់ជូនអ្នកនូវរបាយការណ៍ទៀងទាត់អំពីសកម្មភាពគណនីរបស់អ្នក ។ ដើម្បីទទួលបានរបាយការណ៍អេឡិកត្រូនិក អ្នកត្រូវដោនឡូតតាមរយៈកម្មវិធី ABA Mobile ឬសេវាធនាគារអនឡាញ ។ ក្រៅពីនេះ អ្នកត្រូវស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីទទួលបានរបាយការណ៍អេឡិកត្រូនិកផ្ញើទៅកាន់អាសយដ្ឋានអ៊ីមែលរបស់អ្នក ។ នេះជាការទទួលខុសត្រូវរបស់អ្នកក្នុងការជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរគ្រប់ពេលវេលា នៅពេលអ្នកផ្លាស់ប្តូរអាសយដ្ឋានអ៊ីមែល ឬប្រសិនបើអ្នកមានបំណងដកគណនីណាមួយពីការផ្តល់របាយការណ៍អេឡិកត្រូនិក ។ ដើម្បីជាកិច្ចការពារ និងសុវត្ថិភាពរបស់អ្នក ធនាគារនឹងមិនទទួលការផ្លាស់ប្តូរអាសយដ្ឋានអ៊ីមែលតាមរយៈទូរស័ព្ទ ឬអ៊ីមែលឡើយ ។

ទោះបីជាអ្នកបានស្នើសុំផ្តល់របាយការណ៍របស់អ្នកតាមអេឡិកត្រូនិក ក៏អ្នកប្រហែលអាចទទួលបានរបាយការណ៍គណនីរបស់អ្នកជាក្រដាសផងដែរ ។ អ្នកអាចទទួលរបាយការណ៍មួយច្បាប់ដោយទាក់ទងធនាគារតាមរយៈមធ្យោបាយផ្សេង ហើយស្នើសុំរបាយការណ៍របស់អ្នកមួយច្បាប់ ។ ធនាគារ អាចគិតថ្លៃសេវាក្នុងការព្រីនចេញនូវរបាយការណ៍គណនីរបស់អ្នក ។

ការជូនដំណឹងអំពីរបាយការណ៍អេឡិកត្រូនិកអាចត្រូវផ្ញើជូនអ្នកតាមអាសយដ្ឋានអ៊ីមែលមួយប៉ុណ្ណោះ ។ ឧទាហរណ៍ ការជូនដំណឹងមិនអាចផ្ញើទៅកាន់ម្ចាស់គណនីទាំងពីរនៃគណនីរួមឡើយ ។ ធនាគារមិនមានកាតព្វកិច្ច ឬការទទួលខុសត្រូវក្នុងការជូនដំណឹងដល់ភាគីផ្សេងណាមួយនៅលើគណនីឡើយ ប្រសិនបើអាសយដ្ឋានអ៊ីមែលត្រូវបានផ្លាស់ប្តូរដោយប្រើប្រាស់នីតិវិធីកំណត់ខាងលើ ។ អ្នកយល់ព្រមការពារការសម្ងាត់គណនី, លេខគណនី, ឈ្មោះចូលប្រើ, និងពាក្យសម្ងាត់របស់អ្នក ។ អ្នកយល់ព្រមថា នេះជាការទទួលខុសត្រូវរបស់អ្នកដើម្បីធានាថា របាយការណ៍អេឡិកត្រូនិកមិនមានអ្នកដទៃទទួល និងពិនិត្យមើល, និងធានាថា អ្នកបានចាកចេញ ឬបើកចេញពីគណនីនៅពេលអ្នកបញ្ចប់ប្រតិបត្តិការ ដើម្បីការពារការចូលប្រើប្រាស់គណនីរបស់អ្នកដោយគ្មានការអនុញ្ញាត ។ នេះជាទំនួលខុសត្រូវរបស់អ្នកក្នុងការទាក់ទងមកធនាគារ ប្រសិនបើអ្នកដឹង ឬសង្ស័យពីការប្រើប្រាស់ព័ត៌មានបញ្ជាក់ចូលប្រើគណនីរបស់អ្នកដោយគ្មានការអនុញ្ញាត ។

ធនាគារនឹងផ្តល់ជូនអ្នកនូវរបាយការណ៍អេឡិកត្រូនិករបស់គណនីឲ្យបានញឹកញាប់ ស្របតាមការស្នើសុំរបស់អ្នកតាមរយៈសេវាធនាគារអនឡាញ ABA ។ អ្នកអាចដោនឡូត និងចូលទៅមើលរបាយការណ៍របស់អ្នករហូតដល់ទៅប្រាំមួយ (6) ខែចុងក្រោយ ។

5.5. ចំណុចត្រូវចងចាំអំពីរបាយការណ៍

ត្រូវចាំថា ជាទូទៅ របាយការណ៍ជាផ្នែកដ៏សំខាន់មួយនៃសេវាធនាគារ និងហិរញ្ញវត្ថុរបស់អ្នក ។ សូមចងចាំថា ៖

- រាល់ទិន្នន័យទាំងអស់នៅលើរបាយការណ៍គួរតែពិនិត្យឲ្យបានល្អិតល្អន់ និងត្រូវរាយការណ៍មកធនាគារភ្លាមៗ ប្រសិនបើមានប្រតិបត្តិការដែលគ្មានការអនុញ្ញាតកើតមានឡើង ឬទំនងជាអាចកើតឡើង

- រាល់ប្រតិបត្តិការទាំងអស់នឹងបង្ហាញលើរបាយការណ៍គណនី ប៉ុន្តែសេចក្តីបរិយាយរបស់របាយការណ៍ នឹងមិនមានបញ្ជាក់អំពីអ្នកផ្តួចផ្តើមប្រតិបត្តិការឡើយ។
- អ្នកគួររក្សាទុកកំណត់ត្រាប្រតិបត្តិការ ឬលេខកំណត់ត្រាប្រតិបត្តិការដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងទិន្នន័យដែលមាននៅលើរបាយការណ៍គណនីរបស់អ្នក
- របាយការណ៍ទាំងនោះមិនអាចផ្ញើទៅឲ្យសាខាធនាគារដើម្បីរក្សាទុកបានឡើយ លុះត្រាតែមានករណីលើកលែង និង
- ធនាគារនឹងជួយដល់ការតវ៉ាទាមទារណាមួយដែលអ្នកអាចធ្វើឡើងទាក់ទងនឹងប្រតិបត្តិការធ្វើឡើងដោយមិនមានការអនុញ្ញាត រួមមានដូចជាការក្លែងបន្លំឯកសារ និងចំណុចមិនសមស្របផ្សេងៗទៀត ដូចជា ប្រសិនបើមានមូលប្បទានបត្រនៅលើរបាយការណ៍ដែលខាងធនាគារបានធ្វើការទូទាត់ប្រាក់ ប៉ុន្តែអ្នកមិនបានអនុញ្ញាត ឬប្រសិនបើមានចំនួនទឹកប្រាក់ណាមួយត្រូវបានកាត់ចេញពីគណនីរបស់អ្នកដោយគ្មានការអនុញ្ញាតពីអ្នក។

5.6. ការផ្ទៀងផ្ទាត់របាយការណ៍

អ្នកត្រូវផ្ទៀងផ្ទាត់របាយការណ៍ធនាគាររបស់អ្នក (របាយការណ៍ក្រដាស ឬរបាយការណ៍អេឡិកត្រូនិក) គ្រប់គណនីទាំងអស់របស់អ្នកឲ្យបានឆាប់ នៅពេលដែលអ្នកបានទទួល និងបានចូលទៅមើលរបាយការណ៍ទាំងនោះ ដោយមិនហួសរយៈពេល 30 (សាមសិប) ថ្ងៃចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍គណនីធនាគារ ដើម្បីធានាថា ទិន្នន័យដែលបានកត់ត្រានៅលើរបាយការណ៍នោះមានភាពត្រឹមត្រូវ និងធានាថា មិនមានប្រតិបត្តិការមិនត្រឹមត្រូវ, គួរឲ្យសង្ស័យ ឬគ្មានការអនុញ្ញាត ដោយសារអ្នកអាចរកឃើញប្រតិបត្តិការមិនត្រឹមត្រូវ, គួរឲ្យសង្ស័យ ឬគ្មានការអនុញ្ញាត។

អ្នកត្រូវជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 60 (ហុកសិប) ថ្ងៃ (ប៉ុន្តែមិនលើសពី 90 ថ្ងៃចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍គណនីធនាគារ) អំពីប្រតិបត្តិការមិនត្រឹមត្រូវ, គួរឲ្យសង្ស័យ ឬគ្មានការអនុញ្ញាតក្នុងរបាយការណ៍គណនីធនាគាររបស់អ្នក។ ការមិនបានអនុវត្តការប្រុងប្រយ័ត្ននឹងបង្កើតជាការធ្វេសប្រហែស ហើយអ្នកត្រូវទទួលរ៉ាប់រងចំពោះការខូចខាត ឬការខាតបង់របស់ធនាគារបង្ករឡើងដោយការធ្វេសប្រហែសរបស់អ្នក ហើយការធ្វេសប្រហែសនេះនឹងមិនអនុញ្ញាតឲ្យអ្នកប្តឹងទាមទារធនាគារនូវប្រតិបត្តិការគ្មានការអនុញ្ញាតណាមួយនៅលើគណនីរបស់អ្នកឡើយ។

ប្រសិនបើអ្នកមិនជូនដំណឹងមកធនាគារទេ ដូច្នេះ ផ្អែកតាមច្បាប់ជាធរមាន ៖

- អ្នកនឹងត្រូវបានចាត់ទុកថា ព្រមទទួលស្គាល់ ពីភាពត្រឹមត្រូវ និងស្របច្បាប់នៃ សមតុល្យគណនី និងប្រតិបត្តិការទាំងអស់នៅលើរបាយការណ៍ធនាគារ
- យើងខ្ញុំ មានសិទ្ធិពេញលេញក្នុងការការពារខ្លួនពីបណ្តឹងណាមួយរបស់អ្នកមកលើធនាគារ រួមមាន បណ្តឹងអំពីការរំលោភកិច្ចសន្យា, ការធ្វេសប្រហែស, កំហុសធ្ងន់ក្នុងការកាត់ទឹកប្រាក់ ឬកំហុសផ្សេងៗ, ដំណោះស្រាយសមធម៌ ឬសកម្មភាពផ្សេងៗទៀតប្រឆាំងនឹងធនាគារពាក់ព័ន្ធនឹងគណនីរបស់អ្នក ឬប្រតិបត្តិការនៅក្នុងរបាយការណ៍ធនាគារ។

5.7. ភាពមិនប្រក្រតី កំហុស ចម្ងល់ និងបណ្តឹង

សូមទាក់ទងមកសាខាដែលនៅជិតអ្នកបំផុត ផ្អែកទំនាក់ទំនង (ជាបណ្តាញដែលលើកទឹកចិត្តឲ្យប្រើជាងគេ) ភ្លាមៗ ប្រសិនបើ ៖

- អ្នកគិតថា មានភាពមិនប្រក្រតី/កំហុសនៅលើរបាយការណ៍របស់អ្នក
- មានបាត់ប្រាក់ដោយសារតែម៉ាស៊ីន ATM ឬកាត មិនដំណើរការត្រឹមត្រូវ
- អ្នកមានចម្ងល់ ឬបណ្តឹងណាមួយ

អ្នកនឹងត្រូវផ្តល់ជូនធនាគារនូវ ៖

- ឈ្មោះរបស់អ្នក
- លេខគណនីរបស់អ្នក
- លេខកាតរបស់អ្នក (ប្រសិនបើអាច) និង
- លេខកូដផ្ទៀងផ្ទាត់តាមទូរស័ព្ទរបស់អ្នកសម្រាប់ផ្ទៀងផ្ទាត់តាមទូរស័ព្ទ (ប្រសិនបើអាច)
- ព័ត៌មានលម្អិតអំពីកំហុស ឬការដំណើរការមិនត្រឹមត្រូវដែលគួរឲ្យសង្ស័យ ឬលក្ខណៈនៃបញ្ហា រួមមានចំនួនទឹកប្រាក់ពាក់ព័ន្ធ និងព័ត៌មានលម្អិតអំពីប្រតិបត្តិការ។

ធនាគារនឹងធ្វើការខិតខំប្រឹងប្រែងគ្រប់មធ្យោបាយ ដើម្បីឆ្លើយតប/ដោះស្រាយរាល់ចម្ងល់, បណ្តឹង, ឬវិវាទរបស់អ្នកឲ្យបានឆាប់រហ័ស និងយុត្តិធម៌។ នៅពេលដែលធនាគាររកឃើញថា កំហុសធ្ងន់ពិតជាកើតឡើងមែន នោះខ្លួននឹងកែតម្រូវកំហុសធ្ងន់នោះភ្លាមៗ (ទៅតាមកម្រិតដែលអាចធ្វើបាន) ព្រមទាំងសងរាល់ការប្រាក់ ឬថ្លៃសេវា

ផ្សេងៗដល់អ្នកវិញ ដែលបានកើតឡើងដោយសារតែកំហុសធ្ងន់នោះ។ ធនាគារនឹងកែសម្រួលកំហុសធ្ងន់នានា ដែលបានកត់ចូលទៅក្នុងរបាយការណ៍របស់អ្នក។

អ្នកទទួលស្គាល់ និងឯកភាពថា អាចមានកាលៈទេសៈខ្លះ ដែលការមិនពេញចិត្ត ឬវិវាទអាចកើតមានរវាងភាគីទាំងពីរ (អ្នក និងធនាគារ) ដែលជាការណ៍ធម្មតានៃការបម្រើសេវាទូទៅ។ អ្នកមានឆន្ទៈក្នុងការសហការជាមួយនឹងធនាគារ ហើយគោរពតាមនីតិវិធីរបស់ធនាគារ និងនីតិវិធីសម្រាប់ការដោះស្រាយបណ្តឹង។ ធនាគារបានបង្កើតផ្នែកមួយសម្រាប់ដោះស្រាយបណ្តឹង ហើយអ្នកគប្បីពិភាក្សាជាមួយផ្នែកនេះ នៅពេលអ្នកមិនពេញចិត្តនឹងការព្យាយាមដោះស្រាយវិវាទដំបូង។

ប្រសិនបើអ្នកនៅតែមិនពេញចិត្តបន្ទាប់ពីផ្នែកដោះស្រាយបណ្តឹងនេះបញ្ចប់ករណីរបស់អ្នក អ្នកអាចស្វែងរកជំនួយពីធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមយន្តការដោះស្រាយវិវាទរបស់ធនាគារជាតិ។ ធនាគារនឹងប្រើប្រាស់ភ័ស្តុតាងដែលទទួលបាន និងរកឃើញ អំឡុងពេលដំណើរការស្វែងរកការពិតជំបូង អំឡុងពេលដំណើរការដោះស្រាយបណ្តឹងជាមួយធនាគារជាតិនៃកម្ពុជា។

6. ការប្រើប្រាស់មូលប្បទានបត្រ

6.1. សន្លឹកមូលប្បទានបត្រ សៀវភៅមូលប្បទានបត្រ និងប័ណ្ណដាក់ប្រាក់

សន្លឹកមូលប្បទានបត្រនៅក្នុងសៀវភៅមូលប្បទានបត្រ ដែលផ្តល់ជូនអ្នក មានលេខគណនីរបស់អ្នកនៅលើសន្លឹកនីមួយៗ។ សន្លឹកមូលប្បទានបត្រទាំងនេះ អាចប្រើប្រាស់បានសម្រាប់ការដកប្រាក់ពីគណនីនោះតែប៉ុណ្ណោះ។ សៀវភៅមូលប្បទានបត្ររបស់អ្នកគួរត្រូវរក្សាទុកឲ្យមានសុវត្ថិភាពគ្រប់ពេលវេលាទាំងអស់។ រាល់ការបាត់សន្លឹកមូលប្បទានបត្រណាមួយ ឬការដកប្រាក់ដែលមានការអនុញ្ញាត អ្នកគួររាយការណ៍មកធនាគារឲ្យបានឆាប់តាមដែលអាចធ្វើបាន។

ប័ណ្ណដាក់ប្រាក់ ដែលមានលេខគណនី គឺប្រើសម្រាប់តែការដាក់ប្រាក់ចូលទៅក្នុងគណនីនោះប៉ុណ្ណោះ។ ប័ណ្ណដាក់ប្រាក់ និងសន្លឹកមូលប្បទានបត្រនៅតែជាទ្រព្យសម្បត្តិរបស់ធនាគារដដែល ទោះបីក្រោយពេលអ្នកទទួលបានឯកសារទាំងនោះក្តី ហើយឯកសារទាំងនោះត្រូវប្រគល់ជូនទៅឲ្យធនាគារវិញតាមការស្នើសុំ។

6.2. ការទទួលមូលប្បទានបត្រ

ធនាគារអាចបញ្ជូនមូលប្បទានបត្រ ឬឯកសារផ្សេងទៀតទៅកាន់ទីតាំងផ្សេងៗ ដើម្បីអតិថិជនទទួល ឬធ្វើប្រតិបត្តិការ ស្របតាមការអនុវត្តទូទៅរបស់ធនាគារ។ ធនាគារនឹងមិនទទួលខុសត្រូវលើការខាតបង់ ឬការខូចខាតនៅក្នុងការបញ្ជូនមូលប្បទានបត្រនេះឡើយលុះត្រាតែការខាតបង់ ឬការខូចខាតនោះបណ្តាលមកពីការធ្វេសប្រហែសរបស់ធនាគារ។

6.3. ការដាក់មូលប្បទានបត្រទៅគណនីធនាគារ ABA ដែលធ្វើឡើងនៅធនាគារផ្សេងក្រៅពី ABA

ប្រសិនបើមូលប្បទានបត្រត្រូវបានដាក់ទៅ ABA នៅធនាគារផ្សេង ក្រៅពី ABA នោះមូលប្បទានបត្រ ត្រូវចាត់ចែងទៅតាមមូលដ្ឋាន "សម្រាប់ការប្រមូលទូទាត់" ដែលមានន័យថា ABA នឹងរង់ចាំទឹកប្រាក់ ត្រូវផ្ទាត់ទាត់ជាមុនសិន មុនពេល ABA អាចបង្ហាញវត្តមានទឹកប្រាក់ក្នុងគណនី។

6.4. ការដាក់មូលប្បទានបត្រភាគីទីបី

ជាធម្មតា មូលប្បទានបត្រអាចត្រូវបានដាក់ចូលទៅក្នុងគណនីរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល (តទៅនេះ ហៅថា "បុគ្គល") ដែលមានឈ្មោះជាអត្ថាគាហកលើមូលប្បទានបត្រ (អ្នកបើកប្រាក់) មួយប៉ុណ្ណោះ។ ប្រសិនបើអ្នកកំពុងដាក់មូលប្បទានបត្រចូលទៅក្នុងគណនីរបស់អ្នក ក្នុងករណីដែលអ្នកមិនមែនជាបុគ្គល (ពោលគឺអ្នកជា "ភាគីទីបី") សូមប្រាកដថា អត្ថាគាហក បានផ្ទេរភាពជាម្ចាស់កម្មសិទ្ធិមកឲ្យអ្នកតាមរយៈការចុះហត្ថលេខាលើខ្នងមូលប្បទានបត្រ ទៅតាមលក្ខណៈដូចខាងក្រោម៖

សូមទូទាត់ជូន (ឈ្មោះគណនីរបស់អ្នក)

ហត្ថលេខា (ហត្ថលេខារបស់អត្ថាគាហក)

លើសពីនេះទៅទៀត នៅពេលដែលអ្នកដាក់មូលប្បទានបត្រ យើងខ្ញុំនឹងសួរអ្នកថាតើអ្នកទទួលបានមូលប្បទានបត្រតាមវិធីណា។ ការសួរបែបនេះ គឺដើម្បីបញ្ជាក់ពីភាពជាម្ចាស់លើមូលប្បទានបត្រ ហើយចៀសវាងបញ្ហាដែល អាចនឹងកើតមានចំពោះមូលប្បទានបត្រដែលបាត់ ឬលួចផងដែរ។ ប្រសិនបើមូលប្បទានបត្រមិនមានការចុះហត្ថលេខាឲ្យបានត្រឹមត្រូវមុននឹងប្រគល់មកឲ្យអ្នក ឬប្រសិនបើមិនមានសេចក្តីពន្យល់ណាមួយត្រឹមត្រូវអំពីមូលហេតុដែលអ្នកទទួលបានមូលប្បទានបត្រនោះទេ នោះយើងខ្ញុំនឹងបដិសេធការដាក់មូលប្បទានបត្រនោះ។

6.5. ការដកប្រាក់ចេញពីមូលប្បទានបត្រដែលបានដាក់ប្រាក់

ជាធម្មតា អ្នកនឹងមិនអាចដកចេញនូវចំនួនទឹកប្រាក់ណាមួយនៃមូលប្បទានបត្រដែលអ្នកបានដាក់ រហូតទាល់តែមូលប្បទានបត្រនោះត្រូវបានផ្ទាត់ទាត់រួចរាល់ បើទោះបីជាគណនីរបស់អ្នកអាចនឹងត្រូវបានបញ្ចូលទឹកប្រាក់តាមចំនួនទឹកប្រាក់របស់មូលប្បទានបត្រក្តី។ វិធាននេះក៏ត្រូវបានអនុវត្តផងដែរចំពោះមូលប្បទានបត្រដែលអាចទូទាត់ "ជាសាច់ប្រាក់"។ ក្នុងករណីខ្លះ ការដកប្រាក់អាចត្រូវបានអនុញ្ញាតឆាប់ជាងនេះ។ ការអនុញ្ញាតនេះគឺធ្វើឡើងទៅតាមឆន្ទានុសិទ្ធិរបស់យើងខ្ញុំតែមួយប៉ុណ្ណោះ ហើយអ្នកគួរទាក់ទងទៅសាខាពាក់ព័ន្ធនឹងប្រតិបត្តិការនេះ។ នៅពេលការដកប្រាក់ត្រូវបានធ្វើឡើងមុនពេលដែលមូលប្បទានបត្រដែលបានដាក់ប្រាក់ត្រូវបានផ្ទាត់ទាត់ អ្នកនឹងត្រូវសងមកយើងខ្ញុំវិញ ប្រសិនបើមូលប្បទានបត្រនោះត្រូវបានបដិសេធ ហើយសម្រាប់តម្លៃសេវា និងបន្ទុកផ្សេងៗទៀតក៏អាចត្រូវទូទាត់ផងដែរ។

6.6. របៀបប្រើប្រាស់ប្រាក់មូលប្បទានបត្របានឆាប់

ពេលខ្លះ មូលប្បទានបត្រដែលមានសុពលភាព អាចត្រូវបានផ្ទាត់ទាត់នៅថ្ងៃដែលមូលប្បទានបត្រនោះត្រូវបានដាក់មកធនាគារ ប្រសិនបើអ្នកមានឆន្ទៈទូទាត់ថ្លៃសេវាដែលហៅថា "ការផ្ទាត់ទាត់ពិសេស" ដោយមានការកាត់បន្ថយពេលវេលាខ្លះ ដែលធនាគារបានកំណត់។ មូលប្បទានបត្រនឹងត្រូវបានផ្ទាត់ទាត់ ដើម្បីឲ្យអ្នកអាចដកទឹកប្រាក់នោះបាន នៅពេលដែលមូលប្បទានបត្រនោះត្រូវបានទូទាត់ដោយធនាគារផ្សេងទៀត។

6.7. ចំណុចដែលអ្នកគួរដឹងអំពីការសរសេរមូលប្បទានបត្រ

- សៀវភៅមូលប្បទានបត្រ ដែលបានចេញប្រើសម្រាប់គណនីមួយ (ប្រសិនបើមាន) នឹងត្រូវដាក់ឈ្មោះរបស់ម្ចាស់គណនី។ អ្នកគួរការពារសៀវភៅមូលប្ប ទានបត្ររបស់អ្នកឲ្យបានសមស្រប
- មិនអាចផ្ញើសៀវភៅមូលប្បទានបត្រ តាមប្រៃសណីយ៍ទៅតាមអាសយដ្ឋានសំបុត្ររបស់ម្ចាស់គណនីបានឡើយ លុះត្រាតែមានការរៀបចំផ្សេង ហើយ អាស្រ័យលើឆន្ទានុសិទ្ធិរបស់ធនាគារក្នុងការពិចារណាលើសំណើបែបនេះ ឬអត់
- សៀវភៅមូលប្បទានបត្រ អាចនឹងផ្ញើរទៅឲ្យសាខារបស់ធនាគារ ABA ដើម្បីឲ្យអ្នកមកទទួលក្រោយពេលមានការរៀបចំរួច។ តម្លៃសេវា និងបន្ទុកជាក់លាក់ មួយចំនួន អាចនឹងត្រូវបានកំណត់ដោយធនាគារផងដែរ។ អ្នកក៏ឯកភាពផងដែរថា ការដឹកបញ្ជូនសៀវភៅមូលប្បទានបត្រអាចនឹងត្រូវពន្យាពេល ប្រសិនបើមូលប្បទានបត្រនោះត្រូវបានបញ្ជូនទៅសាខា ដើម្បីឲ្យអតិថិជនមកយក។

6.8. ប្រភេទមូលប្បទានបត្រ

មូលប្បទានបត្រផ្ទាល់ខ្លួន	▪ មូលប្បទានបត្រទាំងនេះអាចប្រើបានចំពោះគណនីដែលមានតម្រូវការសេវាធនាគារប្រចាំថ្ងៃ។ មូលប្ប ទានបត្រត្រូវបានចេញតាមគណនីរបស់អ្នក ហើយត្រូវបានរៀបចំដោយអ្នកផ្ទាល់។ ▪ សៀវភៅមូលប្បទានបត្រក៏អាចស្នើ តាមរយៈការអញ្ជើញទៅកាន់សាខាណាមួយផ្ទាល់ ឬស្នើបើកតាម សេវាធនាគារអេនឡាញ។
មូលប្បទានបត្រចំហ ឬមិនធ្ងូត	▪ មូលប្បទានបត្រចំហ ជាមូលប្បទានបត្រដែលមិនមានធ្ងូត ពោលគឺជាមូលប្បទានបត្រដែលមិនមាន បន្ទាត់ស្របពីរនៅលើនោះទេ។ វាជាសំណើរបស់អ្នកមកកាន់យើងខ្ញុំឲ្យធ្វើការទូទាត់ទៅនរណាម្នាក់ ដែលបង្ហាញមូលប្បទានបត្រនេះ (ដោយសន្មតថា មូលប្បទានបត្រនោះជា មូលប្បទានបត្ររបស់ " អ្នកកាន់") មកកាន់សាខារបស់យើងខ្ញុំ ដែលមានរក្សាទុកគណនីរបស់អ្នកចេញមូលប្បទានបត្រ ហើយ មិនមែនជាមូលប្បទានបត្រដែលតម្រូវឲ្យមានការដាក់ប្រាក់ចូលទៅក្នុងគណនីនោះឡើយ។ ▪ ប្រសិនបើមូលប្បទានបត្របានបាត់ ហើយត្រូវបានយកមកទូទាត់ដោយបុគ្គលដែលរើសបានមូល ប្បទានបត្រនោះ ជាធម្មតា យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះការទូទាត់ ឬបញ្ចេញប្រាក់ទៅឲ្យអ្នក ដកប្រាក់នោះឡើយ។ គ្រប់ពេល អ្នកគួរផ្តល់ចំណាងឲ្យច្បាស់លាស់នៅលើមូលប្បទានបត្រនោះ។
មូលប្បទានបត្រធ្ងូត	▪ នៅពេលដែលអ្នក "ធ្ងូត" មូលប្បទានបត្រដោយបន្ទាត់ស្របពីរ នៅផ្នែកខាងលើ និងជ្រុងខាងឆ្វេងរបស់ មូលប្បទានបត្រ នោះមានន័យថា មូលប្បទានបត្រនោះត្រូវតែមានការដាក់ប្រាក់ចូលទៅក្នុងគណនីជា មុនសិន។ មូលប្បទានបត្រនោះមិនអាចដកជាសាច់ប្រាក់ផ្ទាល់បានឡើយ។
មូលប្បទានបត្រមិនអាចផ្ញើរបាន ឬ មូលប្បទានបត្រសម្រាប់តែគណនី អត្តាគាហក	▪ នេះមានន័យថា មូលប្បទានបត្រនេះមិនអាចផ្ញើរ ឬប្រគល់ទៅឲ្យអ្នកផ្សេងបានឡើយ ហើយអាច ត្រឹមតែទូទាត់ទៅកាន់គណនីធនាគារដែលមានឈ្មោះដូចមានចារលើមូលប្បទានបត្រក្នុងនាមជា អត្តាគាហកប៉ុណ្ណោះ។ មូលប្បទានបត្រនោះមិនអាចដកជាសាច់ប្រាក់ផ្ទាល់បានឡើយ។
មូលប្បទានបត្រ "មិនអាចចរចាបាន"	▪ មូលប្បទានបត្រគឺជាឧបករណ៍ដែលអាចចរចាបាន ពោលគឺវាអាចបញ្ជូនពីមនុស្សម្នាក់ទៅ មនុស្ស ម្នាក់ទៀត។ ▪ មូលប្បទានបត្រធ្ងូត ដែលមាន ឬគ្មានពាក្យថា "មិនអាចចរចាបាន" ដែលសរសេរនៅចន្លោះបន្ទាត់គូស នោះ អាចជួយការពារដល់ "ម្ចាស់មូលប្បទានបត្រពិតប្រាកដ" ក្នុងករណីដែលមូលប្បទានបត្រត្រូវបាន គេលួច ឬបាត់។
មូលប្បទានបត្រ "ឬអ្នកកាន់"	▪ ប្រសិនបើពាក្យថា "ឬអ្នកកាន់" មានបង្ហាញនៅខាងចុងបន្ទាត់ ដែលអ្នកបានសរសេរឈ្មោះអត្តាគាហក ហើយអ្នកមិនធ្ងូតលើមូលប្បទានបត្រនោះ ហើយគ្មានពាក្យថា "មិនអាចចរចាបាន" នៅលើមូលប្ប ទានបត្រនោះទេ យើងខ្ញុំនឹងទូទាត់ទឹកប្រាក់ទៅឲ្យបុគ្គលរូបណាដែល បង្ហាញមូលប្បទានបត្រនោះមក យើងខ្ញុំ។ ▪ នៅលើមូលប្បទានបត្រមិនធ្ងូត ប្រសិនបើអ្នកធ្ងូតលើពាក្យថា "ឬអ្នកកាន់" ហើយមូលប្បទានបត្រ ត្រូវ បានយកមកបើកជាសាច់ប្រាក់ នោះយើងខ្ញុំនឹងត្រូវទូទាត់សាច់ប្រាក់ទៅឲ្យតែបុគ្គលដែលមានឈ្មោះ នៅលើមូលប្បទានបត្រនោះ ឬតាមសំណើបុគ្គលនោះប៉ុណ្ណោះ។

6.9. មូលប្បទានដែលត្រូវបានបដិសេធ

ប្រសិនបើមូលប្បទានបត្រត្រូវបានបង្ហិលមកធនាគារដោយមិនបានទូទាត់ មានន័យថា មូលប្បទានបត្រនោះត្រូវបានបដិសេធដោយធនាគារ ដែលបើកមូលប្បទានបត្រនោះជូនអ្នក។ ប្រសិនបើករណីនេះកើតឡើង យើងខ្ញុំនឹងប្រគល់មូលប្បទានបត្រនេះត្រលប់ទៅឲ្យអ្នកវិញ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏នឹងបង្វែរទិន្នន័យដែលបញ្ចូលក្នុងគណនីរបស់អ្នកត្រលប់វិញ ពោលគឺ ដកចំនួនទឹកប្រាក់ដែលយើងខ្ញុំបានដាក់ចូលនោះមកវិញ។ ប្រសិនបើមូលប្បទានបត្រដែលអ្នកបានដាក់មិនអាចទូទាត់បានទេនោះ អ្នកមានទំនួលខុសត្រូវក្នុងការទាមទារការទូទាត់ពីបុគ្គលដែលចេញមូលប្បទានបត្រនោះ។ មូលប្បទានបត្រអាចនឹងត្រូវបានបដិសេធ ប្រសិនបើពុំមានទឹកប្រាក់គ្រប់គ្រាន់នៅក្នុងគណនីរបស់បុគ្គលចេញមូលប្បទានបត្រនោះ ឬមានភាពមិនប្រក្រតីមួយចំនួនពាក់ព័ន្ធនឹងមូលប្បទានបត្រនោះ។

6.10. ហេតុអ្វីបានជាមូលប្បទានបត្រអាចត្រូវបដិសេធ?

មានមូលហេតុមួយចំនួនដែលមូលប្បទានបត្រអាចត្រូវបានបដិសេធ ហើយហេតុផលមួយចំនួន អាចជា៖:

- ពុំមានទឹកប្រាក់គ្រប់គ្រាន់នៅក្នុងគណនីរបស់អ្នកចេញមូលប្បទានបត្រ (បុគ្គលដែលបានចុះហត្ថលេខាលើមូលប្បទានបត្រ) ដើម្បីផ្គត់ផ្គង់ទឹកប្រាក់គ្រប់ចំនួនដែលបានសរសេរនៅលើមូលប្បទានបត្រនោះ
- មូលប្បទានបត្រមិនមានចុះហត្ថលេខា ហត្ថលេខាមិនមានសុពលភាព ឬតម្រូវឲ្យមានហត្ថលេខាលើសពីមួយ
- មូលប្បទានបត្រត្រូវបាន "បញ្ឈប់" ដោយអ្នកចេញ (សូមមើល ផ្នែក "ការបញ្ឈប់ការទូទាត់" សម្រាប់ព័ត៌មានបន្ថែម ស្តីពី "ការបញ្ឈប់" មូលប្បទានបត្រ និងថ្លៃសេវាពាក់ព័ន្ធ)
- មូលប្បទានបត្រទុកយូរពេក - យកមកទូទាត់លើសពី 6 (ប្រាំមួយខែ) ក្រោយពេលកាលបរិច្ឆេទដែលមានសរសេរនៅលើនោះ (បើទោះបីជាធនាគារអាចជំណើរការទូទាត់ក្តី)
- មូលប្បទានបត្រត្រូវបានកែ ដោយពុំមានការចុះហត្ថលេខា ឬផ្តល់ចំណារ ឲ្យបានត្រឹមត្រូវ។

អ្នកត្រូវបានគិតថ្លៃសេវាសម្រាប់គ្រប់មូលប្បទានបត្រដែលអ្នកចេញ ហើយត្រូវបានបដិសេធ (ដែលត្រូវបានគេហៅថា "ការបដិសេធមិនបញ្ជូញ")។ តម្លៃសេវាមានរៀបរាប់លម្អិតនៅក្នុងខិត្តប័ណ្ណ "តម្លៃសេវា" ខនិងលក្ខខណ្ឌសម្រាប់ផលិតផល/សេវាណាមួយ និង/ឬលើវិបសាយរបស់យើងខ្ញុំ។ ប្រសិនបើអ្នកដាក់មូលប្បទានបត្រដែលអ្នកទទួលបានពីនរណាម្នាក់ ហើយមូលប្បទានបត្រនោះត្រូវបានបដិសេធ (ដែលត្រូវបានគេហៅថា "ការបដិសេធមិនទទួល") នោះអ្នកនឹងមិនត្រូវបង់តម្លៃសេវាឡើយ។ ប្រសិនបើមូលប្បទានបត្រមិនត្រូវបានផ្ទាត់ទាត់ទេ នោះទិន្នន័យនឹងត្រូវបានកែតម្រូវឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

នៅពេលមូលប្បទានបត្រដែលដាក់ចូលទៅក្នុងគណនីរបស់អ្នក ត្រូវបានបដិសេធ នោះចំនួនទឹកប្រាក់ដាក់ ត្រូវបានបង្វែរ (កាត់ចេញ) ពីគណនីរបស់អ្នក។ មូលប្បទានបត្រនឹងត្រូវបានបដិសេធនៅក្នុងថ្ងៃតែមួយ ឬយ៉ាងហោចណាស់ក្នុងរយៈពេល 2 (ពីរ)ថ្ងៃធ្វើការ បន្ទាប់ពីមូលប្បទានបត្រនោះត្រូវបានដំណើរការទូទាត់នៅសភាផ្ទាត់ទាត់។

6.11. មូលប្បទានបត្រទូទាត់ពេលក្រោយ

មូលប្បទានបត្រទូទាត់ពេលក្រោយ មានន័យថា មូលប្បទានបត្រដែលត្រូវបានចុះកាលបរិច្ឆេទប្រតិបត្តិនៅថ្ងៃខាងមុខ។ ធនាគារជាតិនៃកម្ពុជា (NBC) តម្រូវឲ្យមូលប្បទានបត្រទូទាត់ពេលក្រោយ ត្រូវតែធ្វើការផ្ទាត់ទាត់ ដោយមិនគិតថា មូលប្បទានបត្រត្រូវបានយកមកធ្វើប្រតិបត្តិការមុន ឬនៅកាលបរិច្ឆេទកំណត់ ឬនៅក្រោយកាលបរិច្ឆេទដែលបានសរសេរនៅលើមូលប្បទានបត្រនោះឡើយ។ ធនាគារសូមណែនាំយ៉ាងទទូច ឲ្យអ្នកយកមូលប្បទានបត្រទៅទូទាត់នៅក្រោយថ្ងៃបរិច្ឆេទកំណត់។

6.12. ការកែប្រែលើមូលប្បទានបត្រ

ប្រសិនបើអ្នកត្រូវការកែប្រើលើមូលប្បទានបត្រ ហត្ថលេខីត្រូវចុះហត្ថលេខាពេញលេញនៅជាប់កន្លែងកែប្រែនោះ។ ការកែប្រែដែលត្រូវបានអនុញ្ញាត រួមមាន ការបង្កើន/បន្ថយចំនួនទឹកប្រាក់, ការកែប្រែកាលបរិច្ឆេទ, និង/ឬឈ្មោះអត្ថាគាហកមូលប្បទានបត្រ។ ប្រសិនបើការកែប្រែនោះ មិនត្រូវបានចុះហត្ថលេខាបញ្ជាក់ទេ មូលប្បទានបត្ររបស់អ្នកអាចនឹងត្រូវបានបដិសេធ។

6.13. មូលប្បទានបត្រទុកយូរ

មូលប្បទានបត្រដែលយកមកទូទាត់នោះមានអាយុកាលច្រើនជាងប្រាំមួយខែ គិតចាប់ពីកាលបរិច្ឆេទចុះលើមូលប្បទានបត្រ អាចត្រូវបានបដិសេធដោយហេតុផលថាជា "មូលប្បទានបត្រទុកយូរ"។

6.14. ការបញ្ជាក់មូលប្បទានបត្រមុនពេលទូទាត់

ទោះមិនស្ថិតក្រោមកាតព្វកិច្ចរបស់ខ្លួនក៏ដោយ ក៏ធនាគារអាចទាក់ទងម្ចាស់គណនី ឬ ហត្ថលេខីនៃគណនី ដើម្បីបញ្ជាក់ពីការទទួលដឹងឮពីសំណាក់ម្ចាស់គណនីជាមុនសិន មុនធ្វើការដកប្រាក់សម្រាប់មូលប្បទានបត្រដែលត្រូវបានយកមកដកប្រាក់។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារ នឹងបង្កើតកម្រិតកំណត់សម្រាប់ការបញ្ជាក់មូលប្បទានបត្រ។ ធនាគារ ក៏អាចនឹងធ្វើការកែប្រែកម្រិតកំណត់ជាប្រចាំផងដែរ ផ្អែកលើសំណើសុំសមហេតុផលពីអតិថិជន ដែលជាផ្នែកមួយនៃសេវាបំពេញបន្ថែមរបស់ធនាគារ។ ច្បាប់ជាធរមាន មិនតម្រូវឲ្យធនាគារ ទទួលការបញ្ជាក់ពីអ្នកចេញមូលប្បទានបត្រ (អ្នកទូទាត់) ឡើយ នៅពេលទទួលមូលប្បទានបត្រដើម្បីធ្វើការផ្ទាត់ទាត់ឡើយ។

ធនាគារ នឹងមិនទទួលខុសត្រូវ សម្រាប់ការណ៍ដែលមិនបានទទួលការបញ្ជាក់ជាមុនពីម្ចាស់គណនី (ព្រោះថា ការទទួលការបញ្ជាក់បែបនេះ មិនស្ថិតក្រោមច្បាប់ជាធរមានទេ) លើកលែងតែ ការខាតបង់ណាមួយ ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ធនាគារទាំងស្រុង។ ប្រសិនបើអតិថិជន មិនចង់ឲ្យធនាគារ ទាក់ទង ដើម្បីបញ្ជាក់ទេនោះ យើងខ្ញុំសូមផ្តល់យោបល់ឲ្យអ្នក ពិភាក្សាជាមួយ ប្រធានទំនាក់ទំនងអតិថិជន ដើម្បីរកមធ្យោបាយល្អប្រសើរក្នុងការគោរមជានប្រតិបត្តិការគណនីរបស់អ្នក (ឧទាហរណ៍ ចុះឈ្មោះប្រើប្រាស់សេវាធនាគារអេនឡាញ) ហើយអញ្ជើញមកកាន់សាខាធនាគារយើងខ្ញុំ ដើម្បីបំពេញពាក្យ "ស្នើសុំបញ្ឈប់ការទាក់ទងបញ្ជាក់ការទូទាត់មូលប្បទានបត្រ។"

6.15. មូលប្បទានបត្រធនាគារិក

មូលប្បទានបត្រធនាគារិក ដែលចេញដោយធនាគារផ្ទាល់ ត្រូវបានទទួលយកយ៉ាងទូលំទូលាយ ធ្វើជាមធ្យោបាយទូទាត់ដែលមានសុវត្ថិភាព ហើយក៏ជាវិធីដែលមានសុវត្ថិភាពជំនួសឲ្យការកាន់សាច់ប្រាក់ក្នុងដៃក្នុងចំនួនច្រើនផងដែរ។

6.16. ការទទួលបានមូលប្បទានបត្រធនាគារិក

មូលប្បទានបត្រធនាគារិកអាចរកជាវបាននៅតាមសាខានានារបស់ធនាគារ ឬតាមរយៈសេវាធនាគារអេនឡាញ។ អ្នកអាចទូទាត់មូលប្បទានបត្រធនាគារិក និងថ្លៃសេវាផ្សេងៗ ដោយធ្វើការកាត់ប្រាក់ចេញពីគណនីរបស់អ្នក។ តម្លៃសេវាសម្រាប់មូលប្បទានបត្រធនាគារិកដែលបានជាវតាមសេវាធនាគារអេនឡាញ នឹងត្រូវកាត់ចេញពីគណនីរបស់អ្នក ឬកជាមួយនឹងតម្លៃរបស់មូលប្បទានបត្រធនាគារិកដែលអ្នកបានជាវ។

6.17. ចំណុចគួរចងចាំអំពីមូលប្បទានបត្រធនាគារិក

មូលប្បទានបត្រធនាគារិក ត្រូវតែផ្ទាត់ទាត់ដូចគ្នានឹងមូលប្បទានបត្រផ្សេង ហើយអាចនឹងត្រូវបានបដិសេធក្នុងហេតុផលដូចគ្នានឹងមូលប្បទានបត្របុគ្គលដែរ។ ប្រសិនបើមូលប្បទានបត្រធនាគារិកដែលអ្នកបានជាវមានការបាត់បង់, ត្រូវបានគេលួច, ឬបំផ្លាញ សូមទាក់ទងសាខាណាមួយរបស់យើងខ្ញុំភ្លាមៗ ដោយភ្ជាប់មកជាមួយនូវប័ណ្ណ ឬបង្កាន់ដៃជាវមូលប្បទានបត្រធនាគារិកច្បាប់ដើម។ ការចេញមូលប្បទានបត្រធនាគារិកថ្មីជំនួសឲ្យមូលប្បទានបត្រចាស់ គឺមានការគិតតម្លៃសេវា។

ប្រសិនបើលែងត្រូវការមូលប្បទានបត្រធនាគារិកហើយ អ្នកជាវ អាចបញ្ឈប់ ហើយស្នើសុំដូរយកប្រាក់វិញនៅតាមសាខាណាមួយក៏បាន។ អ្នកត្រូវប្រគល់មូលប្បទានបត្រធនាគារិក និងប័ណ្ណ ឬបង្កាន់ដៃជាវច្បាប់ដើមមកឲ្យធនាគារវិញ នៅពេលដែលស្នើសុំដូរយកប្រាក់។ ធនាគារ អាចគិតតម្លៃសេវាសម្រាប់សំណើដូរយកប្រាក់វិញនេះផងដែរ។

6.18. ការបញ្ឈប់ការទូទាត់

ប្រសិនបើចាំបាច់ មូលប្បទានបត្រដែលអ្នកបានសរសេរ ក៏អាចបញ្ឈប់បានផងដែរ។ អ្នកនឹងត្រូវជូនដំណឹងដល់ធនាគារឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន អំពីបំណងរបស់អ្នកក្នុងការបញ្ឈប់មូលប្បទានបត្រនោះ។ ធនាគារនឹងសុំឲ្យអ្នកផ្តល់ព័ត៌មានលម្អិតមួយចំនួនអំពីមូលប្បទានបត្រ, បុគ្គលដែលបានទទួល, ចំនួនទឹកប្រាក់ និងកាលបរិច្ឆេទ និងមូលហេតុនៃការបញ្ឈប់។

ស្រដៀងគ្នានេះដែរ ប្រសិនបើសៀវភៅមូលប្បទានបត្ររបស់អ្នកត្រូវបានគេលួច បាត់ ឬខ្ជេចអ្នកត្រូវជូនដំណឹងនេះដល់ធនាគារឲ្យបានឆាប់តាមដែលអាចធ្វើបាន អំពីគោលបំណងរបស់អ្នកក្នុងការបញ្ឈប់មូលប្បទានបត្រដែលនៅសល់នោះ។ ធនាគារនឹងតម្រូវឲ្យអ្នកប្រាប់អំពីលេខមូលប្បទានបត្រដែលត្រូវបានគេលួច ឬបាត់។

អ្នកត្រូវអញ្ជើញទៅកាន់សាខាធនាគារ ដើម្បីបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទ "សំណើបញ្ឈប់ការទូទាត់"។ ប្រសិនបើមូលប្បទានបត្រ មិនទាន់ត្រូវបានយកទៅដកប្រាក់ ឬទូទាត់ទេនោះ ធនាគារនឹងខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាពដើម្បីធានាថា នឹងមិនមានការទូទាត់លើមូលប្បទានបត្ររបស់អ្នកឡើយ។ ទោះជាយ៉ាងណា ធនាគារនឹងមិនទទួលខុសត្រូវឡើយ សម្រាប់ការទូទាត់លើមូលប្បទានបត្រណា ដែលមិនត្រូវបានបញ្ឈប់។ តម្លៃសេវាបញ្ឈប់មូលប្បទានបត្រ នឹងត្រូវអនុវត្តផងដែរ។ ថ្លៃសេវានេះ មានរៀបរាប់លម្អិតនៅក្នុងខិត្តប័ណ្ណ "តម្លៃសេវាកម្ម" ខ និងលក្ខខណ្ឌសម្រាប់ផលិតផល/សេវាណាមួយ និង/ឬនៅលើវិបសាយរបស់យើងខ្ញុំ។

ផ្នែកនេះរៀបរាប់អំពីវិធីបញ្ឈប់ប្រភេទនៃការទូទាត់មួយចំនួនចេញពីគណនីរបស់អ្នក។

ចន្លោះខាងក្រោមនេះ ត្រូវបានរក្សាទុកឲ្យនៅទំនេរ។
សូមបន្តទៅទំព័របន្ទាប់។

បញ្ឈប់ការទូទាត់មូលប្បទានបត្រ	បញ្ឈប់ការទូទាត់តាមពេលវេលា ឬការផ្ទេរប្រាក់ជាប្រចាំ	បញ្ឈប់ការកាត់ទឹកប្រាក់ដោយផ្ទាល់ ឬការទូទាត់ជាប្រចាំ	
ប្រសិនបើអ្នកចង់បញ្ឈប់ការទូទាត់តាមមូលប្បទានបត្រ អ្នកអាចធ្វើបាន ប្រសិនបើអ្នកជូនដំណឹងមកដល់យើងខ្ញុំ មុនពេលការទូទាត់ត្រូវបានធ្វើឡើង។ អ្នកត្រូវទាក់ទងមកមជ្ឈមណ្ឌលព័ត៌មានរបស់យើងខ្ញុំ និងដាក់សំណើជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា (ក្នុងទម្រង់បែបបទស្តង់ដាររបស់ ABA)។ ការបញ្ឈប់មូលប្បទានបត្រគឺត្រូវគិតថ្លៃសេវា ប៉ុន្តែការគិតតម្លៃសេវានេះ នឹងមិនត្រូវអនុវត្តឡើយប្រសិនបើសៀវភៅមូលប្បទានបត្ររបស់អ្នកបានបាត់, ត្រូវបានគេលួច ឬបំផ្លាញ ឬប្រសិនបើសៀវភៅមូលប្បទានបត្រលែងត្រូវការទៀត ហើយមូលប្បទានបត្រមិនទាន់ចុះហត្ថលេខា។	ប្រសិនបើអ្នកបានផ្តល់សិទ្ធិឲ្យយើងខ្ញុំធ្វើការទូទាត់ដោយស្វ័យប្រវត្តិជាប្រចាំ ឬធ្វើការផ្ទេរប្រាក់ជាប្រចាំចេញពីគណនីរបស់អ្នក ហើយអ្នកចង់បញ្ឈប់ការទូទាត់ ឬការផ្ទេរទាំងនោះ អ្នកចាំបាច់ត្រូវតែជូនដំណឹងដល់យើងខ្ញុំយ៉ាងហោចណាស់មួយថ្ងៃមុន ដែលជាថ្ងៃធ្វើការ មុនពេលការទូទាត់ ឬការផ្ទេរប្រាក់នោះដល់កាលវេលាកំណត់។ ប្រសិនបើអ្នកបង្កើតការទូទាត់ស្វ័យប្រវត្តិជាប្រចាំនៅក្នុងសេវាធនាគារអនឡាញរបស់យើងខ្ញុំ អ្នកអាចបញ្ឈប់ការទូទាត់នោះវិញតាមអនឡាញ បានផងដែរ។	អ្នកអាចផ្តល់សិទ្ធិអនុញ្ញាតដល់ភាគីទីបីណាមួយទៀត ដើម្បីឲ្យគេធ្វើការកាត់ទឹកប្រាក់ចេញពីគណនីរបស់អ្នកសម្រាប់ការទូទាត់លើសេវាផ្សេង (ឧទាហរណ៍ បុព្វលាភរ៉ាប់រងអាយុជីវិត ឬថ្លៃទឹកភ្លើង)។ ប្រសិនបើអ្នកចង់បញ្ឈប់ការទូទាត់បែបនេះ អ្នកអាចធ្វើបានតាមវិធីចំនួនពីរដូចខាងក្រោម៖ 1.ទាក់ទងមកយើងខ្ញុំដើម្បីស្នើសុំការបញ្ឈប់។ សូមកត់ចំណាំថា សំណើសុំនេះ អាចធ្វើទៅបានសម្រាប់តែការកាត់ទឹកប្រាក់ដោយផ្ទាល់ប៉ុណ្ណោះ។ បន្ទាប់មក យើងខ្ញុំអាចទាក់ទងទៅកាន់ភាគីដែលទទួលសិទ្ធិ ជំនួសអ្នក ដើម្បីស្នើសុំការបញ្ឈប់នោះ។ យើងខ្ញុំនឹងអនុវត្តតាមភ្លាម១នូវរាល់៖ ▪ សំណើដែលអ្នកស្នើឡើងដើម្បីឲ្យបញ្ឈប់សំណើកាត់ប្រាក់ដោយផ្ទាល់ ពាក់ព័ន្ធសេវាធនាគារដែលយើងខ្ញុំផ្តល់ជូន ឬ ▪ ការប្តឹងតវ៉ាដែលអ្នកធ្វើឡើងដោយអះអាងថា ការកាត់ប្រាក់ដោយផ្ទាល់នោះ ពុំមានការអនុញ្ញាត ឬពុំមានភាពប្រក្រតី។ នៅពេលដែលអ្នកទាក់ទងមកយើងខ្ញុំដើម្បីស្នើសុំបញ្ឈប់ការទូទាត់ យើងខ្ញុំអាចអនុវត្តសំណើនេះតាងនាមឲ្យអ្នក ហើយបញ្ជូនសំណើនេះបន្តទៅឲ្យភាគីដែលទទួលសិទ្ធិអនុញ្ញាត។ បន្ទាប់មក យើងខ្ញុំនឹងដាក់ពាក្យថា "បញ្ឈប់" នៅលើគណនីរបស់អ្នកដែលនឹងទប់ស្កាត់មិនឲ្យភាគីទទួលសិទ្ធិអនុញ្ញាតពីមុន ធ្វើការកាត់ប្រាក់បាន សម្រាប់រយៈពេលប្រាំឆ្នាំទៅមុខ។ អ្នកអាចស្នើសុំឲ្យដកពាក្យ "បញ្ឈប់" នេះ បានគ្រប់ពេលទាំងអស់។ យើងខ្ញុំនឹងដកសេវានេះ ដោយពុំមានការស្នើសុំឲ្យមានការផ្លាស់ប្តូរឡើយ។	2.ទាក់ទងទៅកាន់ភាគីដែលទទួលសិទ្ធិ ដោយខ្លួនឯង ដើម្បីស្នើសុំឲ្យមានការបញ្ឈប់។ ប្រសិនបើអ្នកបានផ្តល់លេខកាត និងកាលបរិច្ឆេទផុតកំណត់កាតទៅឲ្យអាជីវករ អ្នកនឹងត្រូវទាក់ទងពួកគេដើម្បីស្នើសុំការបញ្ឈប់។ សូមកត់ចំណាំថា ករណីនេះគឺខុសពីការកាត់ទឹកប្រាក់ដោយផ្ទាល់ ធនាគារ ABA មិនអាចបញ្ឈប់ការទូទាត់ជាប្រចាំ (ដែលត្រូវបានគេស្គាល់ផងដែរថាជា ការទូទាត់បន្តបន្ទាប់តាមកាត) ជំនួសឲ្យអ្នកបានឡើយ។ អាជីវករមានសិទ្ធិស្នើសុំឲ្យធនាគារ ABA កាត់ទឹកប្រាក់ចេញពីគណនីរបស់អ្នក ហើយធនាគារ ABA មានកាតព្វកិច្ចក្នុងការអនុវត្តតាមសំណើនេះ លុះត្រាតែអ្នកបានបញ្ឈប់ការផ្តល់សិទ្ធិនេះ។ ប្រសិនបើអាជីវករមិនអនុវត្តតាមសំណើរបស់អ្នកក្នុងការបញ្ឈប់ការផ្តល់សិទ្ធិនេះទេនោះ អ្នកត្រូវផ្តល់មកឲ្យធនាគារ ABA នូវសារឆ្លងឆ្លើយជាមួយនឹងអាជីវករមួយច្បាប់ ដើម្បីផ្តល់លទ្ធភាពឲ្យធនាគារ ABA អាចជំទាស់ទៅនឹងប្រតិបត្តិការនានាដែលតាងនាមឲ្យរូបអ្នកបាន។
ព័ត៌មានលម្អិតអ្វីខ្លះដែលយើងខ្ញុំត្រូវការចាំបាច់ ដើម្បីបញ្ឈប់ការទូទាត់៖			
ព័ត៌មានអំពីមូលប្បទានបត្រដូចខាងក្រោម៖ ▪ ព័ត៌មានអំពីគណនី ▪ លេខមូលប្បទានបត្រ ▪ ចំនួនមូលប្បទានបត្រ ▪ ឈ្មោះអត្ថាគាហក (បុគ្គលដែលអ្នកចេញមូលប្បទានបត្រជូន) ▪ កាលបរិច្ឆេទមូលប្បទានបត្រ និង ▪ បញ្ជាក់ថាតើមូលប្បទានបត្រត្រូវបានធ្លាក ឬចំហ	ព័ត៌មានដូចខាងក្រោម៖ ▪ គណនីទូទាត់ ▪ កាលកំណត់ទូទាត់ ▪ អត្ថាគាហក និង ▪ គណនីដែលជាធម្មតាប្រើសម្រាប់ទូទាត់		

តម្លៃសេវា និងបន្ទុកនានា

7. តម្លៃសេវា និងបន្ទុកនានា

7.1. តម្លៃសេវា និងបន្ទុកគណនី

អាស្រ័យតាម ខ និងលក្ខខណ្ឌដែលអាចអនុវត្តបាន ធនាគារអាចកំណត់តម្លៃសេវា និងបន្ទុកទៅលើសេវាណាមួយដែលបានចែងនៅក្នុងកូនសៀវភៅនេះ និង/ឬ ផលិតផល/សេវានានា ដែលខ្លួនផ្តល់ឲ្យទាក់ទងនឹងគណនីណាមួយ។ តម្លៃសេវា និងបន្ទុកនានា អាចត្រូវបានកំណត់ផ្សេងៗគ្នាអាស្រ័យលើបណ្តាញដែលត្រូវបានប្រើប្រាស់ដើម្បីស្នើសុំសេវា និងរូបិយប័ណ្ណដែលម្ចាស់គណនីបានប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការគណនីរបស់ខ្លួន។

តម្លៃសេវា និងបន្ទុកមួយចំនួនមានបញ្ជាក់នៅក្នុងកូនសៀវភៅនេះ។ ព័ត៌មានលម្អិតពេញលេញអំពីតម្លៃសេវា និងបន្ទុកទាំងអស់មានចែងនៅក្នុងខិត្តប័ណ្ណ "បន្ទុកសេវា" ដែលអាចស្វែងរកបាននៅគ្រប់សាខាធនាគារ ឬនៅលើគេហទំព័រ។ ធនាគារមានសិទ្ធិដកទឹកប្រាក់ចេញពីគណនីរបស់អ្នកសម្រាប់តម្លៃសេវា និងបន្ទុកទាំងនេះ រាល់ពេលដែលអាចទូទាត់បាន។

តម្លៃសេវា និងបន្ទុកទាំងអស់ដែលកំណត់ដោយរដ្ឋាភិបាល រួមមានពន្ធកាត់ទុកលើនិវាសនជន ពន្ធកាត់ទុកលើអនិវាសនជន និងតម្លៃសេវាពាក់ព័ន្ធផ្សេងទៀតទាំងអស់ ក៏អាចត្រូវបានធនាគារកាត់ចេញពីគណនីរបស់អ្នកផងដែរ។

ប្រសិនបើមានការផ្លាស់ប្តូរលើតម្លៃសេវា និងបន្ទុកស្តង់ដារ ធនាគារនឹងជូនដំណឹងដល់អ្នកអំពីការផ្លាស់ប្តូរ និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរទាំងនោះ ដែលនឹងមានសុពលភាពតាមរយៈ ៖

- ការទាក់ទងទៅអ្នកដោយផ្ទាល់ (ឧទាហរណ៍ ដោយការជូនដំណឹងលើរបាយការណ៍គណនីរបស់អ្នក)
- បិទការជូនដំណឹងនៅតាមសាខាធនាគារ ឬមធ្យោបាយទំនាក់ទំនងឌីជីថលផ្សេងទៀត ដូចជា វិបសាយ, ហ្វេសប៊ុក, សារជូនដំណឹង, ការធ្វើជាសារទូរស័ព្ទ និងអ៊ីមែលជាដើម
- ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ។

មធ្យោបាយទំនាក់ទំនងទាំងនេះមិនសូវជាលម្អិតខ្លាំងនោះទេ។ ក្នុងករណីដែលអាចធ្វើបាន ហើយដើម្បីជាការយកចិត្តទុកដាក់សមស្របមកលើសេវាកម្មរបស់ខ្លួន ធនាគារនឹងជូនដំណឹងអំពីតម្លៃសេវា និងបន្ទុកក្រៅស្តង់ដារនានា មុនពេលដល់កំណត់ត្រូវទូទាត់។

ចន្លោះខាងក្រោមនេះ ត្រូវបានរក្សាទុកឲ្យនៅទំនេរ។
សូមបន្តទៅទំព័របន្ទាប់។

សុវត្ថិភាពគណនី
និងការរ៉ាប់រង

8. សុវត្ថិភាព និងការរ៉ាប់រងលើការប្រើប្រាស់កាត និងសេវាធនាគារអនឡាញ

8.1. ការការពារកាតរបស់អ្នក

ដើម្បីការពារកាតរបស់អ្នក អ្នកត្រូវ៖

- ចុះហត្ថលេខាលើកាតនោះ ភ្លាមៗបន្ទាប់ពីអ្នកទទួលបានកាត
- ដាក់កាតរបស់អ្នកតាមខ្លួន ឬទុកនៅទីកន្លែងសុវត្ថិភាព
- ពិនិត្យជាប្រចាំថា កាតនោះនៅជាប់ជាមួយអ្នក ឬនៅកន្លែងមានសុវត្ថិភាព
- មិនត្រូវប្រគល់កាតរបស់អ្នកទៅឲ្យនរណាម្នាក់ឡើយ រួមទាំងសមាជិកគ្រួសារ ឬមិត្តភក្តិរបស់អ្នកផងដែរ។

8.2. ការរក្សាទុកលេខសម្ងាត់ (PIN) របស់អ្នក

ប្រសិនបើអ្នកកត់លេខសម្ងាត់ (PIN) របស់អ្នកទុកនៅកន្លែងណាមួយ អ្នកត្រូវទុកឲ្យដាច់ដោយឡែក និងឲ្យនៅឆ្ងាយពីកាតរបស់អ្នក លុះត្រាតែលេខកាតនោះត្រូវបានលាក់បាំងឲ្យបានសមស្រប។ ទោះជាយ៉ាងណា ដើម្បីកាត់បន្ថយហានិភ័យទាក់ទងនឹងប្រតិបត្តិការគ្មានការអនុញ្ញាតដែលអាចកើតមាននៅលើគណនីរបស់អ្នក ជាការល្អបំផុត អ្នកគួរទុកដាក់លេខសម្ងាត់ (PIN) របស់អ្នកឲ្យនៅដាច់ដោយឡែក និងនៅឆ្ងាយពីកាតរបស់អ្នក បើទោះបីជាអ្នកអាចរក្សាទុកបានល្អយ៉ាងណាក៏ដោយ។

8.3. ការការពាររលេខកូដសម្រាប់បើកចូលគណនី រាប់ទាំងលេខសម្ងាត់(PIN) របស់អ្នក

អ្វីដែលអ្នកត្រូវធ្វើ	អ្វីដែលអ្នកមិនអាចធ្វើ
▪ រក្សាទិន្នន័យទាំងនោះក្នុងការចងចាំ។ ▪ បំផ្លាញលិខិតនានាដែលមានព័ត៌មានអំពីលេខសម្ងាត់ (PIN) ប្រសិនបើមាន និងរាល់ឯកសារដែលយើងខ្ញុំបានចេញជូនអ្នក ហើយមានលេខកូដនៅក្នុងឯកសារនោះ។ ▪ ចូរប្រាកដថាគ្មាននរណាម្នាក់មើលឃើញ ឬស្តាប់ឮអ្នក នៅពេលដែលអ្នកបញ្ចូល ឬប្រើប្រាស់លេខកូដនៅលើឧបករណ៍អេឡិកត្រូនិក (ឧទាហរណ៍ ម៉ាស៊ីន ATM និងម៉ាស៊ីន POS ជាដើម) ▪ ចូរប្រាកដថា អ្នកបានចងចាំទិន្នន័យច្បាស់លាស់រាល់ពេលចូលទៅប្រើម៉ាស៊ីន ATM ឬម៉ាស៊ីនទូទាត់ POS ▪ ចូរប្រាកដថា អ្នកមិនភ្លេចអ្វីមួយឡើយ នៅពេលដែលអ្នកបញ្ចប់ប្រតិបត្តិការ ដូចជាការទុកកាតរបស់អ្នកចូលនៅក្នុង ឬនៅតាមម៉ាស៊ីន ATM ជាដើម។ ▪ ត្រូវជូនដំណឹងមកយើងខ្ញុំភ្លាមៗ ប្រសិនបើសាររលេខសម្ងាត់ (PIN) របស់អ្នក មិនទទួលបាន ឬត្រូវបានបើកមើលរួច (ប្រសិនបើយើងខ្ញុំមានការព្រមព្រៀងលើចំណុចបែបនេះ) ឬប្រសិនបើសំណើសុំប្តូររលេខសម្ងាត់ (PIN) បានកើតឡើងទៅដោយគ្មានការស្នើសុំពីអ្នក។	▪ សរសេររលេខសម្ងាត់ (PIN) នៅលើកាតរបស់អ្នក បើទោះបីជាមានការលាក់បាំងលេខសម្ងាត់ (PIN) នោះ ក៏ដោយ។ ▪ កត់លេខសម្ងាត់ (PIN) ដាក់ជាមួយ ឬនៅជិតកាតរបស់អ្នក។ ▪ ប្រាប់លេខកូដទៅនរណាម្នាក់ ដូចជាសមាជិកគ្រួសារ និងមិត្តភក្តិរបស់អ្នក។ ▪ ប្រសិនបើអ្នកជ្រើសរើសយកលេខកូដផ្ទាល់ខ្លួន សូមកុំជ្រើសរើសយកលេខ ឬពាក្យដែលងាយនឹងគេទាយដឹង (ឧទាហរណ៍ លេខណាមួយដែលបោះពុម្ពលើកាតនោះ, ថ្ងៃខែឆ្នាំកំណើត, លេខប័ណ្ណបើកបរជាដើម) ▪ បញ្ចូលលេខសម្ងាត់ (PIN) របស់អ្នកនៅតាមទីតាំងផ្តល់សេវាធនាគារអេឡិកត្រូនិក ដែលប្រើឧបករណ៍ក្លែងបន្លំ/ចម្លងតាម, ឧបករណ៍កែប្រែសំណុំដើម, មានប្រើភ្ជាប់ឧបករណ៍គួរឲ្យសង្ស័យភ្ជាប់ ឬធ្វើប្រតិបត្តិការក្នុងលក្ខណៈគួរឲ្យសង្ស័យ។

8.4. លេខសម្ងាត់ (PIN) ឬលេខកូដកាតផ្សេងទៀតដែលបាត់ ត្រូវបានលួច ឬបន្លំប្រើ

អ្នកត្រូវជូនដំណឹងមកយើងខ្ញុំឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប្រសិនបើកាត, លេខសម្ងាត់ (PIN) ឬលេខកូដ បានបាត់, ត្រូវបានគេលួច ឬបន្លំប្រើ ឬអ្នកសង្ស័យថា មានការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាតនៅលើគណនីណាមួយ។ ការជូនដំណឹងនេះ នឹងផ្តល់លទ្ធភាពដល់យើងខ្ញុំក្នុងការបញ្ឈប់ប្រតិបត្តិការកាតរបស់អ្នក

ភ្លាមៗ ដោយទប់ស្កាត់ ឬកាត់បន្ថយការខាតបង់ ដែលកើតចេញពីការធ្វើប្រតិបត្តិការគ្មានការអនុញ្ញាត និងការរ៉ាប់រងរបស់អ្នកដែលអាចកើតមានចំពោះការខាតបង់។ ប្រសិនបើអ្នកភ្លេចកាតនៅទីណាមួយ អ្នកអាចបិទប្រតិបត្តិការកាតរបស់អ្នកបណ្តោះអាសន្នសិន ដោយប្រើប្រាស់សេវាធនាគារអនឡាញ។ ប្រសិនបើកាតរបស់អ្នកបានបាត់ ឬត្រូវបានគេលួច អ្នកអាចបង្កកកាតនោះជាអចិន្ត្រៃយ៍តែម្តង ដោយប្រើប្រាស់សេវាធនាគារអនឡាញ និង/ឬ អ្នកចាំបាច់ត្រូវទាក់ទងមកយើងខ្ញុំ ដើម្បីបិទកាតរបស់អ្នកជាអចិន្ត្រៃយ៍។

9. ការរ៉ាប់រងលើប្រតិបត្តិការគ្មានការអនុញ្ញាត

នៅក្នុងផ្នែកនេះ យើងខ្ញុំបានកំណត់ការបែងចែកអំពីថាពេលណាដែលអ្នកត្រូវ និងមិនត្រូវទទួលរ៉ាប់រងចំពោះប្រតិបត្តិការដែលគ្មានការអនុញ្ញាត។

ពេលដែលអ្នកមិនត្រូវទទួលរ៉ាប់រង	ពេលដែលអ្នកត្រូវទទួលរ៉ាប់រង

អ្នកនឹងមិនត្រូវទទួលរ៉ាប់រងលើការខាតបង់ទាំងឡាយណា បង្កដោយប្រតិបត្តិការមិនមានការអនុញ្ញាត ដែលបង្ហាញយ៉ាងច្បាស់ថាអ្នកប្រើប្រាស់មិនបានរួមចំណែកនាំឲ្យមានខាតបង់នោះ។ អ្នកពុំចាំបាច់ទទួលរ៉ាប់រងលើការខាតបង់បង្កឡើងដោយប្រតិបត្តិការមិនមានការអនុញ្ញាតដែល៖
 	
▪ បង្កឡើងដោយការក្លែងបន្លំ ឬការធ្វេសប្រហែសរបស់បុគ្គលិក ឬ
▪ តម្រូវឲ្យប្រើប្រាស់កាត ឬឧបករណ៍ដទៃ និង/ឬលេខកូដ ដែលកើតឡើងមុនពេលអ្នកទទួលបានកាត ឬឧបករណ៍ ឬទទួល ឬជ្រើសរើសលេខកូដ (ទៅតាមករណីជាក់ស្តែង) រួមទាំងការប្តូរ ឬការចេញកាត ឧបករណ៍ និងលេខកូដម្តងទៀត ឬ
▪ តម្រូវឲ្យប្រើប្រាស់កាត ឬឧបករណ៍ដទៃ និង/ឬលេខកូដ ដែលកើតឡើងបន្ទាប់ពីពេលដែលយើងខ្ញុំទទួលបានដំណឹងថា កាត ឬឧបករណ៍ ត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ឬបានបាត់ ឬត្រូវបានគេលួច ឬលេខកូដសុវត្ថិភាព ត្រូវបានបំពាន; ឬ
▪ តម្រូវឲ្យប្រើប្រាស់កាត ឬឧបករណ៍ដទៃ ដែលកើតឡើងបន្ទាប់ពីអ្នកបានស្នើសុំឲ្យយើងខ្ញុំធ្វើការបញ្ឈប់កាត និងបានប្រគល់កាតនោះមកឲ្យយើងខ្ញុំវិញ។
▪ ត្រូវបានបង្កើតជាមួយកាត, លេខកូដ ឬឧបករណ៍ដទៃ ឬឧបករណ៍កំណត់អត្តសញ្ញាណត្រូវបានក្លែងបន្លំ, មានកំហុស, ផុតសុពលភាព ឬត្រូវបានបញ្ឈប់។
▪ ប្រតិបត្តិការអេឡិកត្រូនិក អាចធ្វើទៅបានដោយប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណ ដែលមិនតម្រូវឲ្យមានលេខកូដ ឬ ឧបករណ៍ ឬ
▪ ប្រតិបត្តិការអេឡិកត្រូនិក ដែលអាចប្រើប្រាស់ឧបករណ៍ តែមិនមែនលេខកូដ លុះត្រាតែអ្នកធ្វើការពន្យារពេលដោយមិនសមហេតុផលក្នុងការរាយការណ៍អំពីការខាតបង់ ឬការលួចឧបករណ៍នោះ។
	អ្នកត្រូវទទួលរ៉ាប់រងលើរាល់ការខាតបង់ដែលបណ្តាលមកពីប្រតិបត្តិការ ដែលធ្វើឡើងដោយអ្នកប្រើប្រាស់ ឬដោយបុគ្គលផ្សេងទៀត ដែលអ្នកប្រើប្រាស់បានទទួលស្គាល់ និងយល់ព្រម។ អ្នកត្រូវទទួលខុសត្រូវចំពោះការខាតបង់ដាក់ស្តែង បង្កឡើងពីប្រតិបត្តិការមិនមានការអនុញ្ញាត ដែលបណ្តាលមកពីអ្នកប្រើប្រាស់៖
	
	▪ ចូលរួមពាក់ព័ន្ធនឹងការក្លែងបន្លំ ឬ
	▪ បង្ហាញ ឬប្រាប់លេខកូដដល់នរណាម្នាក់ រួមមានសមាជិកគ្រួសារ ឬមិត្តភក្តិ; ឬ
	▪ ការកត់ទុកនូវលេខសម្ងាត់ (PIN) ឬលេខកូដដទៃ៖
	  ▪ ដោយមិនបានព្យាយាមបិទបាំង ឬការពារពីការចូលប្រើប្រាស់ដោយគ្មានការ អនុញ្ញាត និង
	  ▪ ទុកដាក់ក្នុងរបៀបដែល អាចបាត់បង់ ឬត្រូវគេលួចបាន ជាមួយកាត (ក្នុងករណីលេខសម្ងាត់) ឬ ឧបករណ៍ណាមួយដែលមានលេខកូដ ឬ
	▪ ការកត់លេខកូដទុក៖
	  ▪ ដោយមិនបានព្យាយាមបិទបាំង ឬការពារពីការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត; និង
	  ▪ ដែលមានលេខកូដច្រើនត្រូវបានប្រើប្រាស់, កត់ត្រាទុក លេខកូដទាំងពីរ/ទាំងអស់ ក្នុងរបៀបដែលអាចបាត់បង់ ឬត្រូវគេលួចបាន ឬ
	▪ ការសរសេរលេខសម្ងាត់ (PIN) នៅលើកាតនីមួយៗ ឬ
	▪ ការសរសេរលេខកូដនៅលើឧបករណ៍ដែលប្រើលេខកូដនោះ ឬ
	▪ ការជ្រើសរើស លេខកូដដែលប្រើថ្ងៃខែឆ្នាំកំណើតរបស់ខ្លួន, ឬលេខកូដដែលមានតួអក្សរតាម
	
	លំដាប់អក្ខរក្រម ដែលអាចសម្គាល់បានថាជាផ្នែកមួយនៃឈ្មោះរបស់ខ្លួន បន្ទាប់ពីយើងខ្ញុំបានស្នើសុំ ឬហាមឃាត់មិនឲ្យពួកគេជ្រើសរើសលេខកូដបែបនេះរួចហើយ ហើយបានបញ្ជាក់ប្រាប់ពួកគេរួចរាល់ពីលទ្ធផលប្រឈមដែលបណ្តាលមកពីការជ្រើសរើសលេខកូដបែបនេះ ឬ
	
	▪ ទុកកាតចោលនៅឯម៉ាស៊ីន ATM (លុះត្រាតែម៉ាស៊ីន ATM មានបញ្ចូលស្គង់ជាសុវត្ថិភាពសមស្រប ដែលអាចជួយសម្រាលហានិភ័យនៃការទុកកាតចោលក្នុងម៉ាស៊ីន ATM បាន)។ ឬ
	▪ មិនយកចិត្តទុកដាក់ទាល់តែសោះក្នុងការការពារលេខកូដ។

អ្នកក៏ត្រូវទទួលរ៉ាប់រងចំពោះការខាតបង់ដាក់ស្តែងដែលកើតចេញពីប្រតិបត្តិការដែលគ្មានការអនុញ្ញាត ដែលបង្កឡើងដោយសារអ្នកប្រើប្រាស់ពន្យារការជូនដំណឹងមកយើងខ្ញុំអំពីការបន្លំប្រើ, ការបាត់ ឬត្រូវបានគេលួច នូវកាត ឬឧបករណ៍ដទៃ ឬ លេខកូដ ដែលអ្នកផ្សេងបានដឹង។ ការទទួលរ៉ាប់រងរបស់អ្នកកម្រិតត្រឹមតែការខាតបង់ដែលកើតមានចន្លោះពេលដែលអ្នកបានដឹង (ឬគួរបានដឹង) អំពីការបន្លំប្រើ, ការបាត់ ឬត្រូវបានគេលួចនោះ និងពេលដែលយើងខ្ញុំទទួលបានការជូនដំណឹងដាក់ស្តែង។

ចំណុចផ្សេងទៀតដែលត្រូវដឹង

10. ការកែប្រែ ខ និងលក្ខខណ្ឌ

នៅគ្រប់ពេលទាំងអស់ យើងខ្ញុំអាចធ្វើការកែប្រែ ខ និងលក្ខខណ្ឌ អាស្រ័យតាមច្បាប់ជាធរមាន និងលក្ខខណ្ឌតម្រូវ ពាក់ព័ន្ធនឹង ៖

- តម្លៃសេវា និងបន្ទុក (ដូចជា ចំនួន, ភាពញឹកញាប់, ពេលវេលាទូទាត់ និងដាក់ឲ្យអនុវត្តតម្លៃសេវា និងបន្ទុកថ្មី)
- អត្រាការប្រាក់
- ការកែប្រែវិធីសាស្ត្រគណនាការប្រាក់, បន្ទុក ឬការទូទាត់ចំពោះគណនីរបស់អ្នក ឬចំពោះកម្រិតសមតុល្យប្រចាំថ្ងៃដែលកំណត់អត្រាការប្រាក់ ឬអត្រានានា
- កំណត់កម្រិតប្រតិបត្តិការ
- ប្រភេទប្រតិបត្តិការដែលបានធ្វើឡើង ឬមធ្យោបាយដែលអ្នកអាចប្រើប្រាស់ ឬធ្វើប្រតិបត្តិការគណនីរបស់អ្នក
- លក្ខខណ្ឌតម្រូវពេញសិទ្ធិពាក់ព័ន្ធនឹងគណនីរបស់អ្នក ឬ
- មុខងារគណនីរបស់អ្នក ឬផលិតផល ឬសេវាកម្ម

យើងខ្ញុំនឹងជូនដំណឹងដល់អ្នក ប្រសិនបើ ខ និងលក្ខខណ្ឌនៃគណនីរបស់អ្នកត្រូវបានកែប្រែក្រោមហេតុផលណាមួយ និងផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីបញ្ឈប់គណនីធនាគារ ឬសេវាធនាគារផ្សេងៗទៀតជាមួយយើងខ្ញុំ ក្នុងករណីដែលអ្នកជំទាស់ទៅនឹងការផ្លាស់ប្តូរទាំងនោះ ។

ទោះយ៉ាងណា ការជូនដំណឹងជាមុន នឹងមិនត្រូវបានធ្វើឡើងឡើយ ប្រសិនបើ ការកែប្រែនោះ ត្រូវតម្រូវឲ្យធ្វើឡើងភ្លាមៗ ដើម្បីស្តារ ឬរក្សាសុវត្ថិភាពប្រព័ន្ធ ឬឧបករណ៍នានា ។ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ យើងខ្ញុំអាចនឹងជូនដំណឹងអំពីការកែប្រែដល់អ្នក ទៅតាមការកំណត់នៅក្នុងតារាងខាងក្រោម ៖

ប្រភេទនៃការកែប្រែ	ថេរៈវេលាកម្រិត	មធ្យោបាយជូនដំណឹង
សមតុល្យបន្តអប្បបរមាដែលតម្រូវ	30 ថ្ងៃជាមុន	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
តម្លៃសេវាកម្មថ្មី ឬការដំឡើងតម្លៃសេវាកម្មសម្រាប់ការធ្វើប្រតិបត្តិការតាមអេឡិកត្រូនិក ឬការចេញ ឬការប្តូរឧបករណ៍សម្រាប់ប្រតិបត្តិការអេឡិកត្រូនិក (ដូចជាកាត, ឧបករណ៍បង្កើតកូដ, ឬលេខកូដ)	30 ថ្ងៃជាមុន	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
តម្លៃសេវាកម្ម ឬបន្ទុកថ្មីផ្សេងទៀត ឬការដំឡើងតម្លៃសេវាកម្ម ឬបន្ទុកណាមួយ ។	30 ថ្ងៃជាមុន	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
កែប្រែអត្រាការប្រាក់	មិនឲ្យហួសថ្ងៃដែលខ្លឹមសារត្រូវបានកែប្រែ	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
ការកែប្រែវិធីសាស្ត្រគណនាការប្រាក់, បន្ទុក ឬការទូទាត់ចំពោះគណនីរបស់អ្នក – ឬចំពោះកម្រិតសមតុល្យប្រចាំថ្ងៃដែលកំណត់អត្រាការប្រាក់ ឬអត្រានានា	30 ថ្ងៃជាមុន	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
ការកែប្រែដែលបង្កើនការទទួលខុសត្រូវរបស់អ្នកសម្រាប់ការធ្វើប្រតិបត្តិការអេឡិកត្រូនិក	30 ថ្ងៃជាមុន ឬមិនឲ្យហួសថ្ងៃដែលខ្លឹមសារត្រូវបានកែប្រែ	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
កម្រិតកំណត់ប្រតិបត្តិការលើការធ្វើប្រតិបត្តិការតាមអេឡិកត្រូនិក ឧបករណ៍ ឬបរិក្ខារអេឡិកត្រូនិក	30 ថ្ងៃជាមុន ឬ មិនឲ្យហួសថ្ងៃដែលខ្លឹមសារត្រូវបានកែប្រែ	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ

ប្រភេទនៃការកែប្រែ	ថេរៈវេលាកម្រិត	មធ្យោបាយជូនដំណឹង
បន្ទុកសេវារដ្ឋាភិបាល	ជូនដំណឹងជាមុន ឬឲ្យបានឆាប់តាមដែលអាចអនុវត្តបាន បន្ទាប់ពីថ្ងៃដែលខ្លឹមសារត្រូវបានកែប្រែ លើកលែងតែការកែប្រែនោះ ត្រូវបានភ្នាក់ងារាជរដ្ឋាភិបាល ឬរាជរដ្ឋាភិបាល ឬអង្គភាពតំណាង ធ្វើការផ្សព្វផ្សាយជាសាធារណៈ។	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ
ការកែប្រែ ខ និងលក្ខខណ្ឌផ្សេងទៀត	ជូនដំណឹងមុនថ្ងៃដែលខ្លឹមសារត្រូវបានកែប្រែ	ជាលាយលក្ខណ៍អក្សរ, អេឡិកត្រូនិក, ឬតាមប្រព័ន្ធផ្សព្វផ្សាយ

10.1. ការជូនដំណឹងតាមប្រព័ន្ធអេឡិកត្រូនិក

ធនាគារ អាចនឹងប្រើប្រាស់អាសយដ្ឋានអ៊ីមែលរបស់អ្នក ដើម្បីជូនដំណឹងអំពីការកែប្រែព័ត៌មានគណនីរបស់អ្នក រួមទាំង ខ និងលក្ខខណ្ឌ ឬធ្វើការផ្ញើអ៊ីមែលជូនដំណឹងដល់អ្នកថា អ្នកអាចពិនិត្យមើលការកែប្រែបានតាមរយៈសេវាធនាគារអនឡាញ ឬវិបសាយរបស់យើងខ្ញុំ។

យើងខ្ញុំអាចពង្រីកវិសាលភាពនៃការជូនដំណឹងនេះ តាមរយៈមធ្យោបាយផ្សេងៗទៀត ដូចជាការជូនដំណឹងតាមរយៈសារជូនដំណឹង និងសារទូរស័ព្ទ ទៅកាន់ប្រូហ្វាល ABA Mobile របស់អ្នក និងលេខទូរស័ព្ទដែលបានចុះបញ្ជីក្នុងប្រព័ន្ធ អំពីការកែប្រែផលិតផល និងសេវាកម្មដែលរៀបចំរួចរាល់ ដើម្បីអតិថិជនអញ្ជើញមកទទួលយកក៏ដូចជាការកែប្រែដែលនឹងត្រូវអនុវត្ត ជាមួយយោបល់ ពាក់ព័ន្ធនឹងមធ្យោបាយដើម្បីទទួលបានព័ត៌មានលម្អិត។ លោកអ្នកត្រូវបានសន្មតថាទទួលបានសារជូនដំណឹងនេះ នៅពេលដែលប្រព័ន្ធបានបង្ហាញថា សារត្រូវបានបញ្ជូនចេញដោយជោគជ័យ។

10.2. មធ្យោបាយទំនាក់ទំនង

អ្នកយល់ស្របថា មធ្យោបាយទំនាក់ទំនងប្រចាំថ្ងៃរវាងអ្នក និងធនាគារ ត្រូវធ្វើឡើងតាមរយៈលេខទូរស័ព្ទដែលអ្នកបានផ្តល់ឲ្យនៅពេលអ្នកស្នើសុំបើកគណនី។ អ៊ីមែលអាចប្រើប្រាស់សម្រាប់តែកាលៈទេសៈមួយចំនួនប៉ុណ្ណោះ ពោលគឺនៅពេលណាដែលធនាគារមិនអាចទាក់ទងទៅអ្នកបាន តាមរយៈការហៅតាមទូរស័ព្ទ។

ពាក់ព័ន្ធនឹងលេខទូរស័ព្ទ អ្នកយល់ព្រមថា ធនាគារនឹងមិនបើកគណនីឲ្យអ្នកទេ ក្នុងករណីដែលធនាគាររកឃើញថា លេខទូរស័ព្ទដែលអ្នកផ្តល់ជូន ជាលេខដែលកំពុងប្រើប្រាស់ដោយអ្នកផ្សេងទៀត លើកលែងតែអ្នកមានភ័ស្តុតាងបញ្ជាក់ថា អ្នកពិតជាម្ចាស់បច្ចុប្បន្ទនៃលេខទូរស័ព្ទនោះពិតមែន ឬលើកលែងតែអ្នកយល់ព្រមផ្តល់លេខទូរស័ព្ទថ្មី ឬលើកលែងតែអ្នកយល់ព្រមប្រើតែអ៊ីមែល មិនប្រើលេខទូរស័ព្ទ។

11. កិច្ចការទូទៅ

11.1. ការបិទបញ្ចប់ប្រតិបត្តិការប្រចាំថ្ងៃ (EOD)

ការបិទបញ្ចប់ប្រតិបត្តិការប្រចាំថ្ងៃ គឺជាដំណើរការនៃការបញ្ចូល ឬបញ្ចប់ប្រតិបត្តិការទាំងអស់នៅក្នុងប្រព័ន្ធ នៅក្នុងថ្ងៃតែមួយនៃថ្ងៃធ្វើប្រតិបត្តិការ ហៅថា "T day"(ថ្ងៃនេះ)។ ដោយសារតែចំនួននៃប្រតិបត្តិការក្នុងថ្ងៃនីមួយៗ អាចមានចំនួនច្រើន ធនាគារនឹងចាប់ផ្តើមធ្វើការបញ្ចប់ប្រតិបត្តិការប្រចាំថ្ងៃទាំងអស់ មុនម៉ោង 12:00 យប់ នៃ "T day" (ថ្ងៃនេះ)។ ប្រសិនបើអ្នកធ្វើប្រតិបត្តិការណាមួយ ក្នុងកំឡុងពេលដែលធនាគារធ្វើ EOD កាលបរិច្ឆេទនៃប្រតិបត្តិការរបស់អ្នកឱតនៅក្នុងថ្ងៃដដែល (T day) ឬ 1 ថ្ងៃបន្ទាប់ (T+1 day)។

ក្នុងករណីដែលកាលបរិច្ឆេទប្រតិបត្តិការរបស់អ្នក មានសារៈសំខាន់ ឧទាហរណ៍ ការទូទាត់កម្ចី ឬ សងប្រាក់ទៅអ្នកផ្តត់ផ្តង់ ធនាគារតម្រូវឲ្យអ្នកធ្វើប្រតិបត្តិការទាំងនោះ មុនម៉ោង 8:00 យប់ នៃ T Day បើមិនដូច្នោះទេ កាលបរិច្ឆេទនៃប្រតិបត្តិការរបស់អ្នកអាចនឹងចុះនៅថ្ងៃបន្ទាប់ មិនមែននៅថ្ងៃធ្វើប្រតិបត្តិការឡើយ។

ធនាគារនឹងមិនទទួលខុសត្រូវឡើយ ចំពោះផលវិបាក ឬការបាត់បង់ណាមួយដែលកើតឡើងពីប្រតិបត្តិការ ឬការទូទាត់ណាមួយ ដែលធ្វើឡើងក្រោយម៉ោង 8:00 យប់។

11.2. ទម្រង់ឯកសារនៃការអនុវត្តកិច្ចព្រមព្រៀង

តាមដែលអនុញ្ញាតដោយច្បាប់ជាធរមាន ធនាគារត្រូវយកហត្ថលេខា ឬស្នាមផ្តិតមេដៃរបស់អ្នក នៅពេលអ្នកធ្វើទម្រង់ឯកសារ និង/ឬកិច្ចព្រមព្រៀងណាមួយ។ តាមស្តង់ដារនៃការអនុវត្តជាទូទៅ ធនាគារត្រូវការហត្ថលេខាសម្រាប់ការធ្វើឯកសារ ឬកិច្ចព្រមព្រៀង។ ទោះយ៉ាងណា មានកាលៈទេសៈជាក់លាក់ខ្លះ ដែលធនាគារអាចនឹងត្រូវការទាំងពីរ គឺទាំងហត្ថលេខា និងទាំងស្នាមផ្តិតមេដៃ សម្រាប់ការធ្វើឯកសារ ឬកិច្ចព្រមព្រៀង (ឧទាហរណ៍ ការចុះកិច្ចព្រមព្រៀងកម្ចី ជាដើម)។ ទាំងហត្ថលេខា និងទាំងស្នាមផ្តិតមេដៃ មានសុពលភាពផ្នែកច្បាប់ស្មើគ្នា នៅគ្រប់ពេលវេលា។

11.3. តើអ្វីនឹងកើតឡើង នៅពេលអ្នកផ្លាស់ប្តូរព័ត៌មានរបស់អ្នក?

ប្រសិនបើអាសយដ្ឋាន ឬព័ត៌មានទំនាក់ទំនងដទៃទៀតរបស់អ្នកមានការផ្លាស់ប្តូរ សូមអ្នកជូនដំណឹងមកយើងខ្ញុំឲ្យបានឆាប់ តាមដែលអាចធ្វើបាន។ អ្នកអាចជូនដំណឹងមកយើងខ្ញុំបានយ៉ាងងាយស្រួល ដោយគ្រាន់តែអញ្ជើញទៅកាន់សាខាណាមួយរបស់យើងខ្ញុំ។ ប្រសិនបើហត្ថលេខីរបស់គណនីមានការផ្លាស់ប្តូរ សូមអ្នកជូនដំណឹងមកយើងខ្ញុំឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ដោយអញ្ជើញមកកាន់សាខាណាមួយរបស់យើងខ្ញុំ។ សូមកត់សម្គាល់ថា ប្រសិនបើអ្នកមិនបានជូនដំណឹងជាមុនគ្រប់គ្រាន់ អំពីការផ្លាស់ប្តូរព័ត៌មានគណនីរបស់អ្នកនោះទេ យើងខ្ញុំមិនអាចទទួលខុសត្រូវចំពោះកំហុស ឬបញ្ហាអាក់ដំណើរការណាមួយ ឬការខាតបង់ណាមួយដែលកើតចេញពីការផ្លាស់ប្តូរព័ត៌មានគណនីនេះឡើយ។ ប្រសិនបើយើងខ្ញុំមិនអាចស្វែងរកទីតាំងអ្នកឃើញទេ បន្ទាប់ពីបានខិតខំអស់ពីលទ្ធភាពសមហេតុផលហើយ យើងខ្ញុំអាចនឹងបញ្ឈប់ប្រតិបត្តិការនៅលើគណនីរបស់អ្នក ហើយរង់ចាំរហូតទាល់តែអ្នកផ្តល់បច្ចុប្បន្នភាពនៃព័ត៌មានទំនាក់ទំនងរបស់អ្នក។

11.4. ការផ្លាស់ប្តូរអាសយដ្ឋាន លេខទូរស័ព្ទ និងលេខទូរសារ

អ្នកត្រូវតែជូនដំណឹងមកកាន់ធនាគារភ្លាម១ អំពីការផ្លាស់ប្តូរណាមួយអំពីអាសយដ្ឋាន, លេខទូរស័ព្ទ ឬលេខទូរសាររបស់អ្នក។ ការធ្វើដូច្នេះនឹងជួយឲ្យយើងខ្ញុំអាចធានាបានថា លិខិតទំនាក់ទាក់ទង, ឯកសារសំខាន់ៗ, កាត (ប្រសិនបើអនុញ្ញាត។ល។) ត្រូវបានបញ្ជូនទៅកាន់អាសយដ្ឋានត្រឹមត្រូវ។

អ្នកយល់ព្រមថា ធនាគារមានឆន្ទានុសិទ្ធិក្នុងការតាមដានប្រតិបត្តិការទាំងអស់ ដែលទាក់ទងនឹងគណនីទាំងអស់របស់អ្នក ក្នុងករណីដែលធនាគារមិនអាចទំនាក់ទំនងមកអ្នកបាន តាមរយៈលេខទូរស័ព្ទរបស់អ្នកដែលចុះបញ្ជីជាមួយធនាគារយើងខ្ញុំ ហើយអ្នកយល់ព្រមធានាសងការខូចខាតជូនធនាគារ សម្រាប់រាល់ការខាតបង់គ្រប់បែបយ៉ាង ដែលកើតឡើងដោយសារធនាគារធ្វើការតាមដានរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងគណនីរបស់អ្នក។

11.5. បច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក

អ្នកមានកាតព្វកិច្ចត្រូវជូនដំណឹងដល់ធនាគារ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលដែលអ្នកមានបច្ចុប្បន្នភាពថ្មីលើព័ត៌មានផ្ទាល់ខ្លួនពីមុន ដែលអ្នកបានផ្តល់មកធនាគារ ក្នុងអំឡុងពេលស្នើសុំបើកគណនី ដើម្បីធានាថា ព័ត៌មានរបស់អ្នកបានធ្វើបច្ចុប្បន្នភាព និងមានភាពពាក់ព័ន្ធគ្នា។ ព័ត៌មានទាំងនេះអាចរួមបញ្ចូល ដោយមិនកំណត់ត្រឹម ឈ្មោះរបស់អ្នក, ថ្ងៃខែឆ្នាំកំណើត, អាសយដ្ឋាន, មុខរបរ, សញ្ជាតិ ,ឯកសារអត្តសញ្ញាណ និងព័ត៌មានអំពីអាសយដ្ឋានទំនាក់ទំនង។

អ្នកយល់ព្រមថា ការខកខានក្នុងការផ្តល់ព័ត៌មានបច្ចុប្បន្នភាព អាចឲ្យធនាគារពុំមានលទ្ធភាពក្សា ឬគ្រប់គ្រងព័ត៌មានបច្ចុប្បន្នភាពរបស់អ្នក នៅក្នុងប្រព័ន្ធរបស់ធនាគារយើងខ្ញុំ ស្របតាមច្បាប់ជាធរមាន ដែលអាចនឹងបណ្តាលឲ្យមានការអាក់អួលខ្លះ១ ឬទាំងស្រុង នៅក្នុងអំឡុងពេលដែលអ្នកប្រើប្រាស់សេវារបស់ធនាគារ និងគណនីរបស់អ្នក។

អ្នកឯកភាពថា ធនាគារអាចមានឆន្ទានុសិទ្ធិក្នុងការបិទដំណើរការ/រឹតត្បិតប្រតិបត្តិការដែលទាក់ទងនឹងគណនីរបស់អ្នកទាំងអស់ ដើម្បីទាមទារឲ្យអ្នកធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។

11.6. បច្ចុប្បន្នភាពនៃឯកសារអត្តសញ្ញាណ

ធនាគារនឹងប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ដើម្បីកំណត់អត្តសញ្ញាណរបស់អ្នកនៅពេលដែលអ្នកប្រើប្រាស់សេវារបស់ធនាគារ។ អ្នកត្រូវដាក់ឯកសារអត្តសញ្ញាណប័ណ្ណថ្មីទៅធនាគារ នៅពេលណាដែលអត្តសញ្ញាណប័ណ្ណចាស់របស់អ្នកដែលក្សាទុកនៅក្នុងប្រព័ន្ធធនាគារក្នុងអំឡុងពេលដែលការបើកគណនីនោះ បានផុតកំណត់ ឬអស់សុពលភាព។ ប្រសិនបើអត្តសញ្ញាណប័ណ្ណរបស់អ្នកអស់សុពលភាព ហើយអ្នកមិនបានធ្វើបច្ចុប្បន្នភាពទេ វាអាចនឹងបង្កឲ្យមានភាពអាក់អួលខ្លះ នៅក្នុងអំឡុងពេលនៃការប្រើប្រាស់សេវារបស់អ្នក ឧទាហរណ៍ ការយឺតយ៉ាវក្នុងការផ្តល់សេវា បុគ្គលិកសាកសួរព័ត៌មាន និងទាមទាររកអត្តសញ្ញាណប័ណ្ណថ្មី ឬការរឹតត្បិតលើការប្រើប្រាស់គណនីរបស់អ្នក។ ដូច្នេះ អ្នកព្រមព្រៀងថា អ្នកផ្តល់បច្ចុប្បន្នភាពដល់ធនាគារ នៅពេលណាដែលអ្នកទទួលបានអត្តសញ្ញាណប័ណ្ណថ្មីនោះ។

11.7. ឯកជនភាព និងការសម្ងាត់

គោលនយោបាយរបស់ធនាគារ ពន្យល់អំពីការប្តេជ្ញាចិត្តរបស់យើងខ្ញុំក្នុងការការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ យើងខ្ញុំប្រកាន់ខ្ជាប់យ៉ាងហ្មត់ចត់នូវឯកជនភាពរបស់អ្នក។ ព័ត៌មានដែលអ្នកផ្តល់ឲ្យមកធនាគារ នឹងត្រូវរក្សាទុកជាការសម្ងាត់ ហើយនឹងត្រូវគ្រប់គ្រងប្រកបដោយសុវត្ថិភាពដោយធនាគារ។ អ្នកមានសិទ្ធិទទួលបានព័ត៌មាននេះ ដោយសួررកនៅសាខាណាមួយរបស់ធនាគារ ហើយអ្នកក៏អាចស្នើសុំការកែតម្រូវព័ត៌មាននោះបានដែរ។

ធនាគារនឹងខិតខំគ្រប់បែបយ៉ាងដើម្បីរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកឲ្យមានបច្ចុប្បន្នភាព។ ដើម្បីជួយយើងខ្ញុំលើរឿងនេះ សូមអ្នកជូនដំណឹងឲ្យយើងខ្ញុំបានដឹងអំពីការផ្លាស់ប្តូរណាមួយនៅក្នុងព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានអំពីធុរកិច្ចរបស់អ្នក មានជាអាទិ៍ អាសយដ្ឋាន, លេខទូរស័ព្ទ, ឬការផ្លាស់ប្តូរចនាសម្ព័ន្ធម្ចាស់កម្មសិទ្ធិធុរកិច្ចរបស់អ្នក។ល។

ការប្រើប្រាស់ព័ត៌មានរបស់អ្នកពីសំណាក់យើងខ្ញុំ នឹងអាស្រ័យទៅតាមគោលបំណងដែលព័ត៌មាននោះត្រូវបានប្រមូល។ ជាទូទៅ ធនាគារអាចនឹងប្រើប្រាស់ព័ត៌មាននេះ ដើម្បី៖

- ពិចារណាទៅលើសំណើសុំប្រើប្រាស់ឧបករណ៍, ផលិតផល និងសេវាផ្សេងៗ
- គ្រប់គ្រង, ចាត់ចែង និងតាមដានទៅលើឧបករណ៍, ផលិតផល ឬសេវានានាដែលបានផ្តល់ដល់អ្នក

- ធ្វើការស្រាវជ្រាវទីផ្សារ, ដំណើរការទិន្នន័យ និងការវិភាគស្ថិតិ និង
- ប្រសិនអ្នកមិនជំទាស់ទេ យើងខ្ញុំនឹងផ្តល់ជូនអ្នកនូវព័ត៌មានអំពីឧបករណ៍ ផលិតផល និងសេវាផ្សេងទៀត ក្នុងនោះរាប់ទាំងផលិតផល និងសេវាជាក់លាក់មួយចំនួនពីភាគីទីបីផងដែរ និង
- ដើម្បីប្រតិបត្តិតាមតម្រូវការនិយតកម្ម ដែលជាក់ឲ្យអនុវត្តលើភាគហ៊ុនិកណាមួយរបស់ធនាគារ។

អ្នកយល់ព្រមថា ធនាគារ និងភាគហ៊ុនិករបស់ខ្លួន ក្រុមហ៊ុន និងសម្ពន្ធដៃគូ («គូភាគី») ដែលពាក់ព័ន្ធ អាចនឹងផ្លាស់ប្តូរជាមួយគ្នាទៅវិញទៅមកនូវព័ត៌មានអំពីរូបអ្នក ក្នុងនោះរាប់ទាំង ៖

- ព័ត៌មាននានា ដែលអ្នកបានផ្តល់នៅក្នុងបែបបទស្នើសុំនានា
- ព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតណាមួយ ដែលអ្នកផ្តល់ជូនយើងខ្ញុំ ឬដែលយើងខ្ញុំទទួលបានដោយស្របច្បាប់អំពីរូបអ្នក និង
- ព័ត៌មានលម្អិតអំពីប្រតិបត្តិការ ឬប្រវត្តិប្រតិបត្តិការ ដែលកើតចេញពីការព្រមព្រៀងរបស់អ្នកជាមួយនឹងធនាគារ។

ប្រសិនបើភាគីណាមួយក្នុងចំណោមគូភាគីនេះ តម្រូវឲ្យអ្នកណាម្នាក់ («អ្នកផ្តល់សេវា») ធ្វើអ្វីមួយជំនួសឲ្យខ្លួន (ឧទាហរណ៍ ជាអ្នកគ្រប់គ្រងប្រព័ន្ធអ៊ីមែល ឬប្រព័ន្ធទិន្នន័យ) នោះអ្នកព្រមព្រៀងថា គូភាគី និងអ្នកផ្តល់សេវាអាចផ្លាស់ប្តូរជាមួយគ្នាទៅវិញទៅមកនូវព័ត៌មានណាមួយដែលមាននៅក្នុងនេះបាន ហើយអ្នកព្រមព្រៀងផងដែរថា ព័ត៌មានទាំងនោះ អាចដំណើរការទាំងនៅកម្ពុជា ឬតាមរយៈសេវាកម្ម ដែលមានទីតាំងស្ថិតនៅប្រទេសផ្សេងមួយទៀត។ ធនាគារអាចនឹងផ្តល់ព័ត៌មានអ្វីមួយទៅឲ្យអង្គភាពផ្សេងទៀត ក្រៅពីគូភាគី និងអ្នកផ្តល់សេវា ក្នុងករណីដែលវាជាតម្រូវការចាំបាច់ ឬអនុញ្ញាតដោយច្បាប់ ឬក្នុងករណីដែលអ្នកបានផ្តល់ការយល់ព្រម។

ធនាគារអាចនឹងប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក សម្រាប់គោលបំណងផ្ទូផ្ទងទិន្នន័យ ហើយដើម្បីធ្វើបែបនេះបាន ធនាគារអាចនឹងប្រមូលព័ត៌មានអំពីរូបអ្នក។ «ការផ្ទូផ្ទងទិន្នន័យ» គឺជាដំណើរការនៃការប្រៀបធៀបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ជាមួយនឹងព័ត៌មានដែលអាចរកបានជាសាធារណៈ និង/ឬព័ត៌មានដែលរក្សាទុកដោយអង្គភាព ដែលធនាគារកំពុងមានទំនាក់ទំនងជាមួយ ដើម្បីអាចឲ្យយើងខ្ញុំមានលទ្ធភាពអនុវត្តគោលបំណងខាងលើបាន។

ធនាគារអាចនឹងបញ្ជូនព័ត៌មានរបស់អ្នក ទៅឲ្យភាគីទីបីដែលជ្រើសរើសយ៉ាងប្រុងប្រយ័ត្នសម្រាប់គោលបំណងនៃការផ្ទូផ្ទងទិន្នន័យ ក្នុងលក្ខខណ្ឌដែលភាគីទីបីទាំងនោះត្រូវស្ថិតក្រោមកាតព្វកិច្ចរក្សាការសម្ងាត់។

ធនាគារអាចទទួលបានព័ត៌មាន ហើយធ្វើការសាកសួរព័ត៌មានទាំងនោះអំពីរូបអ្នក តាមដែលធនាគារគិតថាចាំបាច់ ពីប្រភពនានា ក្នុងនោះរួមទាំងទីភ្នាក់ងារព័ត៌មានឥណទាន សម្រាប់គោលបំណងខាងលើ។

ធនាគារអាចបញ្ជូនព័ត៌មានអំពីរូបអ្នក ប្រាប់ទៅទីភ្នាក់ងារព័ត៌មានឥណទាន សម្រាប់គោលបំណងស្វែងរកបាយការណ៍ឥណទានរបស់អ្នក។ ទីភ្នាក់ងារព័ត៌មានឥណទានទាំងនោះ អាចនឹងរក្សាទុកព័ត៌មាននោះ និងផ្តល់វាទៅឲ្យអតិថិជនរបស់គេ ដែលប្រើប្រាស់សេវារបាយការណ៍ឥណទានរបស់គេ។ ប្រសិនបើអ្នកធ្វើខុសកាតព្វកិច្ចណាមួយចំពោះធនាគារ នោះធនាគារអាចនឹងបញ្ជូនព័ត៌មានអំពីរូបអ្នក ទៅទីភ្នាក់ងារព័ត៌មានឥណទាន ឬទីភ្នាក់ងារស្តារបំណុល ហើយធនាគារអាចរក្សាទុកនូវព័ត៌មានទាំងនោះ ឬព័ត៌មាន អាចត្រូវបានរក្សាទុកភ្នាក់ងារទាំងនោះ។ ទីភ្នាក់ងារទាំងនេះ អាចនឹងផ្តល់ព័ត៌មាននោះទៅឲ្យអតិថិជនដែលប្រើប្រាស់សេវារបាយការណ៍ឥណទានរបស់ពួកគេ។

ធនាគារក៏អាចនឹងបញ្ជូនព័ត៌មានអំពីគណនីទៅឲ្យហត្ថលេខីណាមួយនៃគណនីរបស់អ្នកបានផងដែរ។ ប្រសិនបើអ្នកមានអាយុក្រោម 16 ឆ្នាំ (ពលរដ្ឋខ្មែរ) ឬ18 ឆ្នាំ (ជនបរទេស) ធនាគារអាចនឹងធ្វើការទាក់ទងទៅឪពុកម្តាយ/អាណាព្យាបាលរបស់អ្នក ដើម្បីបង្ហាញព័ត៌មាន, ប្រមូលព័ត៌មាន, ឬទាយកមកវិញនូវចំនួនប្រាក់ណាមួយដែលអ្នកជំពាក់ធនាគារ។

ស្តង់ដារសុវត្ថិភាពរបស់យើងខ្ញុំ ត្រូវបានរក្សា ហើយបច្ចេកវិទ្យារបស់យើងខ្ញុំត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីផ្តល់ការការពារដល់ព័ត៌មានដែលយើងខ្ញុំរក្សាទុក។ យើងខ្ញុំមិនលក់, ផ្សព្វផ្សាយ ឬចែករំលែកព័ត៌មានរបស់អ្នកឡើយ។

អ្នកបានបង្ហាញការយល់ព្រម ក្នុងការទទួលយកហានិភ័យនៃការបំពានទិន្នន័យ បើទោះបីជាធនាគារមានវិធានការពារសុវត្ថិភាពក៏ដោយ ដូច្នេះ ក្នុងនាមជាអតិថិជនអ្នកមិនអាចធ្វើការប្តឹងទាមទារសំណងការខូចខាត ដែលទទួលរងដោយសារការបំពានទិន្នន័យ ប្រសិនបើធនាគារបានអនុវត្តវិធានសុវត្ថិភាពបានត្រឹមត្រូវ។

ច្បាប់ជាក់លាក់ខ្លះ ក็តម្រូវឲ្យធនាគារបញ្ជូនព័ត៌មានរបស់អ្នក ទៅតាមការស្នើសុំដែរ។ ប្រសិនបើធនាគារទទួលបានការស្នើសុំពីទីភ្នាក់ងារជាក់លាក់ ឲ្យបញ្ជូនព័ត៌មានរបស់អ្នក ធនាគារប្រហែលនឹងពុំអាចប្រាប់អ្នកអំពីសំណើនោះឡើយ។ ធនាគារក็អាចបញ្ជូនព័ត៌មានទៅឲ្យនគរបាល, ទីភ្នាក់ងាររដ្ឋាភិបាលជាក់លាក់មួយចំនួន, ធនាគារអន្តរកាវ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងករណីដែលធនាគារជឿជាក់ដោយផ្អែកលើហេតុផលសមស្របថា ការបញ្ជូនព័ត៌មាននេះនឹងជួយដល់ការស៊ើបអង្កេត ការស្វែងរកមុខសញ្ញា និង/ឬទប់ស្កាត់អំពើឆបោក ឬបទល្មើសព្រហ្មទណ្ឌដទៃទៀតដូចជា ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រទេសកម្ពុជា ឬនៅបណ្តាប្រទេសផ្សេងទៀត។ អ្នកយល់ព្រមផ្តល់ព័ត៌មានទាំងអស់ដល់ធនាគារ ដែលទាមទារស្របតាមហេតុអនុលោមតាមច្បាប់ទាំងនេះ។ ច្បាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាធរមាននៅក្នុងប្រទេសកម្ពុជា ឬនៅបណ្តាប្រទេសដទៃទៀត ក็អាចនឹងហាមឃាត់យើងខ្ញុំមិនឲ្យចូលរួមពាក់ព័ន្ធ ឬសម្រេចដំណើរការប្រតិបត្តិការទាំងឡាយណា ដែលជាប់ទាក់ទិននឹងប្រទេសមួយចំនួន បុគ្គល ឬស្ថាប័នជាក់លាក់ណាមួយឡើយ។ ដូច្នេះ អ្នកព្រមព្រៀងថា ធនាគារ អាចនឹង ៖

- ពន្យារពេល ឬរារាំងប្រតិបត្តិការណាមួយ ឬបដិសេធទូទាត់ប្រាក់ណាមួយ ដោយមិនមានកាតព្វកិច្ចទទួលខុសត្រូវឡើយ ឬ
- បញ្ជូនព័ត៌មានណាមួយទាក់ទងនឹងរូបអ្នក ឬប្រតិបត្តិការ ទៅឲ្យនគរបាលកម្ពុជា ឬអាជ្ញាធរពាក់ព័ន្ធនៅកម្ពុជា ឬក្នុងប្រទេសណាមួយ ដើម្បីបញ្ជាក់ថា តើប្រតិបត្តិការរបស់អ្នក ល្មើសនឹងច្បាប់ណាមួយ ពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម ឬការសម្អាតប្រាក់ឬអត់ ក្នុងការជឿជាក់ដោយហេតុផលសមស្របថា ប្រតិបត្តិការនោះអាចផ្ទុយនឹងច្បាប់ទាំងនោះ ហើយធនាគារនឹងមិនមានកាតព្វកិច្ចទទួលខុសត្រូវចំពោះអ្នកដែលទទួលរងដោយសារសកម្មភាពបែបនេះឡើយ។

នៅក្នុងប្រការនេះ «ការសម្អាតប្រាក់» រាប់បញ្ចូលទាំងទំនាក់ទំនងណាមួយដែលជាលទ្ធផលនៃសកម្មភាពបទឧក្រិដ្ឋ និងទំនាក់ទំនងណាមួយពាក់ព័ន្ធនឹងមូលនិធি ឬទ្រព្យរបស់មនុស្សណាម្នាក់ ឬអង្គភាពណាមួយ ដែលត្រូវគេសង្ស័យថាជាប់ពាក់ព័ន្ធនឹងភេរវកម្ម ឬអំពើណាមួយនៃភេរវកម្ម។

11.8. ការជូនដំណឹង និងការទំនាក់ទំនង

ការទំនាក់ទំនងដែលពាក់ព័ន្ធនឹងគណនីរបស់អ្នក ក្នុងនោះរាប់ទាំងរបាយការណ៍គណនី និងការជូនដំណឹងអំពីការផ្លាស់ប្តូរណាមួយចំពោះ ខ និងលក្ខខណ្ឌ នឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់ផ្សេងទៀតណាមួយ ដូចមានចែងនៅក្នុង ខ និងលក្ខខណ្ឌទាំងនេះ ឬអ្វីដែលបានព្រមព្រៀងគ្នាជាមួយធនាគារ។ យើងខ្ញុំអាចប្រើប្រាស់មធ្យោបាយអេឡិកត្រូនិកដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នក។ នេះអាចរាប់បញ្ចូលទាំងការផ្ញើអ៊ីមែលទៅកាន់អ្នក នូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬការប្រាស្រ័យទាក់ទងផ្សេងទៀត អំពីការផ្លាស់ប្តូរនានា ទៅលើផលិតផល និងសេវាកម្មរបស់យើងខ្ញុំ ឬផ្ញើទៅកាន់អ្នកនូវការជូនដំណឹងអំពីការផ្លាស់ប្តូរនានាសម្រាប់ការពិនិត្យនៅក្នុងសេវាធនាគារអនឡាញ ឬនៅលើវិបសាយរបស់យើងខ្ញុំ។

ប្រសិនបើយើងខ្ញុំទំនាក់ទំនងទៅកាន់អ្នកជាលាយលក្ខណ៍អក្សរដោយផ្ទាល់ យើងខ្ញុំនឹងផ្ញើសំណេរនោះទៅកាន់អាសយដ្ឋានថ្មីបំផុតដែលអ្នកបានផ្តល់ឲ្យយើងខ្ញុំ។ ក្នុងករណីដែលយើងខ្ញុំផ្ញើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ តាមសំបុត្រធម្មតា យើងខ្ញុំចាត់ទុកថាការជូនដំណឹងនោះ ត្រូវបានផ្តល់ជូនដល់ដៃហើយ ក្នុងរយៈពេល 3 (បី) ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីយើងខ្ញុំបានផ្ញើចេញ។

11.9. កាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងការទប់ស្កាត់ហិរញ្ញប្បទានភេរវកម្ម

យើងខ្ញុំសូមណែនាំថា ដើម្បីបំពេញកាតព្វកិច្ចផ្លូវច្បាប់ និងកាតព្វកិច្ចប្រតិបត្តិតាមរបស់យើងខ្ញុំ យើងខ្ញុំនឹងបង្កើនកម្រិតត្រួតពិនិត្យ និងការតាមដានដែលយើងខ្ញុំនឹងអនុវត្ត។ អ្នកគួរដឹងថា៖

- ប្រតិបត្តិការអាចនឹងពន្យាពេល, រាំងខ្ទប់, បង្ក្រក ឬបដិសេធ ក្នុងករណីដែលយើងខ្ញុំមានហេតុផលគ្រប់គ្រាន់ដើម្បីជឿថា ប្រតិបត្តិការទាំងនោះបំពានច្បាប់ ឬទណ្ឌកម្មជាធរមាន (ឬច្បាប់ ឬទណ្ឌកម្មរបស់ប្រទេសផ្សេងទៀត)។ ក្នុងករណីដែលប្រតិបត្តិការត្រូវបានពន្យាពេល, រាំងខ្ទប់, បង្ក្រក ឬបដិសេធ ធនាគារ និងធនាគារអន្តរការីរបស់ខ្លួន នឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ណាមួយដែលអ្នកទទួលរងឡើយ (រួមទាំងលទ្ធផលដែលបណ្តាលពីការបាត់បង់នោះផងដែរ) ដែលបង្កឡើងក្នុងរូបភាពណាក៏ដោយ ពាក់ព័ន្ធនឹងផលិតផលបញ្ញើណាមួយ
- ជាប្រចាំ យើងខ្ញុំអាចនឹងត្រូវការព័ត៌មានចាំបាច់បន្ថែមពីរូបអ្នក ដើម្បីជួយយើងខ្ញុំនៅក្នុងដំណើរការប្រតិបត្តិតាមខាងលើ (ឧទាហរណ៍ ការយកចិត្តទុកដាក់ស្គាល់អតិថិជន និងអ្នកចូលរួមប្រតិបត្តិការ) និង
- ក្នុងករណីដែលតម្រូវដោយច្បាប់ យើងខ្ញុំនឹងបញ្ជូនព័ត៌មានដែលបានប្រមូល ទៅឲ្យទីភ្នាក់ងារនិយ័តកម្ម និង/ឬទីភ្នាក់ងារអនុវត្តច្បាប់ ធនាគារដទៃទៀត សមាជិកដទៃទៀតនៃបុត្រសម្ពន្ធរបស់ធនាគារ អ្នកផ្តល់សេវា ឬទៅឲ្យភាគីទីបីផ្សេងទៀត។

អ្នកផ្តល់ជូនធនាគារនូវការសន្យាដូចខាងក្រោម និងធានារ៉ាប់រងចំពោះធនាគារ សម្រាប់ការបាត់បង់ណាមួយដែលអាចកើតចេញពីការរំលោភបំពានណាមួយរបស់អ្នក ទៅលើការសន្យាទាំងនេះ ៖

- អ្នកនឹងមិនផ្ទួចផ្តើម, ចូលរួមនៅក្នុង ឬអនុវត្តប្រតិបត្តិការ ដែលអាចនឹងបំពានច្បាប់ ឬទណ្ឌកម្មជាធរមាន (ឬច្បាប់ ឬទណ្ឌកម្មរបស់ប្រទេសផ្សេងទៀត) ឡើយ និង
- សកម្មភាពជាមូលដ្ឋានដែលផលិតផលបញ្ញើណាមួយកំពុងត្រូវបានផ្តល់ជូនមិនរំលោភលើច្បាប់ ឬទណ្ឌកម្មជាធរមានណាមួយ (ឬច្បាប់ ឬទណ្ឌកម្មរបស់ប្រទេសផ្សេងទៀតឡើយ)។

11.10. ឥណទាននៃការប្រាក់

ធនាគារទូទាត់ការប្រាក់សម្រាប់សមតុល្យឥណទាននៅក្នុងប្រភេទគណនីមួយចំនួន។ ការប្រាក់ត្រូវបានគណនាតាមចំនួនថ្ងៃ សម្រាប់ការប្រាក់ដែលគណនីប្រាក់សន្សំ និងគណនីប្រតិបត្តិការទទួលបាន និងត្រូវបានបញ្ចូលទៅក្នុងគណនីរបស់អ្នកនៅថ្ងៃកំណត់ទូទាត់។ ថ្ងៃកំណត់ទូទាត់សម្រាប់គណនីរបស់អ្នក ត្រូវចំថ្ងៃប្រតិទិនដូចគ្នានៃខែនីមួយៗ ឬនៃត្រីមាសនីមួយៗ អាស្រ័យទៅលើប្រភេទគណនីរបស់អ្នក។ ប្រសិនបើថ្ងៃកំណត់ទូទាត់ការប្រាក់សម្រាប់គណនីរបស់អ្នក ប៉ះចំថ្ងៃមិនធ្វើការ នោះថ្ងៃទូទាត់ការប្រាក់សម្រាប់គណនីរបស់អ្នក នឹងរំកិលទៅថ្ងៃធ្វើការបន្ទាប់នៃខែដោយស្វ័យប្រវត្តិ។

ការប្រាក់ដែលបង់ ឬដាក់ចូលគណនីដោយធនាគារ នឹងត្រូវកាត់ពន្ធតាមច្បាប់ពន្ធជាធរមាន។ ស្ថានភាពពន្ធរបស់ម្ចាស់គណនី នឹងកំណត់អំពីប្រភេទ និងចំនួនទឹកប្រាក់ដែលត្រូវកាត់សម្រាប់ការបង់ពន្ធ។ ធនាគារពឹងផ្អែកលើស្ថានភាពពន្ធ និងព័ត៌មានពន្ធ (បើសមស្រប) ដែលផ្តល់ដោយម្ចាស់គណនី។ ពន្ធកាត់ទុកសម្រាប់និវាសនជន (“RWT”) នឹងត្រូវកាត់យកពីការទូទាត់ការប្រាក់ ដែលបង់ទៅឲ្យម្ចាស់គណនីជាពលរដ្ឋកម្ពុជា។ ប៉ុន្តែ RWT ត្រូវអនុវត្តចំពោះជនបរទេសដែលបាននិងកំពុងរស់នៅក្នុងប្រទេសកម្ពុជារយៈពេលយ៉ាងហោចណាស់ 182 ថ្ងៃជាប់ៗគ្នា ឬបញ្ជាក់ថានឹងរស់នៅក្នុងប្រទេសកម្ពុជា រយៈពេលយ៉ាងហោចណាស់ 182 ថ្ងៃ ដោយផ្តល់ឯកសារកំស្តុតាងគ្រប់គ្រាន់ ដូចជា កិច្ចសន្យាការងារ, កិច្ចសន្យាជួលផ្ទះ ឬការកាន់កាប់អាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ស្ថានភាពពន្ធនិវាសនជន ត្រូវបានជ្រើសរើសក្នុងអំឡុងពេលបើកគណនីដំបូង នៅពេលដែលអ្នកផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់បុគ្គលិករបស់យើងខ្ញុំ។ ចំពោះម្ចាស់គណនីអនិវាសនជន ពន្ធកាត់ទុកសម្រាប់អនិវាសនជន (“NRWT”) នឹងត្រូវកាត់កង។ យើងខ្ញុំពឹងផ្អែកលើភាពត្រឹមត្រូវនៃឯកសារ និងព័ត៌មានដែលបានផ្តល់ ដើម្បីជ្រើសរើសស្ថានភាពពន្ធត្រឹមត្រូវសម្រាប់គណនីរបស់អ្នក។

ធនាគារអាចផ្អាកការបង្ករការប្រាក់ និងផ្អាកការទូទាត់ការប្រាក់ចំពោះគណនីដែលត្រូវបានបង្ក្រក ឬផ្អាកដំណើរការដោយសារតែទណ្ឌកម្មអន្តរជាតិ ដើម្បីចៀសវាងហានិភ័យនៃការដាក់ទណ្ឌកម្មបន្ទាប់បន្សំ។

សម្រាប់គណនីខ្លះ ប្រាក់នៅសល់ក្នុងគណនី (សមតុល្យ) ត្រូវតែលើសចំនួនកំណត់អប្បបរមាជាក់លាក់ ទើបធនាគារធ្វើការទូទាត់ការប្រាក់ឲ្យទៅអ្នក។ ធនាគារអាចនឹងកំណត់ ឬផ្លាស់ប្តូរសមតុល្យអប្បបរមាជាក់លាក់សម្រាប់ការទូទាត់ប្រាក់ និងសមតុល្យជាក់លាក់ណាមួយ សម្រាប់ការទូទាត់ការប្រាក់ក្នុងអត្រាខ្ពស់ពិសេស។ អ្នកនឹងទទួលបានការជូនដំណឹងអំពីការកែប្រែ រួមជាមួយកាលបរិច្ឆេទនៃការកែប្រែនោះផងដែរ។

11.11. គណនីបញ្ញើមានកាលកំណត់

ខ និងលក្ខខណ្ឌខាងក្រោមនេះ អនុវត្តចំពោះគណនីបញ្ញើមានកាលកំណត់ និងរួមជាមួយ ខ និងលក្ខខណ្ឌដែលមានចែងនៅក្នុងវិញ្ញាបនបត្របញ្ញើមានកាលកំណត់ ឬបែបបទស្នើសុំ (ប្រសិនបើមាន)។

ការប្រាក់ដែលអាចទូទាត់បាន ក្នុងអំឡុងរយៈពេលនៃបញ្ញើមានកាលកំណត់របស់អ្នក មិនបូកបញ្ចូលនឹងប្រាក់ដើមទេ។ ប៉ុន្តែ ការប្រាក់ណាមួយដែលអាចទូទាត់បាននៅកាលវិសាន្ត អាចបូកបន្ថែមដោយស្វ័យប្រវត្តិទៅលើចំនួនប្រាក់ដើមដែលត្រូវសងវិញ ដើម្បីបង្កើតបានជាបញ្ញើមានកាលកំណត់ថ្មី។

លើកលែងតែមានការយល់ព្រមពីធនាគារ រយៈពេលនៃបញ្ញើមានកាលកំណត់របស់អ្នក គឺថេរ ហើយអ្នកមិនអាចផ្ទេរប្រាក់បញ្ញើនោះ ឬដកប្រាក់បញ្ញើនោះបានទេ ដរាបណាវាមិនទាន់ដល់កាលវេលាកំណត់ ឬកាលវិសានត្រូវដក។ សំណើសុំដកមុនពេលកំណត់ និង/ឬសុំដកខ្លះនូវប្រាក់បញ្ញើមានកាលកំណត់ (ប្រសិនបើត្រូវបានអនុញ្ញាត) ត្រូវតែមានការយល់ព្រមពីធនាគារ។ ធនាគារអាចនឹងកំណត់យកថ្លៃសេវាសម្រាប់ការដកប្រាក់បញ្ញើមុនកាលកំណត់។

ប្រសិនបើកាលកំណត់ ឬកាលវិសានត្រូវដកប្រាក់បញ្ញើមានកាលកំណត់របស់អ្នកប៉ះចំថ្ងៃមិនធ្វើការ នោះនឹងត្រូវរំកិលទៅថ្ងៃធ្វើការបន្ទាប់។

ប្រាក់បញ្ញើមានកាលកំណត់មិនអាចដកដោយប្រើមូលប្បទានបត្របុគ្គលបានទេ។ ក្នុងករណីដែលសមស្រប និងដោយការយកចិត្តទុកដាក់សមហេតុផលសម្រាប់សេវាបំពេញបន្ថែមរបស់ខ្លួន (ទោះជាធនាគារ មិនត្រូវបានតម្រូវឲ្យធ្វើដូច្នេះ) ធនាគារនឹងទាក់ទងទៅអ្នក នៅមុនកាលវិសាននៃប្រាក់បញ្ញើមានកាលកំណត់របស់អ្នក។

កម្រៃ និងបន្ទុកសេវារដ្ឋាភិបាលដែលត្រូវអនុវត្ត ក្នុងនោះរាប់ទាំងពន្ធកាត់ទុកសម្រាប់និវាសនជន ឬពន្ធកាត់ទុកសម្រាប់អនិវាសនជន អាចនឹងត្រូវកាត់ដោយធនាគារ ABA ចេញពីគណនីបញ្ញើមានកាលកំណត់របស់អ្នក ឬពីគណនីដែលបានកំណត់ដោយអ្នក។

11.12. សំណើប្រតិបត្តិការតាមទូរស័ព្ទ ឬតាមអ៊ីមែល

ធនាគារមិនអាចអនុញ្ញាតឲ្យអ្នក ឬបុគ្គលណាម្នាក់ដែលផ្តល់សិទ្ធិដោយអ្នក ធ្វើការស្នើប្រតិបត្តិការសម្រាប់គណនីណាមួយ តាមរយៈការហៅទូរស័ព្ទទៅកាន់សាខារបស់ធនាគារឡើយ។ ប្រសិនបើធនាគារអនុញ្ញាតឲ្យធ្វើដូច្នេះ អ្នកព្រមព្រៀងថា ៖

- មូលនិធិអាចផ្ទេរទៅមកតែរវាងគណនីដែលស្ថិតនៅក្រោមឈ្មោះរបស់អ្នកប៉ុណ្ណោះ
- ការមើលព័ត៌មានប្រតិបត្តិការអាចធ្វើបានតែអំពីគណនីដែលស្ថិតក្រោមឈ្មោះរបស់អ្នកប៉ុណ្ណោះ
- ធនាគារអាចនឹងបដិសេធ ដោយមិនអនុវត្តតាមសំណើណាមួយដែលធនាគារមិនពេញចិត្ត ជាមួយសំណើធ្វើឡើងដោយអ្នក ឬមនុស្សដែលអ្នកបានផ្តល់សិទ្ធិឲ្យ
- ធនាគារមិនមានកាតព្វកិច្ចត្រូវបង្កើតអត្តសញ្ញាណ ឬសិទ្ធិអំណាចរបស់អ្នកណាម្នាក់ (រួមទាំងខ្លួនអ្នក) ដែលដាក់សំណើប្រតិបត្តិការនោះឡើយ
- ធនាគារអាចនឹងកំណត់ចំនួនអប្បបរមាទាក់ទងនឹងប្រភេទសំណើប្រតិបត្តិការ ហើយអាចនឹងកែប្រែចំនួនបែបនេះ នៅពេលណាមួយ ដោយមិនចាំបាច់ជូនដំណឹងឡើយ, ហើយ
- អ្នកនឹងធានារ៉ាប់រងសងធនាគារ ចំពោះការខាតបង់ណាមួយ ដែលធនាគារទទួលរងដោយសារសំណើប្រតិបត្តិការណាមួយ (ក្នុងនោះរាប់ទាំងការផ្តល់ព័ត៌មានខុស ឬមិនពិតពីសំណាក់រូបអ្នក ឬបុគ្គលណាម្នាក់ដែលអ្នកផ្តល់សិទ្ធិឲ្យ ឬបុគ្គលដែលអះអាងថាត្រូវបានអ្នកផ្តល់សិទ្ធិឲ្យ) លើកលែងតែការខាតបង់ណាមួយដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ធនាគារដោយផ្ទាល់។

11.13. តើត្រូវធ្វើដូចម្តេចប្រសិនបើអ្នកមានបញ្ហា ឬបណ្តឹងទាមទារ?

ប្រសិនបើអ្នកមិនសប្បាយចិត្តអំពីអ្វីមួយដែលយើងខ្ញុំបានដោះស្រាយ - ឬអ្វីដែលប្រហែលជាយើងខ្ញុំមិនបានដោះស្រាយ - សូមផ្តល់ឱកាសឲ្យយើងខ្ញុំបានធ្វើការកែតម្រូវផង។ ក្នុងករណីដែលអាចធ្វើទៅបាន យើងខ្ញុំនឹងព្យាយាមដោះស្រាយបណ្តឹងរបស់អ្នកនៅនឹងកន្លែង ដើម្បីរកដំណោះស្រាយភ្លាមៗ។ ប្រសិនបើយើងខ្ញុំត្រូវការពេលវេលាបន្ថែមខ្លះទៀត ដើម្បីត្រលប់ទៅជួបអ្នកវិញ យើងខ្ញុំនឹងជម្រាបឲ្យអ្នកបានដឹង។ ក្នុងករណីដែលយើងខ្ញុំមិនអាចដោះស្រាយបញ្ហារបស់អ្នកនៅពេលអ្នកទាក់ទងមកលើកដំបូងបានទេនោះ យើងខ្ញុំនឹងបញ្ជូនបណ្តឹងនេះទៅកាន់អង្គភាពជំនាញផ្នែកដោះស្រាយបណ្តឹង និងជម្លោះ។

គោលបំណងនៃអង្គភាពដោះស្រាយបណ្តឹងរបស់យើងខ្ញុំ គឺឆ្លើយតបទៅនឹងបណ្តឹងរបស់អ្នកឲ្យបានឆាប់ហ៊ាសបំផុតតាមដែលអាចធ្វើទៅបាន ប៉ុន្តែទោះជាយ៉ាងណាបណ្តឹងខ្លះអាចនឹងត្រូវការពេលដោះស្រាយយូរជាងបណ្តឹងខ្លះទៀត។ យើងខ្ញុំនឹងជូនដំណឹងឲ្យអ្នកបានដឹងអំពីវឌ្ឍនភាពនៃការដោះស្រាយបណ្តឹងរបស់អ្នក។

អ្នកអាចទាក់ទងមកយើងខ្ញុំ ដោយប្រើ ៖

- ប្រព័ន្ធទូរស័ព្ទ តគិតថ្លៃ 1 800 203 203 សម្រាប់ការហៅក្នុងប្រទេសកម្ពុជា និងលេខទូរស័ព្ទ +855 98 203 203 សម្រាប់ការហៅក្រៅប្រទេសកម្ពុជា
- អ៊ីមែល ៖ info@ababank.com / complaintresolution@ababank.com ឬ
- ចូលទៅកាន់វិបសាយ www.ababank.com ហើយស្វែងរក 'បែបបទបញ្ជូញមតិ'

ប្រសិនបើអ្នកនៅតែមិនទាន់ពេញចិត្តចំពោះលទ្ធផលនៃការដោះស្រាយបណ្តឹងរបស់អ្នកទេ សូមមើលទៅផ្នែក 5.7 ដើម្បីស្វែងរកចំណាត់ការបន្ត (ភាពខុសគ្នា, បញ្ហាអាក់ដំណើរការ, ចម្ងល់, បណ្តឹងតវ៉ា) ដែលអ្នកអាចធ្វើបាន ។

12. ដំណោះស្រាយវិវាទ

ខ និងលក្ខខណ្ឌទាំងនេះ ត្រូវស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ រាល់ទំនាស់កើតឡើងពី ឬជាប់ពាក់ព័ន្ធនឹង ខ និងលក្ខខណ្ឌទូទៅនេះ រួមមានចម្ងល់លើវត្តមានភាព, សុពលភាព, ការអនុវត្ត និងការបញ្ចប់ ខ និងលក្ខខណ្ឌទូទៅ ត្រូវបញ្ជូនទៅកាន់ គុណាការនៃយុត្តាធិការមានសមត្ថកិច្ចក្នុងប្រទេសកម្ពុជា ប្រសិនបើកម្មវត្ថុនៃទំនាស់មានទឹកប្រាក់តិចជាង 10,000 ដុល្លារអាមេរិក ។ ប្រសិនបើ កម្មវត្ថុនៃទំនាស់ មានទឹកប្រាក់ច្រើនជាង 10,000 ដុល្លារអាមេរិក នោះទំនាស់ត្រូវបញ្ជូនទៅកាន់ និងដោះស្រាយចុងក្រោយដោយ មជ្ឈត្តការ ក្រោមមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា អនុលោមតាម ច្បាប់មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ច្បាប់ មជ្ឈត្តការ ម.ជ.ម.) ជាធរមាន អំឡុងពេលចាប់ផ្តើមមជ្ឈត្តការ និងដោយយោងតាមប្រការនេះ ច្បាប់ មជ្ឈត្តការ ម.ជ.ម. ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃខ និងលក្ខខណ្ឌទាំងនេះ ។ អាសនៈនៃមជ្ឈត្តការ ត្រូវស្ថិតនៅក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ សាលាជម្រះក្តីត្រូវមានមជ្ឈត្តករមួយរូប ។ ភាសាមជ្ឈត្តការ ត្រូវតែជាភាសាអង់គ្លេស ។

- ចប់ -

ABA T&C V11_06192026

ABA BANK
NATIONAL BANK OF CANADA GROUP

អគារលេខ 141, 146, 148, 148 អា បេ សេ ដេ និង162 អា មហាវិថីព្រះសីហនុ
អគារលេខ 15 និង 153 អា បេ សេ ផ្លូវ 278 និង អគារលេខ 171 ផ្លូវព្រះត្រសក់ផ្អែម
សង្កាត់បឹងកេងកងទី 1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធឥតគិតថ្លៃ៖ 1 800 203 203 | (+855) 23 225 333
info@ababank.com | www.ababank.com